ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន និងការចូលរួមរបស់សហគមន៍ នៅវិទ្យាល័យមេសាង ច័ន្ទក្រឹស្នា និងវិទ្យាល័យអង្គរស ស្រុកមេសាង

# THE RELATIONSHIP BETWEEN SCHOOL ACCOUNTABILITY AND COMMUNITY ENGAGEMENT AT MESANG, CHANKRISHNA AND ANGKOR SOR HIGH SCHOOLS IN MESANG

គាន ជានី

KEAN CHEANY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩
ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន
# និងការចូលរួមរបស់សហគមន៍
# នៅវិទ្យាល័យមេសាង ច័ន្ទក្រឹស្នា និងវិទ្យាល័យអង្គរស
# ស្រុកមេសាង

# THE RELATIONSHIP BETWEEN SCHOOL ACCOUNTABILITY AND COMMUNITY ENGAGEMENT AT MESANG, CHANKRISHNA AND ANGKOR SOR HIGH SCHOOLS IN MESANG


គាន ជានី

KEAN CHEANY


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩
ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០២០-២០២២

គ្រូណែនាំគោលៈ លោកបណ្ឌិត អៃ សុងហ៊ាង

គ្រូណែនាំរងៈ លោក ចាប រតនា

# សេចក្ដីប្រកាសអះអាងរបស់បេក្ខជន

នាងខ្ញុំ **គាន ជានី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៩ ឯកទេស គ្រប់គ្រងអប់រំ នៃ វិទ្យាស្ថានជាតិ អប់រំ។

សូមធ្វើការអះអាងថា ខ្លឹមសារក្នុងនិក្ខេបបទស្ដីពី **«ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន និងការចូលរួមរបស់សហគមន៍ នៅវិទ្យាល័យមេសាង ច័ន្ទក្រឹស្នា និងវិទ្យាល័យអង្គរស ស្រុកមេសាង»** គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំពិតៗ ដោយមិនបានក្លែងបន្លំ ឬពាក់ព័ន្ធជាមួយនឹងនិក្ខេបបទអ្នកដទៃទេ ក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីទទួលបានសញ្ញាបត្រ។ ទិន្នន័យ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ ដែលបានលើកឡើងនៅក្នុងនិក្ខេបបទ គឺថ្មី ហើយមិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងនិក្ខេបបទរបស់គេឡើយ។

នាងខ្ញុំសូមសន្យាថា និក្ខេបបទនេះមិនមានការក្លែងបន្លំ និងមិនមានការលួចចម្លងពីនិស្សិត ឬស្នាដៃអ្នកទៃ។ ក្នុងករណីដែលវិទ្យាស្ថានជាតិអប់រំពិនិត្យឃើញថា មានករណីខាងលើកើតឡើងពិតប្រាកដមែន នាងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃ ព្រហស្បតិ៍ ១៣ កើត ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២២

**ហត្ថលេខា**

**គាន ជានី**

# លិខិតបញ្ជាក់

**លោកបណ្ឌិត អ៊ែ សុខហ៊ាង** ជាគ្រូណែនាំគោល

**លោក ចាប រតនា** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោកស្រី **គាន ដានី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី »ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន និងការចូលរួម របស់សហគមន៍ នៅវិទ្យាល័យមេសាង ច័ន្ទក្រីស្នា និងវិទ្យាល័យអង្គរស ស្រុកមេសាង « ពិតប្រាកដមែន។

ថ្ងៃសុក្រ ១១កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០២២

**លោកបណ្ឌិត អ៊ែ សុខហ៊ាង**
នាយកមជ្ឈមណ្ឌល តំបន់អាស៊ីអាគ្នេយ៍
សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស

**លោក ចាប រតនា**
អនុប្រធាន ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ

# សេចក្តីថ្លែងអំណរគុណ

ជាបឋម នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះលោកអ្នកមានគុណទាំងពីរគឺលោកឪពុកអ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូនឱ្យបានទទួលការសិក្សារហូតរូបកូនមានថ្ងៃនេះ និងសូមថ្លែងអំណរគុណយ៉ាងច្រើនបំផុតដល់ឧត្តមស្វាមីជាទីស្រឡាញ់របស់ខ្ញុំ កូនៗ ជាទីស្រលាញ់ និងមិត្តភក្តិ ដែលបានគាំទ្រ និងលើកទឹកចិត្តខ្ញុំនៅក្នុងកំលុងពេលសិក្សានេះ។

សូមគោរពថ្លែងអំណរគុណដល់ក្រសួងអប់រំយុវជននិងកីឡា វិទ្យាស្ថានជាតិអប់រំនិងមូលនិធិគាំទ្រការអប់រំអន្តរជាតិ(CIESF) ដែលបានរៀបចំផ្តល់អាហារូបករណ៍ដល់រូបនាងខ្ញុំដើម្បីបានចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនេះ។

នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មការគ្រប់គ្រង ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ និងមមាញឹកបំផុត មកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់ គ្នា។ ជាពិសេស នាងខ្ញុំសូមគោរពថ្លែងអំណរគុណ ចំពោះលោកបណ្ឌិត អែ សុងហ៊ាង សាស្ត្រាចារ្យដឹកនាំនិង លោក ចាប រតនា ជាគ្រូដឹកនាំរង នៃការសរសេរនិក្ខេបបទ ដែលលោកទាំងពីរ បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការត្រួតពិនិត្យ វាយតម្លៃ ជួយណែនាំ និងផ្តល់យោបល់ណែនាំដល់រូបនាងខ្ញុំក្នុងការសរសេរនិក្ខេបបទស្តីពី«**ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន និងការចូលរួមរបស់សហគមន៍ នៅវិទ្យាល័យមេសាង ចន្ទគ្រីស្នា និងវិទ្យាល័យអង្គរស ខេត្តព្រៃវែង**»។

នាងខ្ញុំសូមថ្លែងអំណរគុណដល់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅតាមសាលាគោលដៅទាំងអស់ដែលបានអនុញ្ញាត និងចូលរួមសហការ ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោក

លោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**សេចក្តីប្រកាសអះអាងរបស់បេក្ខជន** ........ ii

**លិខិតបញ្ជាក់** ........ iii

**សេចក្តីថ្លែងអំណរគុណ** ........ iv

**មាតិកា** ........ vi

**បញ្ជីតារាង** ........ ix

**បញ្ជីរូបភាព** ........ x

**ឧបសម្ព័ន្ធ** ........ xi

**បញ្ជីអក្សរកាត់** ........ xii

**មូលន័យសង្ខេប** ........ xiii

**ជំពូកទី១៖ សេចក្តីផ្តើម** ........ 2

១១ លំ.នាំបញ្ហានៃការស្រាវជ្រាវ ........ 2

១២ ចំណោទបញ្ហានៃការស្រាវជ្រាវ. ........ 8

១៣ គោលបំណងនៃការស្រាវជ្រាវ. ........ 10

១.៤ សំណួរនៃការស្រាវជ្រាវ ........ 10

១៥ សារៈសំខាន់នៃការស្រាវជ្រាវ. ........ 10

១៦ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........ 11

១.៧ .រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 11

**ជំពូកទី២៖ រំលឹកទ្រឹស្តី** ........ 15

២១ សេចក្តីផ្តើម........................................................................................................15

២២ និយមន័យនៃពាក្យគន្លឹះ.......................................................................................16

២៣ គណនេយ្យភាពសាលារៀន....................................................................................19

២៤ ទំនាក់ទំនងរវាងគណនេយ្យភាព.សាលារៀន និងការចូលរួមរបស់សហគមន៍ ................23

២៥ កម្រិតនៃទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀននិងការចូលរួមរបស់សហគមន៍.............26

២៦ កត្តាប្រសិទ្ធភាពនៃគណនេយ្យភាពសាលារៀន.......................................................31

២៧ សកម្មភាពរបស់សហគមន៍ក្នុងការចូលរួមចំណែកអភិវឌ្ឍសាលារៀន...........................34

២៨ សមទ្ធិផលរបស់របស់សហគមន៍ក្នុងការចូលរួមចំណែកអភិវឌ្ឍសា.លារៀន....................36

២៩ ការវិភាគការអនុវត្តការងាររបស់សាលារៀន...........................................................41

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ**..................................................................................53

៣១ វិធីស្រាវជ្រាវ.........................................................................................................53

៣ ២.ការជ្រើសរើសភាគសំណាក....................................................................................53

៣៣ ឧបករណ៍ស្រាវជ្រាវ.................................................................................................54

៣៤ ការប្រមូលទិន្នន័យ..................................................................................................55

៣៥ ការវិភាគទិន្នន័យ.....................................................................................................56

**ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ**.............................................................................58

៤១ លទ្ធផលនៃការស្រាវជ្រាវ..........................................................................................58

៤.២ ដែនកំណត់នៃការស្រាវជ្រាវ ..................................................................................61

៤៣ ការពិភាក្សា............................................................................................................65

**ជំពូកទី៥សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 70

៥១ សេចក្តីសន្និដ្ឋាន. ........ 70

៥២ សំណូមពរ. ........ 70

**ប្រភពឯកសារយោង** ........ 73

**ឧបសម្ព័ន្ធ «ក»** ........ 77

**ឧបសម្ព័ន្ធ «ខ»** ........ 81

# បញ្ជីតារាង

តារាងទី ១៖ Model Summary ........................................... Error! Bookmark not defined.

តារាងទី ២៖ ANOVA ........................................................................................59

តារាងទី ៣៖ Coefficients.......................................................................................60

តារាងទី ៤៖ វិទ្យាល័យទាំងបី គ្រូបង្រៀនមានអាយុ ........................................................ 61

តារាងទី ៥៖ វិទ្យាល័យទាំងបី គ្រូបង្រៀនមានភេទ ........................................................ 61

តារាងទី ៦៖ វិទ្យាល័យទាំងបី គ្រូបង្រៀនមានបទពិសោធ...................................................62

តារាងទី ៧៖ វិទ្យាល័យទាំងបី គ្រូបង្រៀនមានកម្រិតវប្បធម៌...............................................63

តារាងទី ៨៖ វិទ្យាល័យទាំងបី ចំនួនគ្រូបង្រៀនដែលបានចូលរួមក្នុងការប្រមូលទិន្នន័យ ……………...63

# បញ្ជីរូបភាព


រូបភាពទី ១៖ ប្រព័ន្ធ ៣ អា បិទជិត ........ 42

រូបភាពទី ២៖ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានឆ្ពោះទៅរកគណនេយ្យភាព ........ 43

រូបភាពទី ៣៖ យុទ្ធសាស្ត្រសហគមន៍សាលារៀន (៦អា) ........ 46

រូបភាពទី ៤៖ ក្របខណ្ឌនិងលំដាប់អនុវត្តយុទ្ធសាស្ត្រសហគមន៍និងសាលារៀន ........ 50

រូបភាពទី ៥៖ កម្រិតទំនាក់ទំនងខ្ពស់ដែលបណ្ដុំទិន្ន័យទទួលបាន ........ 61

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ «ក»

កម្រងសំណួរស្រាវជ្រាវ………………………………………………………………………………77

## ឧបសម្ព័ន្ធ «ខ»

ឧបសម្ព័ន្ធទី 1៖ លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា …………..81

ឧបសម្ព័ន្ធទី 2៖ លិខិតឧទ្ទេសនាមគ្រូដឹកនាំគោល និងគ្រូដឹកនាំរងសម្រាប់ការសរសេរនិក្ខេបបទ ……85

ឧបសម្ព័ន្ធទី 3៖ លិខិតឧទ្ទេសនាមគ្រូដឹកនាំគោល និងគ្រូដឹកនាំរងសម្រាប់ការសរសេរនិក្ខេបបទ ……88

ឧបសម្ព័ន្ធទី ៤៖ លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា …………92

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| DOE | District Office of Education | ការិយាល័យអប់រំ យុវជន និងកីឡា |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| PoE | Provincial Department of Education | មន្ទីរអប់រំ យុវជន និងកីឡា |
| SBM | School-Based Management | ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល |
| SSC | School Support Committee | គណៈកម្មការទ្រទ្រង់សាលារៀន |
| SA | School Accountability | គណនេយ្យភាពសាលារៀន |
| CE | Community Engagement | ការចូលរួមរបស់សហគមន៍ |

# មូលន័យសង្ខេប

ការសិក្សាលើប្រធានបទស្តីពី **"ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន និងការចូលរួមរបស់ សហគមន៍ នៅវិទ្យាល័យមេសាង ច័ន្ទក្រឹស្នា និងវិទ្យាល័យអង្គរស ស្រុកមេសាង"** នាពេលនេះ ធ្វើឡើងស្របពេលជាមួយនឹងកំណែទម្រង់វិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដាក់អោយអនុវត្តគោលនយោបាយស្តី ពី យុទ្ធសាស្ត្រ សហគមន៍សាលារៀន។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដើម្បីពិនិត្យមើលទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន(school accountability) និងការចូលរួមរបស់សហគមន៍ (community engagement)។

ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងតាមបែបបរិមាណវិស័យ។ ភាគសំណាកក្នុងការស្រាវជ្រាវគឺគ្រូបង្រៀន និង ដោយប្រើកម្រងសំណួរជាឧបករណ៍ស្រាវជ្រាវឱ្យសំណាកបំពេញ។ ជាលទ្ធផល គ្រូភាគច្រើនបាន យល់ដឹងច្បាស់និងឆ្លើយតបដោយការយល់និងភាពត្រឹមត្រូវ។ ការអនុវត្តគណនេយ្យភាព និងការចូលរួមរបស់សហគមន៍ បានបង្ហាញពីភាពមានទំនាក់ទំនងគ្នា។ ទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់គុណភាពអប់រំ នៃគណៈគ្រប់គ្រងតាមសាលារៀនរបស់ពួកគាត់។ តែទោះបីជាយ៉ាងណាក៏ដោយក៏នៅមានបញ្ហាប្រឈមខ្លះកើតឡើង ដែលមានជាអាទិ៍គណៈគ្រប់គ្រងតាមសាលារៀន គ្រូមួយចំនួនតូចមិនទាន់បានអនុវត្តបានទៀងទាត់ និងតម្លាភាពនៅឡើយ។ តែទោះបីជាយ៉ាងនេះក្តី គណៈគ្រប់គ្រងតាមសាលារៀន គ្រូ ភាគច្រើនមានទស្សនៈយល់ឃើញជារួមគ្នាថា ការអនុវត្តទៅលើគណនេយ្យភាពសាលារៀន ពិតជាមានទំនាក់ទំនងខ្លាំងដល់ការចូលរួមរបស់សហគមន៍ប្រាកដមែន ទាំងនេះបានជួយអភិវឌ្ឍ សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន បង្កើនលទ្ធផលសិក្សារបស់សិស្ស សហគមន៍ អាណាព្យាបាលសិស្ស មានសេចក្តីទុកចិត្ត និងផ្តល់តម្លៃដល់សាលារៀន ចូលរួមគ្រប់សកម្មភាពនានារបស់សាលា និងបានជួយបង្កើនទំនាក់ទំនង និងសាមគ្គីភាពផ្ទៃក្នុងបានល្អ ដើម្បីឱ្យសាលារៀន មានការអភិវឌ្ឍលើគ្រប់ផ្នែក ជាពិសេសបង្កើនលទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរជាងមុន។ ជាសេចក្តីសន្និដ្ឋាន ការអនុវត្តគណនេយ្យភាពសាលារៀន ពិតជាមានទំនាក់ទំនងខ្លាំងដល់ការចូលរួមរបស់សហគមន៍ប្រាកដមែន ហើយសហគមន៍គឺជាធនធានមិនចេះរីងស្ងួត ដែលអាចរួមចំណែកក្នុងការចូលរួមអភិវឌ្ឍការបង្រៀន និង

រៀន សុខភាពសិក្សារបស់សិស្សមិនអាចកាត់ផ្ដាច់បាន។កត្តាទាំងនេះ ពិតជាបានរួមចំណែកដល់ការអនុវត្តគោលនយោបាយអប់រំ និងកំណែទម្រង់វិស័យអប់រំនៅកម្ពុជា។

ពាក្យគន្លឹះ៖ *គណនេយ្យភាពសាលារៀន, ការចូលរួមរបស់សហគមន៍, សាលាមធ្យមសិក្សាចំណេះទូទៅ។*

# ABSTRACT

The current study on the topic of "The Relationship between School Accountability and Community Engagement at Mesang, Chankrisna and Angkor Sor High School in Mesang " is conducted underway with the education reform of Ministry of Education, Youth and Sports, implementing policies on school community strategies. The purpose of this study was to examine the relationship between school accountability and community engagement.

This research was conducted on a quantitative basis. The samples participated in the research were secondary school teachers and questionnaire was used as research instrument. As a result, most teachers are clear and responsive with understanding and accuracy. The practice of accountability and community involvement has shown a correlation. These reflect the high focus on improving the quality of education from their school leaders. However, there are still some challenges, such as some school leaders and teachers have not yet implemented regularly and transparently. On the other hand, most of school leaders and teachers agree that the implementation of school accountability is absolutely correlated to the participation of the community. This relationship certainly helps to develop the professional capacity of teachers, improve student outcomes, gain trust and appreciation from the community, students' parents on school values, participate in all school activities, and help increase internal relationships and solidarity so that the school develops in all areas, especially reinforcing student achievement. In conclusion, the implementation of school accountability has a strong relationship with community engagement, and the community is an inexhaustible resource that can contribute to the development of teaching and learning, students' health. These factors have really contributed to the implementation of education policies and education reform in Cambodia.


Keywords: *school accountability, community engagement, general education secondary school*.

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ស្ថានភាពពិភពលោកមានការរីកចម្រើនជារៀងរាល់ថ្ងៃឥតឈប់ឈរ និងមានការប្រកួតប្រជែងយ៉ាងខ្លាំងទាំងផ្នែកសេដ្ឋកិច្ច នយោបាយ និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីឆ្លើយតបជាមួយនឹងសន្ទុះនៃការរីកចម្រើននេះប្រទេសភាគច្រើនទូទាំងសកលលោកទាំងនៅលោកខាងលិច ក៏ដូចជាអាស៊ីបានផ្តោតទៅលើការអភិវឌ្ឍប្រទេសរបស់ខ្លួនដោយចាប់អារម្មណ៍ខ្លាំងទៅលើការវិនិយោគផ្នែកចំណេះដឹងប្រជាពលរដ្ឋរបស់ខ្លួន។ ការណ៍នេះវិស័យអប់រំជាតិត្រូវបានគេចាប់អារម្មណ៍និងយកចិត្តទុកដាក់យ៉ាងខ្លាំងខ្លាក្នុងការអនុវត្តយន្តការ វិធីសាស្ត្រ និងរៀបចំគោលនយោបាយ ដើម្បីសម្រេចគោលដៅបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធិផល។ ទន្ទឹមនឹងបរិបទពិភពលោកមានទំនោរបែបនេះកម្ពុជាបានបោះជំហានរបស់ខ្លួនដល់ដំណាក់កាលថ្មីមួយនៃការអភិវឌ្ឍវិស័យអប់រំដើម្បីឆ្លើយតបជាមួយនឹងបរិបទតំបន់ ដែលមានមហិច្ឆតានិងវិសាលភាពទូលំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាពអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតក្នុងក្របខណ្ឌទូលំទូលាយគ្របដណ្តប់លើគ្រប់ប្រភេទ និងគ្រប់កម្រិតនៃការអប់រំជាពិសេសស្របនឹងទស្សនៈវិស័យអភិវឌ្ឍកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។

ដើម្បីសម្រេចមហិច្ឆតានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលការអភិវឌ្ឍធនធានមនុស្ស គឺជាផ្នែកមួយនៃការសម្រមសម្រួលគោលនយោបាយគាំទ្រ។ កំណែទម្រង់វិស័យអប់រំ សំដៅលើកកម្ពស់គុណភាពអប់រំ និងអភិវឌ្ឍធនធានមនុស្ស ស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៥-២០៣០។

ក្នុងន័យនេះការអប់រំសម្រាប់ឆ្នាំ២០៣០ផ្តោតជាសំខាន់ទៅលើការផ្តល់សេវាប្រកបដោយ គុណភាព សមធម៌ បរិយាបន្ន សម្រាប់កុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំ

បច្ចេកទេស និងវិជ្ជាជីវៈជាពិសេសការសិក្សាពេញមួយជីវិតដើម្បីបង្កើនប្រសិទ្ធិភាព គុណភាព ផលិតភាព ការងារស្របតាមយុគសម័យបច្ចេកវិទ្យាក្នុងការបង្កើនសេដ្ឋកិច្ចនិងសុខុដុមជីវិតបុគ្គលនិងសង្គម។

ជាមួយគ្នានេះដែរ សន្និបាតអប់រំ ២០១៥ បានដាក់ចេញនូវវិធានការកំណែទម្រង់វិស័យអប់រំដំណាក់កាលទី២ គឺកំណែទម្រង់សាលារៀន។ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះក្រសួងបានសាកល្បងអនុវត្តកំណែទម្រង់សាលារៀន ដោយបានបង្កើតនូវគំរូកំណែទម្រង់ចំនួន២គឺះ

**ទី១. ការបង្កើតសាលារៀនជំនាន់ថ្មី** តាមការស្នើសុំរបស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ។ សាលារៀនជំនាន់ថ្មីមានស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សា ដើម្បីបណ្តុះធនធានមនុស្សមានបំណិន សតវត្សទី២១។

**ទី២. ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព (SBM)** ដោយផ្តោតលើគោលការណ៍ចំនួន ៥គឺះ

ទី១- គណនេយ្យភាពសាលារៀន (Accountability) ៖ នាយកសាលាត្រូវមានគណនេយ្យភាព ចំពោះមាតាបិតា ដោយបង្កើតគណៈកម្មការសាលារៀន និងចុះកិច្ចសន្យាលទ្ធផលការងារប្រចាំឆ្នាំ, ការប្រជុំវាយតម្លៃ, និងស្វ័យវាយតម្លៃ ដើម្បីសម្រេចស្តង់ដារសាលារៀនមានប្រសិទ្ធភាព។

ទី២- ស្វ័យភាព (Autonomy)៖ សាលារៀនរៀបចំផែនការកែលម្អសាលារៀន ដើម្បីដោះស្រាយបញ្ហាចំពោះមុខ ជាពិសេសដើម្បីជួយបង្កើតបរិស្ថានអំណោយផលសម្រាប់ ការរៀនសូត្រ, ការជួយគាំទ្រគ្រូ, កែលម្អវប្បធម៌សលារៀន, និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ តាមរយៈកម្មវិធីលើកកម្ពស់គុណវុឌ្ឍិនាយក (LUP)។

ទី៣- វង្វាយតម្លៃ Assessment ៖ ការរៀបចំតេស្តស្តង់ដារមានតម្លាភាព និងយុត្តិធម៌ដើម្បីកែម្អការបង្រៀន ដោយបង្រៀនបន្ថែមជួយដល់សិស្សរៀន

យឺត និងផ្សព្វផ្សាយលទ្ធផល ជាសាធារណៈនិងផ្តល់ព័ត៌មានពីលទ្ធផលដល់មាតាបិតា។

ទី៤- ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន Attention to Teachers ៖ គ្រូប្រើលទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន ការចុះកិច្ចសន្យាវាយតម្លៃលទ្ធផលការងារនិងការបង្កើនគុណវុឌ្ឍិគ្រូតាមរយៈកម្មវិធីបង្កើនគុណវុឌ្ឍិគ្រូ (TUP)។

1. ទី៥- ការចូលរួម Participation៖ មាតាបិតាចូលរួមគាំទ្រសាលា ដើម្បីរួមគ្នាអភិវឌ្ឍសាលារៀន។ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨ក)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យអប់រំ ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ការអភិវឌ្ឍវិស័យអប់រំទាមទារឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធផល។

វិស័យអប់រំ ពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹងនិង សមត្ថភាពខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ចការពង្រឹងភាពប្រកួតប្រជែងនិងលើកកម្ពស់ផលិតភាព។

តបទៅនឹងចក្ខុវិស័យអប់រំដែលបានលើកឡើងខាងលើ គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ គឺជាកត្តាគន្លឹះក្នុងការជួយសិស្សឱ្យសម្រេចបានលទ្ធផលល្អប្រសើរក្នុងការសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)។ នៅក្នុងគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥នេះផងដែរ បានដាក់ចេញនូវគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាពសមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្របសីលធម៌វិជ្ជាជីវៈនិងផ្តល់លក្ខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិក្នុងគោល

ដៅទីបួនបានដៅថាជានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀននិងការបបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាព សក្តិសិទ្ធិផងដែរ។

គុណភាពអប់រំ គឺជាអាទិភាពមួយដែលត្រូវយកចិត្តទុកដាក់ហើយវាអាស្រ័យលើគុណភាពនាយកសាលារៀននិងគុណភាពរបស់គ្រូបង្រៀន។ ការអភិវឌ្ឍសាលារៀនទាមទារឱ្យមានការបង្កើតនូវរចនាសម្ព័ន្ធគ្រប់គ្រងមួយច្បាស់លាស់ប្រកបដោយការទទួលខុសត្រូវ គណនេយ្យភាព តម្លាភាពស្របតាមគោលការណ៍អភិបាលកិច្ចល្អជាពិសេសការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨ក)។

ដើម្បីឆ្លើយតបជាមួយនឹងគោលបំណង និងគោលដៅនេះតួនាទីរបស់នាយកសាលាក្នុងការគ្រប់គ្រង ដឹកនាំ ពិនិត្យតាមដាន វាយតម្លៃ សម្របសម្រួលទៅលើដំណើរនៃការបំពេញភារកិច្ចបុគ្គលិករបស់ខ្លួនពិតជារឿងចាំបាច់បំផុតដែលជានាទៅដល់គុណភាពនៃការសិក្សារបស់សិស្សានុសិស្សនៅក្នុងសាលារបស់ពួកគាត់។

ហេតុផលជាច្រើនដូចដែលបានរៀបរាប់មកខាងលើនេះហើយ ទើបជំរុញទឹកចិត្តឱ្យអ្នកសិក្សាស្រាវជ្រាវមានចំណាប់អារម្មណ៍ ដើម្បីស្វែងយល់ពីផលជះនៃគុណភាពសិក្សារបស់សិស្សានុសិស្សកម្រិត វិទ្យាល័យនៅក្នុងខេត្តព្រៃវែងដែលទទួលបានប្រសិទ្ធភាពពីការគ្រប់គ្រងបុគ្គលិករបស់នាយកសាលានីមួយៗ។

ម្យ៉ាងវិញទៀតការគ្រប់គ្រង និងការដឹកនាំ នៅក្នុងអង្គភាពសាលារៀនប្រកបដោយចីរភាព គឺទាមទារឱ្យនាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀនមានបំណិនក្នុងការកៀរគរធនធានពីគ្រប់មជ្ឈដ្ឋាន បង្កើនការចូលរួម និងជំនឿទុកចិត្តពីគ្រប់ អ្នកពាក់ព័ន្ធ ក្នុងការអនុវត្តសកម្មភាពនៅកម្រិតសាលារៀន ជាពិសេសត្រូវធ្វើស្វ័យវាយតម្លៃសាលារៀន ដើម្បីឃើញលទ្ធផលវឌ្ឍនភាព និងបញ្ហាប្រឈមនានា ក្នុងការអនុវត្តសកម្មភាពនោះដែលជាមូលដ្ឋានសម្រាប់ធ្វើការកែលម្អ តាមរយៈការរៀបចំផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ។

ទន្ទឹមនិងមានការកំណែទម្រង់លើវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែង និងមានចក្ខុវិស័យ ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ម៉្យាងទៀតដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ការកសាងធនធានមនុស្សឱ្យមានសមត្ថភាពខ្ពស់គឺជាគន្លឹះមួយយ៉ាងសំខាន់បំផុត សម្រាប់ឆ្លើយតបទៅនឹងបរិបទសកលភាវូបនីយកម្ម សមាហរណកម្មក្នុងតំបន់ និងជានាបានការប្រកួតប្រជែងក្នុងទីផ្សារពលកម្មដោយបើកចំហរ។ នេះហើយដែលតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡាបានខិតខំបំពេញតួនាទីចម្បងក្នុងការកសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ ដែលជាធាតុយ៉ាងសំខាន់លើគ្រប់វិស័យដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនដោយផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ស្របជាមួយនឹងការរីកចម្រើនប្រព័ន្ធអប់រំកម្ពុជា នៅមានបញ្ហាប្រឈមមួយចំនួនដែលទាមទារឱ្យមានការយក ចិត្តទុកដាក់កម្រិតខ្ពស់បន្ថែមទៀត។ ការសិក្សាជាសាកលបង្ហាញថា គុណភាពអប់រំគឺជាកត្តាគន្លឹះសម្រាប់កំណើនសេដ្ឋកិច្ច។ ក្នុងន័យនេះ ដើម្បីរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើន ចាំបាច់ត្រូវលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀន មានន័យថាការចូលរៀននាំឱ្យសិស្សអាចបង្កើនចំណេះដឹង ពោលគឺបើ សិស្សរៀនកាន់តែច្រើន នោះសេដ្ឋកិច្ចនឹងរីកចម្រើនកាន់តែឆាប់រហ័ស (Hanushek and Woessmann 2008)។ គួរកត់សម្គាល់ថា ប្រទេសដែលទទួលលទ្ធផលតេស្ត១កម្រិតពិន្ទុ ធ្វើឱ្យផលទុនសរុបក្នុងមួយនាក់ក្នុងមួយ ឆ្នាំច្រើនជាង២ពិន្ទុភាគរយរយៈពេល៤០ឆ្នាំ (Hanushek and Woessmann 2008)។ មួយវិញទៀត ការវិនិយោគ តែលើហេដ្ឋារចនាសម្ព័ន្ធនឹងមិនមានផលវិជ្ជមានដល់ការីកចម្រើនផ្នែកសេដ្ឋកិច្ចទេ តែបើការវិនិយោគផ្តោត ទាំងលើការអភិវឌ្ឍមូលធនមនុស្ស និងរចនាសម្ព័ន្ធជាពិសេសសម្រាប់វិស័យអប់រំ នោះនឹងអាចកំណត់បានពី កំណើនសេដ្ឋកិច្ច។

ពាក់ព័ន្ធនឹងការអភិវឌ្ឍមូលធនមនុស្ស តាមទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការសិក្សា ស្រាវជ្រាវរបស់ធនាគារពិភពលោក «ការអប់រំមនុស្សជំនាន់ក្រោយ» បង្ហាញនូវការបែងចែង និងប្រសិទ្ធភាព នៃការប្រើប្រាស់ធនធាន មានដូចជាការបែងចែកគ្រូបង្រៀនមិនស្របតាមតម្រូវការឧទាហរណ៍ ផលធៀបគ្រូ/សិស្សនៅមធ្យមសិក្សា ក្នុងរាជធានីភ្នំពេញគឺ ១/១៤.៨ តែនៅខេត្តព្រៃវែង ១/

២៩.៩។ ការបំពេញការងាររបស់គ្រូបង្រៀនវិញ ជាមធ្យម ៤៧.៦ភាគរយ នៃសំណាកគំរូមានកិច្ចតែងការបង្រៀន ក្នុងនោះ ៦៦.២ភាគរយ គឺជាគ្រូបង្រៀននៅតំបន់ប្រជុំជន និងមានតែ ៣៤.៧ភាគរយ ប៉ុណ្ណោះ សម្រាប់គ្រូបង្រៀននៅតំបន់ជនបទនិង ដាច់ស្រយាល។ គ្រូបង្រៀនដែលអវត្តមានញឹកញាប់ មានចំនួន ៦ ភាគរយ ក្នុងនោះ ៣.៦ភាគរយ នៅតំបន់ប្រជុំ ជន ៧.៦ភាគរយ នៅតំបន់ជនបទ និង១០.២ភាគរយនៅតំបន់ដាច់ស្រយាល។

សរុបមក ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវពង្រឹងគណនេយ្យភាពក្នុងប្រព័ន្ធអប់រំ ដើម្បីធានាថា សាលារៀនទទួលបានធនធាន(គ្រូបង្រៀន និងសម្ភាររូបវន្ត) ដែលមានគុណភាព ស្របតាមនិយាម/ស្តង់ដា កំណត់ហើយសាលារៀនត្រូវប្រើប្រាស់ធនធានទាំងនោះឱ្យអស់លទ្ធភាព។ ផ្អែកតាមស្ថានភាពខាងលើ និងសមត្ថភាពដែលមានស្រាប់ ក្រសួងអប់រំ យុវជន និងកីឡា ផ្តោតលើការអន្តរាគមន៍ និងផ្តល់ការគាំទ្រដល់ សាលារៀនមួយចំនួនដើម្បីក្លាយជាសាលារៀនមានឧត្តមានុវត្ត និងបំពេញបាននូវស្តង់ដាសាលារៀនមាន ប្រសិទ្ធភាព។ ការចូលរួម និងការប្តេជ្ញាចិត្តរបស់មន្ត្រីអប់រំនៅគ្រប់កម្រិត របស់សិស្សានុសិស្ស របស់សហគមន៍ និងមាតាបិតា/អ្នកអាណាព្យាបាល ជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន (Fata & Kreng , ២០១៦)។

មួយវិញទៀតដោយឃើញថា គណៈកម្មការគ្រប់គ្រងសាលាបានជួបប្រទះបញ្ហាប្រឈមយ៉ាងខ្លាំងអំពីវិធីការអភិវឌ្ឍសាលារៀនតាមផ្នែក ព្រោះពួកគាត់មិនយល់ដឹងច្បាស់អំពីតួនាទីភារកិច្ច និងការទទួលខុសត្រូវ។ នៅពេលនោះ គណៈកម្មការគ្រប់គ្រងសាលាមិនមានសកម្មភាពខ្លាំង ឬចូលរួមក្នុងប្រតិបត្តិការសាលានោះទេ។ ពួកគាត់មិនបានតាមដានសង្កេត ត្រួតពិនិត្យ ឬវាយតម្លៃការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្ស ព្រមទាំងគ្មានធនធានគ្រប់គ្រាន់សម្រាប់អភិវឌ្ឍន៍សាលារៀន និង ជាពិសេសមិនទាន់មានការចូលរួមល្អពី សហគមន៍ ដោយឃើញថាការចូលរួមរបស់សហគមន៍នៅមានកម្រិតនៅឡើយ និងដោយហេតុថាសាលារៀនមួយ អភិវឌ្ឍន៍ទៅបានល្អ ប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាព លុះត្រាតែសាលាមានការចូលរួមពីសហគមន៍បានល្អប្រសើរ ហេតុនេះហើយទើបរូបខ្ញុំ ចង់សិក្សាស្រាវជ្រាវ លើប្រធានបទ «ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន (school accountability) និងការចូលរួម

របស់សហគមន៍ (community engagement) នៅវិទ្យាល័យមេសាង ច័ន្ទក្រឹស្នា និងវិទ្យាល័យអង្គរស ក្នុង ស្រុកមេសាង»។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ចាប់តាំងពីឆ្នាំ២០១៧ កំណែទម្រង់វិស័យអប់រំចាប់ផ្តើមផ្តោតលើ ការជម្រុញកំណែទម្រង់ឱ្យដល់កម្រិត សាលារៀន ដោយក្រសួងអប់រំយុវជន និង កីឡា បានអនុម័តឯកសារទស្សនាទានស្តីពីការគ្រប់គ្រងសាលារៀន ដោយផ្តោតសំខាន់លើ សមាសភាព៤គឺ ១) ការគ្រប់គ្រងរដ្ឋបាល ២) ការគ្រប់គ្រងការរៀន និងបង្រៀន ៣) ការគ្រប់គ្រងធនធានមនុស្ស ៤) ការគ្រប់គ្រងហិរញ្ញវត្ថុ។ មុំទី ៣ កំណែទម្រង់សាលារៀន សំដៅជម្រុញ ប្រសិទ្ធិភាពការងារ នៃការងារដឹកនាំនិងគ្រប់គ្រង ពង្រឹងកញ្ចប់សមត្ថភាពគ្រូបង្រៀន បានបញ្ជាក់យ៉ាងច្បាស់ថា សាលារៀនគឺបានដើរតួនាទីយ៉ាងសំខាន់ធ្វើឱ្យសម្រេចចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងគោលបំណងរួមនៃការផ្តល់សេវាអប់រំជូនដល់សិស្សានុសិស្ស។ ការគ្រប់គ្រងសាលារៀន (School Based Management ) ជាកម្មវិធីកំណែទម្រង់មួយរបស់ក្រសួង ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំសាលារៀនបច្ចុប្បន្ន ឱ្យក្លាយជាសាលារៀនសហគមន៍ ដើម្បីសហគមន៍ និងសហគមន៍ចូលរួមអភិវឌ្ឍផ្តោតទៅលើ បណ្តុះបណ្តាលអ្នកសិក្សា ឱ្យទទួលបានលទ្ធផលសិក្សា ឆ្លើយតបទៅនិងតម្រូវការរបស់មូលដ្ឋាន និងសម្រេចបានតាមគោលដៅអប់រំជាតិ និងគោលបំណងកម្មវិធីសិក្សាកម្រិតមូលដ្ឋាន។ គោលនយោបាយទី២ ក្នុងវិស័យអប់រំ ក៏បានផ្តោតទៅលើការជានាភាពស័ក្តិសមនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង មន្រ្តីអប់រំ គ្រប់លំដាប់ថ្នាក់ ដោយសំដៅលើការអនុវត្ត និងបំពេញការងារ របស់មន្រ្តីអប់រំ ដែលឆ្លុះបញ្ចាំងឱ្យឃើញថា ប្រសិទ្ធិភាពនៃការដឹកនាំ គ្រប់គ្រងរបស់នាយក ជាមាគ៌ាឆ្ពោះទៅរកភាពជោគជ័យនៃការសិក្សារបស់សិស្ស។ យោងតាមសៀវភៅកំណែទម្រង់សាលារៀននៅកម្ពុជា (២០២០) បានលើកឡើងថា នាយកល្អ គឺនាយកដែលបង្កើតបរិស្ថានល្អសម្រាប់ការរៀន និងការបង្រៀន (២៥ភាគរយនៃលទ្ធផលសិក្សារបស់សិស្ស)។

ក្នុងការអភិវឌ្ឍន៍ការងារប្រចាំថ្ងៃនៅសាលារៀន នាយកសាលាគឺជាអ្នកដែលទទួលខុសត្រូវលើដំណើរការរៀននិងបង្រៀន ព្រមទាំងលទ្ធផលសិក្សារបស់សិស្សផងដែរ។ ការងារផែនការកែលម្អសាលា

រៀន ជាមធ្យោបាយដ៏មានសក្តានុពល សម្រាប់ធ្វើឱ្យបានប្រសើរឡើងវិញ នូវប្រពៃណីជួយអាសាគ្នា និងរូបរួមសាគ្គីគ្នានៅក្នុងសហគមន៍អភិវឌ្ឍសាលារៀន ផ្តោតលើលទ្ធផលសិក្សារបស់សិស្ស ជាពិសេសសិស្សមកពីគ្រួសារជួបការលំបាក និងការលំបាករបស់គ្រូបង្រៀន ក្នុងការងារបង្រៀន និងរៀន ។

ការធ្វើផែនការកែលម្អសាលារៀនឱ្យបានម៉ត់ចត់ គឺជាការចូលរួមដើម្បីពិភាក្សាកំណត់សកម្មភាពជាអាទិភាព និងបានឆ្លងជាមួយសិស្សានុសិស្ស មាតាបិតា អ្នកអាណាព្យាបាល គណៈកម្មការគ្រប់គ្រងសាលារៀន អជ្ញាធរដែនដី នគរបាល មណ្ឌលសុខភាព និង ស្ថាប័ន ផ្តល់សេវាកម្មសង្គមផ្សេងៗទៀតក្នុងមូលដ្ឋាន។ ការដឹកនាំគ្រប់គ្រងលើបំលាស់ប្តូរ មានភាពចាំបាច់ណាស់ ពិសេសក្នុងដំណើរការគ្រប់គ្រងសាលារៀន ដើម្បីដំណើរការ និងទទួលបានជោគជ័យក្នុងស្ថានភាពប្រកួតប្រជែងទាំងទីផ្សារការងារ និងកម្លាំងពលកម្ម បច្ចេកវិទ្យា ទាំងក្នុងតំបន់និងពិភពលោក។ សាលារៀនបច្ចុប្បន្នដំណើរការក្នុងបរិបទមួយដែលមានការប្រែប្រួលជាបន្តបន្ទាប់ដូចជា ចំណេះដឹង និងព័តមានជាដើម។ បញ្ហាប្រឈមមួយដែលជាបន្ទុកដ៏ធំនោះ គឺការបន្ថែមនូវភាពយល់ចំណេះដឹងដ៏ត្រឹមត្រូវនៅបញ្ហាដែលកំពុងកើតឡើង និងថ្មីនៅក្នុងសង្គមពុទ្ធិ ក្នុងខណៈដែល វាកំពុងជះឥទ្ធិពលលើដំណើរការរៀនសូត្រ ដូចជាការរីករាលដាលនៃជម្ងឺ កូវីដ-១៩ ការរៀនតាមប្រព័ន្ធអនឡាញ និងការរៀនតាមគន្លងជីវិតថ្មីជាដើម។ ជារួមមកនាយកសាលា ត្រូវធ្វើបច្ចុប្បន្នភាពលើក្របខណ្ឌចំណេះដឹងភាពជាអ្នកដឹកនាំគ្រប់គ្រង និងបំណិនលើការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័អប់រំដែលជាផ្នែកមួយនៃកិច្ចកសាងសមត្ថភាពតាមរយៈ ការសិក្សាជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់លើការដឹកនាំគ្រប់គ្រងបំលាស់ប្តូរ និងអាចដោះស្រាយបញ្ហាប្រឈមដែលកើតមានក្នុងសហគមន៍។

គណៈកម្មការគ្រប់គ្រងសាលាបានជួបប្រទះបញ្ហាប្រឈមយ៉ាងខ្លាំង អំពីវិធីការអភិវឌ្ឍសាលារៀនតាមផ្នែក ព្រោះពួកគាត់មិនយល់ដឹងច្បាស់អំពីតួនាទីភារកិច្ច និងការទទួលខុសត្រូវ។ នៅពេលនោះ គណៈកម្មការគ្រប់គ្រងសាលាមិនមានសកម្មភាពខ្លាំង ឬចូលរួមក្នុងប្រតិបត្តិការសាលានោះទេ។ ពួកគាត់មិនបានតាមដានសង្កេត ត្រួតពិនិត្យ ឬវាយតម្លៃការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្ស ព្រមទាំងគ្មានធនធានគ្រប់គ្រាន់សម្រាប់អភិវឌ្ឍន៍សាលារៀនទេ និង ជាពិសេសមិនទាន់មានការចូលរួមល្អពី សហគមន៍ ដោយឃើញថាការចូលរួមរបស់សហគមន៍នៅមានកម្រិតនៅឡើយ និងដោយឃើញថាសាលារៀន

មួយ អភិវឌ្ឍន៍ទៅបានល្អ ប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាព លុះត្រាតែសាលាមានការចូលរួមពីសហគមន៍បានល្អប្រសើរ ហេតុនេះហើយទើបរូបខ្ញុំ ចង់សិក្សាស្រាវជ្រាវ លើប្រធានបទ «ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន (school accountability) និងការចូលរួមរបស់សហគមន៍ (community engagement) នៅវិទ្យាល័យមេសាង ច័ន្ទក្រឹស្នា និងវិទ្យាល័យអង្គរស ក្នុងស្រុកមេសាង»។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ដើម្បីពិនិត្យមើលទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន (school accountability) និងការចូលរួមរបស់សហគមន៍ (community engagement)។

## ១.៤ សំណួរនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងគោលបំណងខាងលើការស្រាវជ្រាវនេះបានលើកឡើងនូវសំណួរ ពីរ ៖

១. តើគណនេយ្យភាពសាលារៀន (school accountability)មានទំនាក់ទំនងទៅនឹងការចូលរួមរបស់សហគមន៍ដែរឬទេ(community engagement) ?

២. តើគណនេយ្យភាពសាលារៀន (school accountability)មានទំនាក់ទំនងដល់កម្រិតណាទៅលើការចូលរួមរបស់សហគមន៍(community engagement) ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានសារៈសំខាន់ណាស់ក្រោយពីការទទួលបានលទ្ធផលនៃការស្រាវជ្រាវ យើងនឹងអាចពន្យល់បានពី គណនេយ្យភាពសាលារៀន និងការចូលរួមរបស់សហគមន៍ ក្នុងការជួយអភិវឌ្ឍសាលា ប្រកបដោយនិរន្តរភាព ព្រោះសហគមន៍ ជាធនធានមិនចេះរីងស្ងួតរបស់សាលារៀន សាលាដែលមានការកសាងទំនាក់ទំនងល្អជាមួយសហគមន៍ ជាសាលាដែល មានហេដ្ឋារចនាសម្ព័ន្ធល្អ មានគណគ្រប់គ្រងល្អ និងគ្រូល្អ ប្រកបដោយមនសិការវិជ្ជាជីវៈ ដែលជាកត្តារុញច្រានដល់លទ្ធផលសិក្សារបស់សិស្សានុសិស្ស ស្របតាមគោលដៅរបស់ក្រសួងអប់រំ។ការចាយថវិការបស់សាលារៀន កាន់តែមានភាពត្រឹមត្រូវ តាមតម្រូវការជាក់ស្តែងរបស់សាលាពិសេសគ្រូ និងសិស្ស ការបែងចែកផលលាភនិងភារកិច្ចជូនគ្រូកាន់តែមានប្រសិទ្ធិភាព សមស្របតាមកម្រិតយល់ដឹង និងកម្រិតជំនាញរបស់គាត់ ការចូលរួមរបស់

សហគមន៍កាន់តែមានភាពសកម្ម និងឆ្លុះបញ្ចាំងពីចក្ខុវិស័យ និងបេសកកម្មរបស់សាលារៀន ធនធានខាងក្រៅនឹងកើនឡើងដោយការគ្រប់គ្រងរបស់សាលារៀន មានប្រសិទ្ធិភាពនិងប្រសិទ្ធផលជាងមុន។ ជាពិសេសអត្រាសិស្សឡើងថ្នាក់ និងប្រឡងជាប់នឹងកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ស្របតាម គោលដៅរបស់ក្រសួងអប់រំ។

ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងជួយលើកកម្ពស់គុណភាពអប់រំប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៅក្នុងវិស័យអប់រំ។

## ១.៦ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងត្រូវធ្វើឡើងនៅក្នុងវិទ្យាល័យ មេសាង ច័ន្ទក្រឹស្នា និងអង្គរស ស្ថិតក្នុងស្រុក មេសាង ខេត្តព្រៃវែង ដែលសំណាកគឺជាគ្រូ នៅវិទ្យាល័យទាំង ៣ នេះ។ ការសិក្សាស្រាវជ្រាវនេះបានអនុវត្តលើគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ កម្រិតថ្នាក់ទី៧ ដល់ទី១២) ក្នុងខេត្តព្រៃវែង។ វិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យ ត្រូវបានប្រើប្រាស់ដើម្បីសិក្សាទំនាក់ទំនងរបស់អថេរ ដោយមានការចូលរួមផ្តល់ទិន្នន័យពីគ្រូបង្រៀន។

អ្នកស្រាវជ្រាវលើកពីលក្ខណៈជាក់ស្តែងដែលបានធ្វើការស្រាវជ្រាវ និងវិភាគទៅលើចំណុចទាំងអស់ដែលបានអនុវត្តជាក់ស្តែងដើម្បីរកឱ្យឃើញថា តើវាដូចគ្នាទៅនឹងទ្រឹស្តីឬទេ គឺក្នុងគោលបំណងវិភាគរកឱ្យឃើញចំណុចខ្វះខាតដើម្បីកែលម្អបន្ថែមទៀត។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដំណើរការស្រាវជ្រាវត្រូវបានបែងចែកជាប្រាំជំពូកធំៗគឺ៖

- **ជំពូកទី១៖ សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

១.៣ គោលបំណងនៃការស្រាវជ្រាវ

១.៤ សំណួរនៃការស្រាវជ្រាវ

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

១.៦ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- **ជំពូកទី២៖ រំឭកទ្រឹស្តី**

២.១ លំនាំបញ្ហានៃការស្រាវជ្រាវ

២.២ និយមន័យនៃពាក្យគន្លឹះ

២.៣ គណនេយ្យភាពសាលារៀន

២.៤ ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន និងការចូលរួមរបស់សហគមន៍

២.៥ កម្រិតនៃទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន និងការចូលរួមរបស់

សហ

គមន៍

២.៦ កត្តាប្រសិទ្ធភាពនៃគណនេយ្យភាព សាលារៀន

២.៧ សកម្មភាពរបស់សហគមន៍ក្នុងការចូលរួមចំណែកអភិវឌ្ឍសាលារៀន

២.៨ សមិទ្ធិផលរបស់សហគមន៍ ក្នុងការចូលរួមចំណែកអភិវឌ្ឍសាលារៀន

២.៩ ការវិភាគការអនុវត្តការងាររបស់សាលារៀន

- **ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ**

៣.១ វីធីសាស្ត្រស្រាជ្រាវ

៣.២ ការជ្រើសរើសភាគសំណាក

៣.៣ ឧបករណ៍ស្រាវជ្រាវ

៣.៤ ការប្រមូលទិន្នន័យ

៣.៥ ការវិភាគទិន្នន័យ

**ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវ និងការវិភាគ**

៤.១ លទ្ធផលនៃការស្រាវជ្រាវ

៤.២ ដែនកំណត់នៃការស្រាវជ្រាវ

៤.៣ ការពិភាក្សា

- **ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

៥.១ សេចក្តីសន្និដ្ឋាន

៥.២ សំណូមពរ

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២៖ រំលឹកទ្រឹស្តី

## ២.១ សេចក្តីផ្តើម

ដើម្បីសម្រេចនូវគោលដៅអប់រំប្រកបដោយចីរភាពក្នុងឆ្នាំ២០៣០ ក្រសួងអប់រំយុវជននិងកីឡាបាន ដាក់ ចេញនូវផែនទីបង្ហាញផ្លូវអប់រំសម្រាប់កម្ពុជា (SDG4) ដោយផ្តោតជាអាទិភាព៥ចំណុច៖ ១) ការអប់រំ និងការ គាំពារកុមារតូច និងការអប់រំកម្រិតមូលដ្ឋាន ២) ការអប់រំមធ្យមសិក្សាទុតិយភូមិ ៣) ការអប់រំកម្រិត ឧត្តសិក្សា៤) អក្ខរកម្មយុវជន និងមនុស្សពេញវ័យ និង ៥)អភិបាលកិច្ចនិងការគ្រប់គ្រងវិស័យអប់រំ (ក្រសួង អប់រំ យុវជន និងកីឡា, ២០១៩ក)។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រការគ្រប់គ្រងតាមសាលារៀន ក្នុងគោល បំណង ១) ផ្តល់ស្វ័យភាព និងភាពបត់បែនក្នុងការដឹកនាំ និងគ្រប់គ្រងលើការងារ និងធនធានស្របតាម តម្រូវការរបស់សិស្ស ២) ទទួលបានធនធានច្រើនពីការចូលរួមរបស់ឪពុកម្តាយសិស្ស និងសហគក មន៍ ៣) ពង្រឹងនូវតម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់នូវធនធាននានាសម្រាប់អភិវឌ្ឍសាលា រៀន ៤) បង្កើតនូវយន្តការនៃការធ្វើសេចក្តីសម្រេចចិត្តដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និង ៥) លើកកម្ពស់លទ្ធផលនៃការសិក្សារបស់សិស្ស កាត់បន្ថយអត្រាត្រួតថ្នាក់ និងកាត់បន្ថយអត្រាបោះបង់ការ សិក្សា។

ក្នុងបរិបទនៃការគ្រប់គ្រងតាមសាលារៀនទាមទារការយកចិត្តទុកដាក់លើសមាសធាតុសំខាន់ ៤ នៃ ការគ្រប់គ្រងរួមមាន៖ ១)ការគ្រប់គ្រងរដ្ឋបាល ២)ការគ្រប់គ្រងការរៀននិងបង្រៀន ៣)ការគ្រប់គ្រង បុគ្គលិក និង ៤) ការគ្រប់គ្រងហិរញ្ញវត្ថុ។ ដើម្បីចូលរួមអនុវត្តសម្រេចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលា រៀននេះ ត្រូវជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ពិសេសសហគមន៍ដែលជាម្ចាស់សាលារៀនក្នុងការ រួមចំណែកការអភិវឌ្ឍន៍សាលារៀនប្រកបដោយនិរន្តភាព។

ការគ្រប់គ្រង និងការដឹកនាំ នៅក្នុងអង្គភាពសាលារៀនប្រកបដោយចីរភាព គឺទាមទារឱ្យនាយកសាលា គណៈ កម្មការគ្រប់គ្រងសាលារៀន មានបំណិនក្នុងការកៀរគរធនធានពីគ្រប់មជ្ឈដ្ឋានបង្កើនការចូលរួមនិងជំនឿទុក ចិត្តពីគ្រប់អ្នកពាក់ព័ន្ធ ក្នុងការអនុវត្តសកម្មភាពនៅកម្រិតសាលារៀន ជាពិសេសត្រូវធ្វើស្វ័យវាយតម្លៃ

សាលារៀន ដើម្បីឃើញលទ្ធផលវឌ្ឍនភាព និងបញ្ហាប្រឈមនានា ក្នុងការអនុវត្តសកម្មភាពនោះដែលជាមូលដ្ឋានសម្រាប់ធ្វើការកែលម្អតាមរយៈការរៀបចំផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ។

ម្យ៉ាងវិញទៀតសាលារៀនជាកន្លែងសម្រាប់ផ្តល់សេវាអប់រំ ដល់សិស្សនិងប្រជាជនក្នុងសហគមន៍ប្រកបប្រកប ដោយគុណភាពនិងប្រសិទ្ធភាព។ ការបណ្តុះបណ្តាលសិស្សគឺដើម្បីធានាបាន ការរីកចំរើនទាំងចំណេះដឹង បំណិនប្រសប់ និងការអភិវឌ្ឍបុគ្គលិកលក្ខណៈ។ ចំពោះសហគមន៍វិញសាលារៀនមានមុខងារជាកន្លែងបង្ហាញគម្រូបង្កើតថ្មី ដែលនាំឱ្យការអប់រំសម្រាប់ការអភិវឌ្ឍសង្គម ប្រកបដោយចីរភាព។

ដើម្បីធានាបាននូវគោលការណ៍ខាងលើ លុះត្រាសាលារៀនត្រូវបានអនុវត្ត ការគ្រប់គ្រងតាមសាលារៀន ដែលជាយុទ្ធសាស្ត្រជាក់ស្តែង និងមានប្រសិទ្ធិភាពអំពីវិមជ្ឈការការងារអប់រំ។ ក្នុងន័យនេះ សាលារៀនមានសិទ្ធិក្នុងការធ្វើការងារជាមួយសហគមន៍ និងចលនាសហគមន៍ឱ្យក្លាយជាម្ចាស់សាលារៀន ឬសាលារៀនជារបស់សហគមន៍ និងដើម្បីសហគមន៍។ ធ្វើយ៉ាងនេះរាល់ការប្រឈមទាំងឡាយដែលកើតឡើងប្រចាំថ្ងៃ នៅសាលារៀនត្រូវបានសហគមន៍ចូលរួមដោះស្រាយពេញទំហឹង និងជាបន្ទាន់ ដូចជាសិស្សមិនចូលរៀន សិស្សមិនបន្តរៀន សិស្សមករៀនមិនទៀតទាត់ សិស្សមករៀនយឺត សិស្សអវត្តមាន និងសិស្សរៀនមិនទទួលបានលទ្ធផលល្អ។ល។ ក្រៅពីនោះក៏មានសកម្មភាពអភិវឌ្ឍសាលារៀន មួយចំនួនដែលសហគមន៍មានលទ្ធភាពចូលរួមតាមរយៈកម្លាំងសាមគ្គី។

## ២.២ និយមន័យនៃពាក្យគន្លឹះ

គណនេយ្យភាពសាលារៀន ជា ដំណើរការនៃការវាយតម្លៃការអនុវត្តរបស់សាលាដោយផ្អែកលើមូលដ្ឋាននៃការវាស់វែងលទ្ធផលសិក្សារបស់សិស្ស វាត្រូវបានអនុវត្តជុំវិញពិភពលោក។ នៅសហរដ្ឋអាមេរិក គណនេយ្យភាពបានក្លាយជាចំណុចស្នូលទាំងរបបប្រជាធិបតេយ្យ និងគោលនយោបាយអប់រំរបស់រដ្ឋបាលសហព័ន្ធសាធារណរដ្ឋ តាមចលនានេះ។ដោយរដ្ឋនីមួយៗត្រូវណែនាំឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាពចាប់តាំងពីទសវត្សរ៍ឆ្នាំ 1990 មក។ តាមរបាយការណ៍អំពីពិន្ទុប្រឡងទូទាំងសាលាបានកើតឡើងអស់រយៈពេលជាងពីរទសវត្សរ៍មកនេះ នៅចក្រភពអង់គ្លេស (Burgess et al., ២០០៥) និងនៅប្រទេសឈីលី (Mizala, Romaguera និងUrquiola, 2007)។

គណនេយ្យភាពរបស់សាលារៀន ត្រូវបានគេវាស់ដោយផ្អែកលើមូលដ្ឋាននៃកម្រិតនៃការចូលរួម របស់ សហគមន៍ និងការបំពេញការងាររបស់សាលារៀន។ ការវាស់វែងទាំង២នេះគឺជាធាតុចូលដែលគេ ដាក់បញ្ចូល គ្នាដើម្បីឆ្លុះបញ្ចាំងពីវិសាលភាពដែលសាលារៀនមានគណនេយ្យភាពចំពោះដំណើរការផ្ទាល់ របស់ខ្លួន ចំពោះ ការរៀនសូត្ររបស់សិស្ស និងចំពោះសហគមន៍ជាទូទៅ (Fata & Kreng, ២០១៦)។

ការចូលរួមរបស់សហគមន៍ សំដៅទៅលើកម្រិតនៃការពាក់ព័ន្ធរបស់គណៈកម្មការទ្រទ្រង់សាលា រៀន នៅក្នុងដំណើរប្រតិបត្តិការរបស់សាលារៀនដោយផ្អែកលើសេចក្តីណែនាំរបស់ SSC ដែលបានរៀបចំ ឡើងនៅ ក្នុងឆ្នាំ២០១៣ ដែលមានភារៈកិច្ច និងការទទួលខុសត្រូវចំនួន ៨ចំណុច។ ការចូលរួមរបស់ SSC ត្រូវបានគេវាយ តម្លៃដោយផ្អែកទៅលើការយល់ឃើញរបស់ SSCs សមាជិកមិនមែន SSCs និង នាយកសាលា។

ការបំពេញការងាររបស់សាលារៀន សំដៅទៅលើសកម្មភាពនានានៅក្នុងសាលារៀនដែលតាមរ យៈ សកម្មភាពទាំងនោះសាលារៀនត្រូវមានគណនេយ្យភាពចំពោះសហគមន៍ ដែលផ្ទុយទៅនឹងលទ្ធផល នៃការ សិក្សារបស់សិស្សដែលគេបានវាស់វែង(Fata & Kreng, ២០១៦)។

យើងមើលឯកសារដែលមានស្រាប់ គោលគំនិតនៃគណនេយ្យភាពរបស់សាលារៀនលេចរូបរាង ឡើងជាលើកដំបូងនៅក្នុងទសវត្សឆ្នាំ១៩៦០ (Beneniste, ១៩៨៥)។ គោលបំណង និងអត្ថន័យរបស់ វានៅតែកំពុងត្រូវបានគេស្វែងយល់នៅឡើយនៅក្នុង ការប្រតិបត្តិជាក់ស្តែង និងនៅក្នុងឯកសារដែលមាន ស្រាប់ ហេតុដូច្នេះហើយពុំមានការយល់ដឹងដែលច្បាស់លាស់ តែមួយគត់ពីគោលគំនិតនេះទេ។ ទោះជា យ៉ាងណាក៏ដោយ គោលដៅ និងនិយមន័យនានារបស់គណនេយ្យភាពនៅក្នុងវិស័យអប់រំរាប់បញ្ចូលទាំង ការជឿជាក់ចំពោះសេវាកម្មអប់រំនៅតាមមូលដ្ឋាន ស្វ័យបញ្ញត្តិ ច្បាប់ និងបដិញ្ញាការិយាធិបតេយ្យ គោល ដៅ និងលទ្ធផលនៃការប្រតិបត្តិ គំនិតផ្តួចផ្តើមផ្នែកគោលនយោបាយ និងសេចក្តីណែនាំខាងនយោបាយ ហើយជាចុងក្រោយគឺទីផ្សារសាធារណៈ និង គ្រឿងលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល (Burke, ២០០៥) ។ គំរូជាលក្ខណៈអន្តរជាតិនៃគណនេយ្យភាពសាលារៀនសម្រាប់ការប្រតិបត្តិគណនេយ្យភាពសាលារៀន ត្រូវបានគេអនុវត្តខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ ហើយពួកបញ្ញវន្ត ក៏មានការយល់ឃើញផ្ទុយគ្នា

ដែរទោះបីជាស្ថិតនៅក្នុងបរិបទដូចគ្នាក៏ដោយ។ គោលគំនិតនៃគណនេយ្យភាព មានលក្ខណៈទូលំទូលាយមែនទែន ហើយគេអាចដោះស្រាយវាទៅតាមមធ្យោបាយផ្សេងៗជាច្រើន។ ឧទាហរណ៍ គេអាចដាក់បញ្ចូលការប្រើប្រាស់ដំណើរការផ្នែកនយោបាយ ដើម្បីបញ្ជាក់អះអាងពីគណនេយ្យភាព តាមបែបប្រជាធិបតេយ្យ ការណែនាំពីកំណែទម្រង់ដោយផ្តោតលើទីផ្សារដើម្បីបង្កើនគណនេយ្យភាពចំពោះ ឪពុកម្តាយ និងកុមារ ឬការបង្កើតប្រព័ន្ធគណនេយ្យភាពដោយផ្អែកលើការទទួលខុសត្រូវរួមគ្នា (peer-base) ដើម្បីបង្កើនគណនេយ្យភាពផ្នែកវិជ្ជាជីវៈរបស់គ្រូបង្រៀន (Figlio & Loeb, ២០១១)។ និយមន័យនៃពាក្យ គណនេយ្យភាពដែលគេគិតគូរជាទូទៅបំផុតនោះ គឺទាក់ទងនឹងការប្រើប្រាស់យន្តការដែលមានមូលដ្ឋានលើ ទិន្នន័យរដ្ឋបាល ដែលមានបំណងបង្កើននូវលទ្ធផលសិក្សារបស់សិស្សតាមរយៈការលើកឡើងនូវស្នាដៃបំពេញ ការងាររបស់សាលារៀននីមួយៗ ឬគ្រឹះស្ថានអប់រំនានា។ ជាតួយ៉ាងប្រទេសជាច្រើនប្រើប្រាស់នូវការធ្វើតេស្តស្តង់ដារដែលមានសារៈសំខាន់បំផុត (highstake) ដើម្បីវាស់វែងពីស្នាដៃបំពេញការងាររបស់សាលារៀន និងដើម្បីធានាបាននូវគណនេយ្យភាពចំពោះ សកម្មភាពនានារបស់សាលារៀន (Figlio & Loeb, ២០១១)។ វិធានការនៃការវាស់វែងពីគណនេយ្យភាពរបស់សាលារៀននេះ ត្រូវបានគេណែនាំជាលើកដំបូងនៅសហរដ្ឋអាមេរិកនៅក្នុងទសវត្សឆ្នាំ១៩៩០ ទោះបីវា ត្រូវបានគេអនុវត្តយូរយារណាស់មកហើយក៏ដោយ នៅក្នុងចក្រភពអង់គ្លេសចាប់តាំងពីទសវត្សឆ្នាំ១៩៨០ (Burgess, Propper, Slatter, & Wilson, ២០០៥)។ គំរូមួយនៃការវាស់វែងមួយដូចនេះ ធ្វើឱ្យសាលារៀន ស្ថិតនៅក្នុងស្ថានភាពនៃការទទួលរង្វាន់ និងការដាក់ទណ្ឌកម្ម។ តាមការរៀបរាប់ដោយសាមញ្ញ សាលារៀន ទាំងឡាយណាដែលសិស្សរបស់ខ្លួនប្រតិបត្តិការសិក្សាបានល្អ ដោយទទួលបានលទ្ធផលល្អនៅក្នុងការប្រឡង ថ្នាក់ជាតិបានទទួលរង្វាន់ចំពោះការដំឡើងថវិការួម (budget_share) ការតំឡើងប្រាក់បៀវត្សរ៍សម្រាប់ សមាជិកបុគ្គលិករបស់ខ្លួន និង/ ឬស្វ័យភាពរបស់សាលារៀនច្រើនថែមទៀត ចំណែកឯសាលារៀនដែល សម្រេចលទ្ធផលបានទាបទទួលពិន័យពីរដ្ឋ។ លទ្ធផលនៃការប្រឡងថ្នាក់ជាតិមានបំណងដាក់បញ្ចូលនូវលទ្ធផលនៃការសិក្សារៀនសូត្រសំខាន់ៗ និងស្តង់ដារដែលមានការឆ្លុះបញ្ចាំងជាមួយកម្មវិធីសិក្សាដែលបានកំណត់ដោយរដ្ឋាភិបាល។Reeves (១៩៩៨) អះអាងថា គណនេយ្យភាពរបស់សាលារៀនមិនត្រូវដាក់បញ្ចូល

តែពិន្ទុនៃការធ្វើ តេស្តលទ្ធផលសិក្សាតែមួយមុខទេ ហេតុដូច្នេះហើយពិន្ទុមិនមែនជាការឆ្លុះបញ្ចាំងទាំងស្រុងទៅលើការរៀនសូត្រ របស់សិស្សឡើយ។ Reeves បានសង្កត់ធ្ងន់បន្ថែមទៀតទៅលើតួនាទី និងការទទួលខុសត្រូវរបស់គ្រូបង្រៀន សាលារៀន និងសហគមន៍។ ហេតុដូច្នេះហើយ គាត់បានផ្តល់នូវគោលការណ៍សំខាន់ៗចំនួន៥ ដែលត្រូវបាន គេប្រើប្រាស់ដើម្បីវាស់វែងពីកម្រិតនៃគណនេយ្យភាពរបស់សាលារៀន៖ ភាពស្របគ្នា ភាពជាក់លាក់ ភាពជាប់ទាក់ទង ការគោរពចំពោះភាពខុសប្លែកគ្នា និងការកែលម្អជាបន្តបន្ទាប់ វប្បធម៌និង គុណតម្លៃអង្គភាព។

## ២.៣ គណនេយ្យភាពសាលារៀន

គណនេយ្យភាពសាលារៀនជាផ្នែកសំខាន់ទី៣នៃប្រព័ន្ធ ៣ អាបិទជិត ។ វាមានគណនេយ្យភាពពីដំណើរការ សាលារៀន គណនេយ្យភាពសិក្សា និង គណនេយ្យភាពហិរញ្ញវត្ថុ ។

### ២.៣.១ ប្រភេទគណនេយ្យភាព

**១. គណនេយ្យភាពពីដំណើរការ**

លទ្ធផលបានមកពីការវាយតម្លៃសិស្ស និងសាលារៀន ដូចមានក្នុងរៀបរាប់ ពីការវាយតម្លៃសិស្ស និងសាលារៀន ត្រូវតែយកមកប្រើប្រាស់ ដើម្បីបញ្ជាក់គណនេយ្យភាពពីព្រឹត្តិការណ៍សាលារៀន ។

ភស្តុតាងជាតារាងទិន្ន័យ ចំនួនពីរការបិទផ្សាតជាសាធារណៈនៅដើមឆ្នាំសិក្សា ដែលបញ្ជាក់ពីគណនេយ្យភាពសាលារៀន៖ ១. ផែនការកែលម្អសាលារៀន និងថវិកាប្រចាំឆ្នាំ ២. ចំណូលរបស់សាលារៀនពីគ្រប់ប្រភេទធនធាន ។

**២. គណនេយ្យភាពសិក្សា**

គណនេយ្យភាពសិក្សាមានបីកម្រិត៖ កម្រិត១ មានគ្រូបង្រៀន មាតាបីតា និងសិស្ស កម្រិត២ មានគណៈកម្មការគ្រប់គ្រងសាលា និង មន្ត្រីអប់រំស្រុក និង កម្រិត៣ មានក្រុមការងារគ្រប់គ្រងតាមសាលារៀន និង មន្ត្រីអប់រំរាជធានីខេត្ត។

ភស្តុតាងគណនេយ្យភាពសិក្សាបង្ហាញដោយ តារាងទិន្ន័យ ចំនួនបីការបិទផ្សាតជាសាធារណៈនៅដំណាច់ឆ្នាំសិក្សា៖

កម្រឹត១ តារាងពិន្ទុតេស្តប្រចាំត្រីមាស ប្រចាំឆ្នាំ និងប្រចាំមុខវិជ្ជាគោល (សូចនាករស្តង់ដារ២)

កម្រិត២ តារាងទិន្នន័យនៅដំណាច់ឆ្នាំសិក្សាពីស្តង់ដារទី១ វត្ថុបំណងគោលនយោបាយសាលារៀន និងផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ

កម្រិត៣ តារាងទិន្នន័យកាតរបាយការណ៍ប្រៀនធៀបសូចនាករសំខាន់ៗរបស់សាលារៀន (ប្រចាំឆ្នាំ)។

**៣. គណនេយ្យភាពហិរញ្ញវត្ថុ**

តារាងទិន្នន័យហិរញ្ញវត្ថុមាននៅក្នុងសូចនាករ ៩.២ និង ៩.៣នៃស្តង់ដាទី៩ ថវិកាសាលារៀន និងការគ្រប់គ្រងហិរញ្ញវត្ថុ ដែលត្រូវបិទផ្សាយជាសាធារណៈ នៅចុងឆ្នាំសិក្សានិមួយៗ។

សាលារៀនត្រូវមានគណនេយ្យភាពចំពោះការសិក្សារៀនសូត្ររបស់សិស្សដែលតាមធម្មតាត្រូវបានគេ វាស់វែងទៅតាមពិន្ទុតេស្តស្តង់ដារ។ គណនេយ្យភាពនេះត្រូវបានអ្នកធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយ សន្មតយ៉ាងទូលំទូលាយថា តាមពិតការធ្វើតេស្តពីខាងក្រៅក៏វាស់វែងបានគ្រប់គ្រាន់ដែរពីការរៀនសូត្ររបស់ សិស្ស។ Jones, ២០០៤ អះអាងថា គេត្រូវតែចោទជាសំណួរចំពោះចំណុចទាំងនេះ និងការសន្មតផ្សេងៗ ទៀតអំពីគណនេយ្យភាពរបស់សាលារៀន ប្រសិនបើយើងត្រូវបង្កើតឱ្យមានគំរូគណនេយ្យភាពដែលកាន់តែ ទទួលជោគជ័យច្រើនថែមទៀត។ សាលារៀនក៏ត្រូវមានគណនេយ្យភាពចំពោះសុខុមាលភាពផ្នែករាងកាយ និងអារម្មណ៍របស់សិស្ស ការសិក្សារៀនសូត្ររបស់សិស្ស ការសិក្សារៀនសូត្ររបស់គ្រូបង្រៀន សមធម៌ និងសិទ្ធិ ទទួលបាន ព្រមទាំងការកែលម្អដែរ។ ចំពោះចំណុចនេះ សាលារៀនក៏ត្រូវមានគណនេយ្យភាព ចំពោះភាគីដែល ពាក់ព័ន្ធចម្បងៗរបស់ខ្លួនផងដែរ ៖ សិស្សានុសិស្ស ឪពុកម្តាយ និងសហគមន៍មូលដ្ឋាន។ ហេតុដូច្នេះហើយ ប្រព័ន្ធគណនេយ្យភាពដែលបានកំណត់នៅក្នុងប្រព័ន្ធអប់រំរបស់ជាតិ ត្រូវជួយសាលារៀនឱ្យបំពេញតួនាទីរបស់ ខ្លួនឱ្យបានត្រឹមត្រូវមានលទ្ធភាពកែលម្អការសិក្សារៀនសូត្ររបស់សិស្ស និងការប្រតិបត្តិរបស់សាលារៀន ផ្តល់ នូវសេចក្តីណែនាំ និងព័ត៌មានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តនៅតាមមូលដ្ឋាន ព្រមទាំងផ្តល់នូវតុល្យភាព មួយនៃការទទួលខុសត្រូវ និងអំណាចក្នុងចំណោមស្ថាប័នរដ្ឋាភិបាលក្នុងកម្រិតខុសៗគ្នា (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨ក)។

Beneniste (១៩៨៥) បានណែនាំគោលបំណងសំខាន់នៃគណនេយ្យភាពរបស់សាលារៀននៅក្នុង លក្ខណៈយ៉ាងសាមញ្ញមួយ ពោលគឺដើម្បីត្រួតពិនិត្យ និងវាយតម្លៃថា តើសាលារៀនបានបំពេញការងារបានល្អ កម្រិតណាដើម្បីឱ្យគេអាចផ្តល់រង្វាន់ដល់សាលារៀនដែលមានស្នាដៃបំពេញការងារល្អ ខណៈដែលការដាក់ពិន័យអាចត្រូវបានគេដាក់ទៅលើសាលាដែលអនុវត្តការងារពុំបានល្អ។ គំរូនេះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយចាប់តាំងពីពេលនោះមក។ បើយោងតាម Beneniste គណនេយ្យភាពរបស់សាលារៀន មាន តួនាទីសំខាន់ៗចំនួន៣គឺៈ ដើម្បីជូនដំណឹង ដើម្បីណែនាំសកម្មភាពឡើងវិញ និងដើម្បីកែសម្រួលអ្វីដែលគេបានធ្វើ។ យន្តការគណនេយ្យភាពផ្តល់នូវព័ត៌មានដល់សាធារណៈជនអំពីអ្វីដែលសាលារៀនកំពុងធ្វើ និងបញ្ជូនព័ត៌មាន មកឱ្យសាលារៀនវិញអំពីអ្វីដែលសាធារណជនចង់បាន។ ព័ត៌មាននេះត្រូវបានគេប្រើប្រាស់ដើម្បីជួយសាលា រៀន គ្រូបង្រៀន សិស្ស និងសាធារណៈជនឱ្យយល់ពីគ្នាទៅវិញទៅមកកាន់តែច្បាស់ថែមទៀត។ ដំណាក់កាលទី២ គឺត្រូវស្នើសុំឱ្យគ្រូបង្រៀន ឬសាលារៀនឱ្យកែលម្អភារកិច្ច និងស្នាដៃបំពេញការងារជាក់លាក់មួយចំនួន។ ដំណាក់កាលនេះត្រូវធ្វើឡើងនៅពេលដែលការផ្តល់រង្វាន់ជាវិជ្ជមាន និងការដាក់ពិន័យត្រូវបានគេដាក់បញ្ចូល ប្រសិនបើសាលារៀននៅតែពុំបានអនុវត្តការងារបានល្អបន្ទាប់ពីមានធនធាន ឬជំនួយបន្ថែមទៀត។ Beneniste ព្រមានថា ប្រព័ន្ធគណនេយ្យភាព ពេលខ្លះត្រូវបានគេប្រើប្រាស់ខុសដើម្បីកែតម្រូវការអនុវត្តជាក់ស្តែងដែលគេ មិនចង់បាន ហើយថារដ្ឋាភិបាលមួយចំនួនបានប្រើប្រាស់ប្រព័ន្ធនេះដើម្បីវាស់វែងពីអ្វីដែលខ្លួនសម្រេចបានរួចទៅហើយ។ ចំពោះចំណុចនេះ Beneniste ជឿជាក់ថាប្រព័ន្ធគណនេយ្យភាពអាចជាកាំបិតមុខពីរ។ ជាការគួរឱ្យចាប់អារម្មណ៍ Finn (២០០២) បានប្រៀបធៀបប្រព័ន្ធគណនេយ្យភាព វិស័យអប់រំទៅ នឹង ជីវៈនិងជំនាញឯកទេស។

Ted ជាតួអង្គដែលជឿជាក់លើស្តង់ដារដែលបានកំណត់ និងពិនិត្យផ្ទៀងផ្ទាត់ ដោយប្រៀបធៀបទៅនឹងស្តង់ដារទាំងនេះ ព្រមទាំង Alice ជាតួអង្គដែលជឿជាក់លើអតិថិជនក្នុងការទាមទារ និងជ្រើសរើសអ្វីដែលគេត្រូវការតាមរយៈសេវាកម្មរបស់ទីផ្សារ។ Finn វាយតម្លៃថា ប្រទេសជាច្រើននៅជុំវិញ ពិភពលោកកំពុងតែប្រើប្រាស់ Ted ដែលជាប្រព័ន្ធពីលើចុះក្រោមមួយដែលស្តង់ដារជាតិ និងការធ្វើតេស្តទូទាំង

ប្រទេសត្រូវបានគេប្រើប្រាស់ដើម្បីត្រួតពិនិត្យមើលជាប្រចាំទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស។ គាត់បាន អះអាងថា ក្នុងគោលបំណងធ្វើឱ្យប្រព័ន្ធគណនេយ្យភាពវិស័យអប់រំមានដំណើរការផ្នែកនីមួយៗ ក្នុងចំណោម ផ្នែកទាំង៤នេះ ចាំបាច់ត្រូវមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក។ នៅក្នុងចំណុចនេះស្តង់ដារជាតិដែលត្រូវបានគេបង្កើតឡើងតាមរយៈច្បាប់ ហើយបទបញ្ញាផ្សេងៗត្រូវតែកំណត់សម្រាប់អាជ្ញាធរមូលដ្ឋាននីមួយៗ ដើម្បីឱ្យមានលក្ខណៈច្បាស់លាស់ពីអ្វីដែលគេត្រូវសម្រេចឱ្យបាន។ នៅក្នុងចំណុចនេះ ការប៉ាន់ស្មាន និងការវាយតម្លៃពីលទ្ធផលនៃការអប់រំមិនត្រូវបានគេផ្តោតតែទៅលើពិន្ទុតេស្តនោះទេ ប៉ុន្តែទៅលើជំនាញ និងចំណេះដឹង ដែលទីផ្សារពលកម្មត្រូវការផងដែរ។ អាជ្ញាធរមូលដ្ឋាន និងសាលារៀនចាំបាច់ត្រូវស្វាគមន៍ការពិនិត្យរបស់ សមាជិកសហគមន៍ អ្នកមានវិជ្ជាជីវៈ និងអ្នកឯកទេស ដើម្បីគាំទ្រដល់ដំណើរការកាន់តែប្រសើរឡើងនាពេលអនាគត។

រដ្ឋាភិបាល ឬអាជ្ញាធរអប់រំតាមមូលដ្ឋានមួយចំនួនដាក់បញ្ចូលអនុក្រុមសូចនាករមួយចំនួនដូចជា អត្រាវត្តមានរបស់សិស្ស និង ឬគ្រូបង្រៀន អត្រាបោះបង់ការសិក្សា និងអត្រាគង់វង្សបន្ថែមទៅលើលទ្ធផលនៃការធ្វើតេស្តរបស់សិស្សនៅក្នុងការគណនាពីសន្ទស្សន៍ ដែលគេប្រើប្រាស់សម្រាប់គណនេយ្យភាពរបស់សាលារៀន។ ជាទូទៅ សូចនាករដែលមិនមែនជាការធ្វើតេស្ត ត្រូវបានគេផ្តល់តម្លៃតិចជាងលទ្ធផលនៃការធ្វើតេស្តរបស់សិស្ស នៅក្នុងសន្ទស្សន៍នៃការប្រតិបត្តិទូទៅ។ តម្លៃប្រកបដោយប្រសិទ្ធិភាព តាមធម្មតាមានតម្លៃតិចជាងតម្លៃដែលគេចាត់តាំងជាផ្លូវការសម្រាប់ទិន្នន័យដែលមិនមែនជាការធ្វើតេស្ត ដោយសារតម្លៃដែលមានប្រសិទ្ធិភាពរបស់ផ្នែក មួយនៃសន្ទស្សន៍គណនេយ្យភាពពឹងផ្អែកទៅលើភាពខុសប្លែកគ្នារបស់ផ្នែកផ្សេងៗពីសាលារៀនមួយ ទៅសាលា រៀនមួយ ហើយសូចនាករនានាដូចជាវត្តមានប្រចាំថ្ងៃជាមធ្យម មានភាពប្រែប្រួលតិចជាងនៅគ្រប់សាលាទាំងអស់ជាងលទ្ធផលនៃការធ្វើតេស្ត។ ទោះជាយ៉ាងនេះក្តី ការដាក់បញ្ចូលសូចនាករដែលមិនមែនជាការធ្វើតេស្ត អាចបញ្ជូនសារមួយដែលថាលក្ខណៈផ្សេងៗដូចជា ការឡើងថ្នាក់ទាន់ពេលវេលា អត្រាបញ្ចប់ការសិក្សា និងវត្តមានទាំងគ្រូបង្រៀន និងសិស្សត្រូវបានគេឱ្យតម្លៃ (Linn, ២០០៤)។

## ២.៤ ទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន និងការចូលរួមរបស់សហគមន៍

ការស្រាវជ្រាវបង្ហាញថា ភាពជាដៃគូរវាងសាលារៀន និងសហគមន៍ ដើម្បី ជួយគាំទ្រដល់ការសិក្សារបស់សិស្ស កែលម្អសាលារៀន និងពង្រឹងការចូលរួមឱ្យបានខ្លាំងខ្លារវាងភាគីពាក់ព័ន្ធ។ ភាពជាដៃគូទាំងនេះពង្រីកការអប់រំបែបប្រពៃណី និង បែបទំនើប បេសកកម្មរបស់សាលាដើម្បីរួមបញ្ចូលសេវាសុខភាព និងសង្គមសម្រាប់កុមារ និងគ្រួសាររបស់ពួកគេ ព្រមទាំងដើម្បីកៀរគរការចូលរួមពីសហគមន៍យ៉ាងទូលំទូលាយ។ ភាពជាដៃគូសាលារៀន-សហគមន៍ជាធម្មតាកើតចេញពីតម្រូវការជាក់លាក់មួយនៅក្នុងសហគមន៍ ហើយដូច្នេះ មានភាពខុសប្លែកគ្នានូវរាល់ដំណើរការ រចនាសម្ព័ន គោលបំណង និងប្រភេទនៃគ្រួសារពាក់ព័ន្ធនឹងការទាក់ទងគ្នា។ នៅក្នុងការងារពីមុន យើងបានបង្កើត typology ដើម្បីពិនិត្យមើលកាន់តែជិតដល់ភាពជាដៃគូរបស់សាលាសហគមន៍ផ្សេងៗ (Valli, Stefanski, & Jacobson, 2013)។

យើងមកគិតពីគុណភាព ទោះបីជាវាហួសសម័យបន្តិចទៅហើយក៏ដោយ ក៏គំរូដែលអាចដំណើរការបានចំពោះការកំណត់និយមន័យគុណភាពនៃការអប់រំ គឺជាគំរូនៃដំណើរការនៃការផលិត (production-function model)។ ទ្រឹស្តីនេះពិនិត្យមើលគុណភាពអប់រំដែលទាក់ទងនឹងធាតុចូល និងដំណើរការ។ របាយការណ៍លំអិតរបស់ (Coleman et al, ១៩៦៦) បានរកឃើញថាធាតុចូលរបស់សាលារៀនមានឥទ្ធិពល (ផលជះ) យ៉ាងខ្លាំងទៅលើការសិក្សារៀនសូត្ររបស់សិស្ស។ ការរកឃើញនេះបានអំពាវនាវឱ្យមានការ វិនិយោគថែមទៀតទៅ លើធាតុចូលពីសំណាក់រដ្ឋាភិបាលនីមួយៗនៅជុំវិញពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាច្រើន ថែមទៀតក្នុងពេលថ្មីៗនេះពីសំណាក់បញ្ញវ័ន្តជាច្រើននាក់ផ្សេងទៀត (ឧទាហរណ៍ Huneshek, ២០១០) លើកឡើងថា ដំណើរការនៃការបង្រៀន និងការរៀននៅតាមគ្រឹះស្ថានអប់រំនានា ជារឿយៗត្រូវបានគេបានគេ សំដៅថាជា "ប្រអប់ខ្មៅ" ដែលគេដាក់នៅចន្លោះកណ្តាលរវាងធាតុចូល និងលទ្ធផល ដើរតួនាទីចំបងមួយនៅ ក្នុងការលើកកម្ពស់គុណភាពនៃការសិក្សារៀនសូត្ររបស់សិស្ស។ ដំណើរការទាំងនេះរាប់បញ្ចូលទាំងដំណើរការទាំងឡាយណាដែលផ្តល់នូវគណនេយ្យភាពរបស់គ្រូបង្រៀន និងសាលារៀនចំពោះការបំពេញភារកិច្ចរបស់ខ្លួន ដើម្បីធានាថាសិស្សបានរៀននូវអ្វីដែលគេរំពឹងទុកថាពួកគេនឹងរៀន។ ដោយសារចំណុចនេះ ពាក្យ គណនេយ្យភាព

បានក្លាយទៅជាទិដ្ឋភាពនៃវិធីសាស្ត្រនានា ដែលគេពិភាក្សាគ្នាជាញឹកញាប់ ចំពោះការធានាបាននូវ គុណភាពអប់រំក្នុងរយៈពេលពីរបីទសវត្សចុងក្រោយនេះ។ ទោះបីជានៅមានការពិភាក្សាដេញដោលច្រើនទៅលើការគាំទ្រនិងការប្រឆាំងចំពោះវាក៏ដោយក៏គោលគំនិតនៃគណនេយ្យភាពរបស់សាលារៀន បានចាប់ផ្តើមជាលើកដំបូងនៅក្នុងការសិក្សាស្រាវជ្រាវពីការ អប់រំ និងការពិភាក្សាដេញដោលពីគោលនយោបាយទំនងជាកើតមានឡើងនៅក្នុងទសវត្សឆ្នាំ១៩៦០ (Beneniste, ១៩៨៥)។ ចាប់តាំងពីពេលនោះមក អន្តរាគមន៍នានាដែលមានគោលបំណងលើកកម្ពស់ គណនេយ្យភាពរបស់សាលារៀនបានក្លាយទៅជាផ្នែកមួយនៃការឆ្លើយតបផ្នែកគោលនយោបាយ ដើម្បីនាំមក នូវគុណភាពរបស់សាលារៀន និងពេលខ្លះឆ្លើយតបទៅនឹងតម្រូវការជាសាធារណៈសម្រាប់សេវាកម្មអប់រំដែល។

គំរូដែលមានឥទ្ធិពល និងល្បីល្បាញមួយផ្សេងទៀតទាក់ទងនឹងប្រព័ន្ធគណនេយ្យភាពក្នុងវិស័យអប់រំ ត្រូវបាន Levin (១៩៧៤) ណែនាំ។ Levin បានរៀបចំក្របខ័ណ្ឌទ្រឹស្តីដ៏រឹងមាំមួយនៃគណនេយ្យភាពរបស់ សាលារៀនថាជាដំណើរការមួយនៃការរាយការណ៍ពីការប្រតិបត្តិ ជាដំណើរការផ្នែកបច្ចេកទេស ជាដំណើរការ ផ្នែកនយោបាយ និងជាដំណើរការផ្នែកស្ថាប័ន។ ការរាយការណ៍ពីស្នាដៃបំពេញការងាររបស់សាលារៀន ជា ទូទៅគឺមានមូលដ្ឋានលើការប្រឡង និងលទ្ធផលសំខាន់ៗផ្សេងទៀតរបស់សិស្សសម្រាប់ភាគីពាក់ព័ន្ធ ផ្នែកអប់រំ ដើម្បីឱ្យគេអាចវាយតម្លៃស្នាដៃបំពេញការងាររបស់សាលារៀនបាន។

ដំណើរការផ្នែកបច្ចេកទេសគឺជាគោលដៅសម្រាប់សម្រេចបានប្រព័ន្ធនៃការចុះឈ្មោះចូលរៀន ។ ការ ចុះឈ្មោះចូលរៀនមានគោលដៅច្បាស់លាស់ផ្សេងៗរបស់វា ហើយដំណើរការផ្នែកបច្ចេកទេសធ្វើឱ្យទទួល

ជោគជ័យនៃការសម្រេចបានគោលដៅនានាទោះបីជាមានឧបសគ្គផ្នែកហិរញ្ញវត្ថុ ធនធានមនុស្ស និងកត្តាផ្សេងៗទៀតក៏ដោយ។ ក្នុងការធ្វើដូច្នេះ ជាទូទៅគំរូនៃការធានាគុណភាពត្រូវបានគេប្រើប្រាស់ដើម្បីកែលម្អប្រសិទ្ធិផល និងប្រសិទ្ធិភាពរបស់សាលារៀនថាជាប្រព័ន្ធនៃការប្រតិបត្តិមួយ ។ ដំណើរការផ្នែកនយោបាយព្យាយាមឆ្លើយនឹងសំណួរថាតើសាលារៀនត្រូវមានគណនេយ្យភាពចំពោះអ្នកណា បើទោះបីជាគោលដៅ

រួម នានានៃការអប់រំ និងរបស់សាលារៀនត្រូវបានគេកំណត់ជាក់លាក់រួចហើយក៏ដោយ។ តាមធម្មតា សាលារៀន

ឈរជាតំណាងឱ្យតម្រូវការនានារបស់ភាគីដែលពាក់ព័ន្ធខុសៗគ្នាដែលពួកគេម្នាក់ៗ មានគោលដៅនៃការអប់រំខុសៗគ្នា។ ដំណើរការផ្នែកនយោបាយស្វែងរកការធ្វើឱ្យក្រុមមួយពេញចិត្តជាងក្រុមមួយផ្សេងទៀត។ នៅក្នុងគោលគំនិតនៃគណនេយ្យភាពដែលជាដំណើរការមួយផ្នែកស្ថាប័ន ភាពស្របច្បាប់នៃដំណើរការនៃការអប់រំ ដែលជួយនាំទៅរកសង្គមមួយដែលកាន់តែល្អប្រសើរ គេចាំបាច់ត្រូវតែកំណត់ និងផ្ដល់ឱ្យ។ ដោយប្រើប្រាស់គំរូរបស់ (Levin Ng ២០១០) មានលទ្ធភាពកំណត់ពីការវាយតម្លៃប្រព័ន្ធគណនេយ្យភាពរបស់សាលារៀននៅក្នុងប្រទេសសឹង្ហបូរី។ គាត់បានរកឃើញថា ប្រទេសសឹង្ហបូរីប្រើប្រាស់ដំណើរការនៃការធ្វើរបាយការណ៍ និងបច្ចេកទេសក្នុងអំឡុងពេលនៃ "ដំណាក់កាលនៃការកំណត់ស្តង់ដារ" (នៅពាក់កណ្ដាលទសវត្សឆ្នាំ១៩៦០ ដល់ពាក់កណ្ដាលទសវត្សឆ្នាំ១៩៨០) ដំណើរការផ្នែកនយោបាយនៅក្នុងអំឡុងនៃ "ដំណាក់កាលនៃគណនេយ្យភាពតាមមូលដ្ឋាន" (ពាក់កណ្ដាលទសវត្សឆ្នាំ១៩៨០ ដល់ពាក់កណ្ដាលទសវត្សឆ្នាំ១៩៩០) និងដំណើរការ ផ្នែកស្ថាប័ននៅក្នុងអំឡុងពេលនៃ "ដំណាក់កាលនៃការផ្ដល់ និងការថ្លៃប្រឌិត" (ពាក់កណ្ដាលទសវត្សរ៍ឆ្នាំ ១៩៩០ រហូតដល់បច្ចុប្បន្ន)។ ទោះបីជាគំរូខុសៗគ្នាត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីពន្យល់ និងវាស់វែងពីកម្រិតនៃគណ នេយ្យភាពរបស់សាលារៀនក៏ដោយ ក៏ការឯកភាពរួមគ្នាលើការពន្យល់នានានិងការវាស់វែងពីស្នាដៃបំពេញ ការងារដែលសមស្របនៅមិនទាន់មាននៅឡើយ។ ទោះជាយ៉ាងនេះក្ដី នៅក្នុងការពិនិត្យមើលឡើងវិញនូវ ឯកសារដែលមានស្រាប់យ៉ាងទូលំទូលាយស្ដីពីស្នាដៃបំពេញការងារ និងគំរូគណនេយ្យភាព យើងអាចមើល ឃើញពីភាពដូចគ្នា (commonalities) ជាច្រើន។ មានការយល់ឃើញរួមគ្នាមួយថា សាលារៀនចាំបាច់ត្រូវ បំពេញការងារនៅក្នុងមធ្យោបាយមួយ ដើម្បីធានាបាននូវការអនុម័តយល់ព្រមពីសំណាក់សាធារណជន ដើម្បី សម្រេចបាននូវលទ្ធផលដែលមានតម្លៃខ្ពស់ (high value-outcome) ទោះបីថវិកា ដែលគេផ្ដល់ឱ្យមានចំនួន តិចតួចក៏ដោយ។ ទោះជាយ៉ាងនេះក្ដី វាទប្បដិវាទកើតចេញពីការកំណត់លទ្ធផលដែលគេចង់បានចំពោះការចុះឈ្មោះចូលរៀន។

## ២.៥ កម្រិតនៃទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀននិងការចូលរួមរបស់សហគមន៍

ទីបអាស៊ី វិធីសាស្រ្តទូទៅមួយចំពោះគណនេយ្យភាពរបស់សាលារៀនគឺការអនុវត្តនូវការចង សាលា រៀនជាកម្រង និងការចូលរួមរបស់សហគមន៍ក្នុងអភិបាលកិច្ចសាលារៀន បើទោះបីជាឈ្មោះដែល គេប្រើ និង ការអនុវត្តជាក់ស្តែងអាចមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយក៏ដោយ (Wheeler et al., ១៩៩៨, ដូចដែលបានដកស្រង់នៅក្នុង Pellini, ២០០៧)។ នៅក្នុងប្រទេសថៃ កម្រង សាលារៀនដើរតួនាទីជា យន្តការមួយក្នុងការលើកកម្ពស់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ និង ធ្វើឱ្យសាលារៀនមានគណនេយ្យភាពចំពោះអភិបាលកិច្ចសាលារៀន។ ឥណ្ឌាបានណែនាំឱ្យបង្កើត សមាគមមាតាបិតាសិស្ស និងគ្រូបង្រៀន (PTA) ដើម្បីធ្វើការឱ្យបានស្និតរមួតជាមួយគណៈគ្រប់គ្រងសា លា។ ហ្វីលីពីនបង្កើតប្រព័ន្ធគាំទ្រការសិក្សារៀន សូត្ររបស់ឪពុកម្តាយ (PLSS)។ ឥណ្ឌូនេស៊ីបង្កើតអង្គ ការមាតាបិតាសិស្ស (PO)។ ទោះជាយ៉ាងនេះក៏ដោយ ប្រទេសទាំងនេះមានបញ្ហាស្រដៀងគ្នា ដែលបញ្ហា ភាគច្រើនបំផុតដែលគេកត់សំគាល់គឺការខ្វះការចូលរួមរបស់ សហគមន៍នៅក្នុងដំណើរការនៃការធ្វើសេច ក្តីសម្រេចចិត្ត។ ការវាយតម្លៃជាលក្ខណៈទ្រឹស្តីបានលើកឡើងថា អំណាចនៃការធ្វើសេចក្តីសម្រេចចិត្តនៅ តែស្ថិតក្នុងដៃរបស់នាយកសាលាដដែល។

គំរូរបស់ប្រទេសឥណ្ឌូនេស៊ី ត្រូវបានគេវិនិច្ឆ័យថាពុំបានទទួលជោគជ័យទេដោយសារគ្រូបង្រៀន មិនត្រូវបានគេដាក់បញ្ចូលទៅក្នុងយន្តការ នានាដែលគេបង្កើតឡើងដោយពឹងផ្អែកខ្លាំងពេកតែទៅលើ សមាជិកសហគមន៍។ គំរូកម្រងសាលារៀនរបស់ ប្រទេសនេប៉ាល់ក៏មិនត្រូវបានគេមើលឃើញថាមាន ដំណើរការល្អដែរ ដោយសារគំរូនៃការគ្រប់គ្រងសាលារៀន នៅតែត្រូវបានគេរៀបចំរចនាសម្ព័ន្ធ ដែលមាន លក្ខណៈតាមឋានានុក្រមដដែល។ សាលារៀននានាខកខានក្នុង ការឱ្យសហគមន៍ចូលរួមនៅក្នុងដំណើរ ការនៃការធ្វើសេចក្តីសម្រេចចិត្តដែលជាហេតុបង្កឱ្យមានការបង្កើតឡើង នូវការចូលរួមក្លែងក្លាយ របស់ សហគមន៍នៅក្នុងអភិបាលកិច្ចសាលារៀន។

នៅក្នុងប្រទេសកម្ពុជាកម្មវិធី កម្រងសាលារៀនត្រូវបានគេណែនាំនៅឆ្នាំ១៩៩២ ដោយមានគោលបំណងមួយក្នុងការលើកកម្ពស់ការចូលរួមរបស់សហគមន៍ ដើម្បីជួយសាលារៀនឱ្យបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយគណនេយ្យភាព (Pellini, ២០០៧)។ បន្ទាប់ពីនោះមក គណៈកម្មការទ្រទ្រង់សាលារៀន (SSCs) ត្រូវបានគេបង្កើតឡើងជាកម្លាំងអន្តរការីមួយដើម្បីភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។ យន្តការទាំងពីរនេះមានបំណងផ្តល់នូវវេទិការនៃការគាំទ្រមួយសម្រាប់សហគមន៍នៅក្នុងការជួយសាលារៀនឱ្យបំពេញភារកិច្ចរបស់ខ្លួនទាំងប្រកបដោយប្រសិទ្ធិភាព និងគណនេយ្យភាព។ ប៉ុន្តែភស្តុតាងបង្ហាញថា យន្តការទាំងនេះមិនត្រូវបានគេកំណត់ថាទទួលជោគជ័យទេដោយសារការខ្វះខាតនូវធនធានមនុស្ស និងហិរញ្ញវត្ថុ (ឧទាហារណ៍ Shoraku, ២០០៨; Thida & Joy, ២០១២)។ ដើម្បីធ្វើឱ្យសាលារៀនមានគណនេយ្យភាព តាមរយៈការចូលរួមរបស់សហគមន៍ គឺជាការប្រឈមមុខដ៏ខ្លាំងក្លាមួយ។ ទោះជាយ៉ាងណាក៏ដោយ Shoraku (២០០៨) ផ្តល់អនុសាសន៍មួយទាក់ទងនឹងវិធីសាស្ត្ររួមចំពោះចំណុចនេះ៖ ១) បណ្តុះបណ្តាលគ្រូបង្រៀន និងនាយកសាលានូវបច្ចេកទេសនៃភាពជាអ្នកដឹកនាំជាមូលដ្ឋាន និងជំនាញក្នុងការចងក្រងសហគមន៍ (ឧទាហរណ៍ ការប្រើប្រាស់ថវិកាសាលារៀន ការផ្តល់ហិរញ្ញវត្ថុ និងការចងក្រងសហគមន៍) ២) បណ្តុះ បណ្តាលបុគ្គលិករដ្ឋាភិបាលថ្នាក់មូលដ្ឋានស្តីពីការត្រួតពិនិត្យ ការគ្រប់គ្រង និងការវាយតម្លៃប្រតិបត្តិការរបស់ សាលារៀន នៅក្នុងករណីនេះគឺសំដៅទៅលើក្រុមការងារបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ទី៣) បង្កើតនូវអង្គការស្វ័យភាពដែលមានមូលដ្ឋាននៅតាមសាលារៀនដាច់ដោយឡែកសម្រាប់ក្រុមដែលមានការ ចាប់អារម្មណ៍ផ្ទាល់ខ្លួន និងប្រជាជនធម្មតាផ្សេងៗទៀត (ឧទាហរណ៍ អង្គការឪពុកម្តាយ និងអង្គការដែលមាន មូលដ្ឋាននៅសាលារៀន) ដើម្បីឱ្យមានលំហរដែលមានលក្ខណៈសង្គតភាពសម្រាប់ការពិភាក្សាដោយបើកចំហរ អំពីការអប់រំកូនៗរបស់ពួកគាត់។ Thida និង Joy (២០១២) បានសង្កត់ធ្ងន់ទៅលើលក្ខខ័ណ្ឌដំបូងចំពោះ ឯកសារមួយដែលបោះពុម្ពនៅមុនសន្និសិទ្ធិ អាស៊ីស្តីពីការអប់រំឆ្នាំ២០១២ Osaka, Japan ជោគជ័យនៃការគ្រប់គ្រងដោយផ្អែកលើសាលារៀននៅក្នុងប្រទេសកម្ពុជាដែលរាប់បញ្ចូលទាំងការរៀបចំភាពជា អ្នកដឹកនាំ និងការគ្រប់គ្រងសម្រាប់បុគ្គលិករបស់សាលារៀន ជាពិសេសនាយកសាលា ព្រមទាំងវិធីសាស្ត្រនៃការធ្វើសេចក្តីសម្រេច

ចិត្តតាមបែបចូលរួមឱ្យបានច្រើនថែមទៀត នៅក្នុងការគ្រប់គ្រងសាលារៀន ជាពិសេសពី សំណាក់គ្រូបង្រៀន និង SSCs។

នៅទ្វីបអាហ្វ្រិកមានគំរូស្រដៀងគ្នាដែរចំពោះគណនេយ្យភាពរបស់សាលារៀន តាមរយៈការចូលរួមរបស់ សហគមន៍នៅក្នុងអភិបាលកិច្ចសាលារៀន។ ឧទាហរណ៍ Benin បានព្យាយាមសាកល្បងគំរូមួយដែលផ្ទេរការ ធ្វើសេចក្តីសម្រេចចិត្តពីថ្នាក់កណ្តាលទៅថ្នាក់មូលដ្ឋាន។ សាលារៀនមានសិទ្ធិគ្រប់គ្រងមូលនិធិនានា ដែល ទទួលបានពីរដ្ឋាភិបាលកណ្តាល និងប្រើប្រាស់មូលនិធិទាំងនោះសម្រាប់គោលបំណងក្នុងការអប់រំ (ឧទាហរណ៍ ជួលគ្រូបង្រៀននៅតាមសហគមន៍)។ ជាងនេះទៅទៀត PTAS ត្រូវបានគេណែនាំដើម្បីឱ្យសហគមន៍ចូលរួម ក្នុងប្រព័ន្ធនេះ។ ទោះជាយ៉ាងនេះក៏ដោយ លទ្ធផលដែលគេទទួលបានតាមរយៈការខិតខំប្រឹងប្រែងនេះមាន លក្ខណៈចំរុះគ្នា។ គេបានរកឃើញថា ការចូលរួមរបស់សហគមន៍មានទាំងលក្ខណៈពិតប្រាកដ និងសិប្បនិម្មិត ដោយសារតែមានអ្នកដឹងនាំតាមមូលដ្ឋានតែពីរបីនាក់ប៉ុណ្ណោះដែលធ្វើសេចក្តីសម្រេចចិត្តចុងក្រោយ។ នៅក្នុងប្រទេស Malawi ការចូលរួមរបស់សហគមន៍ត្រូវបានគាំទ្រដោយគំនិតផ្តួចផ្តើមនៃការផ្តល់អំណាចដល់សហគមន៍ដែលតាមរយៈនោះសហគមន៍មានភាពជាម្ចាស់ចំនួន២០% នៃធនធានផ្សេងៗ នៅក្នុងគម្រោងដែលផ្តល់ មូលនិធិដោយរដ្ឋាភិបាល។ យន្តការនេះបានទទួលជោគជ័យមួយចំនួនដែរ ប៉ុន្តែជោគជ័យនេះគឺទទួលបានជាក់ លាក់តែចំពោះការសាងសង់សាលារៀនប៉ុណ្ណោះ (Rose, ២០០៣, ដូចដែលបានដកស្រង់នៅក្នុង Pellini, ២០០៧)។ ការធ្វើសេចក្តីសម្រេចិត្ត និងការរៀបចំផែនការនៅតែស្ថិតនៅក្រោមការណែនាំរបស់អ្នកដឹកនាំតាម មូលដ្ឋាន មន្ត្រីថ្នាក់កណ្តាល ឬអ្នកតាក់តែងគោលនយោបាយ។

ចំណែកប្រទេសហ្គាណា គណនេយ្យភាពរបស់ សាលារៀនក៏ត្រូវបានគេផ្សព្វផ្សាយតាមរយៈដំណើរការវិមជ្ឈការ និងការចូលរួមរបស់សហគមន៍ដែរ។ ទំនាក់ ទំនងសាលារៀន និងសហគមន៍ត្រូវបានគេបង្កើតឡើង ប៉ុន្តែគេបានអះអាងថាវាមិនទទួលបានជោគជ័យ ដូចដែលគេរំពឹងទុកទេ។ ក្រៅពីការខ្វះការចាប់អារម្មណ៍ពីសហគមន៍ដោយសារភាពក្រីក្រ សហគមន៍មាន បទពិសោធន៍តិចតួចនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តតាមបែបវិមជ្ឈការនេះ បើតាមអ្វីដែលគេ បានរាយការណ៍។ ដើម្បីលើក

កម្ពស់ការចូលរួមរបស់សហគមន៍ (Chapman et al. ២០០២) ចង្អុលបង្ហាញ ថាសហគមន៍ត្រូវការការបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់ ស្តីពីរបៀបចូលរួមឱ្យមានប្រសិទ្ធិភាពនៅក្នុងដំណើរ ការនៃការធ្វើសេចក្តីសម្រេចចិត្ត (ដូចដែលបានដកស្រង់នៅក្នុង Pellini, ២០០៧)។ នៅក្នុងចំណុចនេះ គេ ចាំបាច់ត្រូវកសាងសមត្ថភាពរបស់សហគមន៍ ដើម្បីចូលរួមនៅក្នុងដំណើរការអភិបាលកិច្ចរបស់សាលារៀន ដើម្បីធ្វើឱ្យយន្តការជាផ្លូវការនេះបានទទួលជោគជ័យ។

សំណាកការវាយតម្លៃគណនេយ្យភាពជួយសហគមន៍ គឺភាគីពាក់ព័ន្ធសង្កេតមើលការអនុវត្តរបស់សាលារៀន។ ឧទាហរណ៍ ការវាយតម្លៃគណនេយ្យភាពរបស់សាលា អាចប៉ះពាល់ដល់ទីផ្សារលំនៅដ្ឋាននៅក្នុងសហគមន៍មួយ (Figlio and Lucas, 2004) និងអាចមានឥទ្ធិពលលើការបរិច្ចាគឯកជនដល់សាលារៀន (Figlio and Kenny, 2009)។ Figlio and Ladd (2007), នៅក្នុងការស្ទង់មតិពីមុននៃអក្សរសិល្ប៍គណនេយ្យភាពរបស់សាលា ដាក់ចេញនូវបញ្ហាជាច្រើន។ ទាក់ទងនឹងការទទួលខុសត្រូវរបស់សាលា ជំពូកបច្ចុប្បន្នសង្ខេបអំពីគោលគំនិតទាំងនេះហើយ បង្ហាញភស្តុតាងលម្អិតបន្ថែមទៀតអំពីផលប៉ះពាល់នៃគោលនយោបាយគណនេយ្យភាពរបស់សាលា និង កម្មវិធីគណនេយ្យភាពសាលារៀនសាលាមិនមែនជាកម្រិតតែមួយគត់ដែលការទទួលខុសត្រូវអាចត្រូវបានកំណត់គោលដៅនោះទេ។ គោលនយោបាយមួយចំនួន អ្នកបង្កើតគាំទ្រទំនួលខុសត្រូវសម្រាប់គ្រូបង្រៀនបុគ្គល តាមរយៈឧទាហរណ៍ គុណសម្បត្តិ ឬប្រាក់បៀវត្សរ៍ផ្អែកលើទម្រង់ ដូចដែលបានតស៊ូមតិដោយប្រធានាធិបតីអូបាម៉ា និងអ្នកដទៃ ជាជាងសម្រាប់ សាលារៀន; និងអ្នកស្រាវជ្រាវមួយចំនួនបានរកឃើញភស្តុតាងដែលបង្ហាញថាការលើកទឹកចិត្តក្នុងការអនុវត្ត សម្រាប់គ្រូបង្រៀនអាចមានប្រយោជន៍សម្រាប់លទ្ធផលសិស្ស (ឧទាហរណ៍ Lavy, 2007; Figlio និង Kenny,២០០៧)។ អ្នកផ្សេងទៀតចាត់ទុកទំនួលខុសត្រូវនៅកម្រិតសាលាជាអាទិភាពទាំងពីរ ព្រោះវាជំរុញឱ្យមានកិច្ចសហការរវាងគ្រូ និងដោយសារសាលាមានឱកាសច្រើនជាង ធ្វើគ្រូបង្រៀនម្នាក់ៗ ដើម្បីអនុវត្តប្រភេទនៃការផ្លាស់ប្តូរក្នុងការបែងចែកធនធាន និងការអនុវត្តនោះ។ប្រហែលជាត្រូវការដើម្បីលើកកំពស់សមិទ្ធផលរបស់សិស្ស (Ladd, 2001)។ ប្រព័ន្ធគណនេយ្យភាពរបស់សាលាមានអត្ថប្រយោជន៍ដ៏មានសក្តានុពលនៃការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងជាមួយគោលដៅរបស់អ្នក

ពាក់ព័ន្ធ និងការផ្តល់ព័ត៌មានសម្រាប់ការកែលម្អ។ ទោះយ៉ាងណាក៏ដោយពួកគេត្រូវបានកំណត់ការពិតដែលថាពួកគេអាចវាស់វែងបានតែចំនួនតូចមួយនៃវិមាត្រដែលភាគីពាក់ព័ន្ធតម្លៃ។ Rothstein, Jacobson, and Wilder (2008) បង្ហាញថាអ្នកពាក់ព័ន្ធផ្នែកអប់រំផ្តល់តម្លៃដល់លទ្ធផលជាច្រើន រួមទាំងការអនុវត្តន៍ការសិក្សា និងការអប់រំផងដែរ។ការសម្រេចបាន ប៉ុន្តែក៏មានផ្នែកផងដែរ ដូចជា ភាពជាពលរដ្ឋក្រមសីលធម៌ការងារ និងការគិតរិះគន់។ ប៉ុន្តែសាលា ប្រព័ន្ធគណនេយ្យភាពជាទូទៅមិនគ្របដណ្តប់សូម្បីតែសំណុំពេញលេញនៃការសិក្សាដែលមានតម្លៃចេញមក ផ្ទុយទៅវិញជារឿយៗផ្តោតលើតែការអាន និងការអនុវត្តគណិតវិទ្យា និង វិធានការដែលមិនល្អបំផុតដូចជាអត្រាបញ្ចប់ការសិក្សាឬអត្រាចូលរួមក៏ជាអាកប្បកិរិយានិងការសម្រេចបាននូវលទ្ធផលដែលអ្នកពាក់ព័ន្ធមានតម្លៃ។ ដោយផ្តោតលើការយកចិត្តទុកដាក់ សំណុំនៃលទ្ធផលដែលអាចវាស់វែងបានយ៉ាងងាយស្រួល ប្រព័ន្ធគណនេយ្យភាពរបស់សាលាអាចនឹងដឹកនាំ លទ្ធផលដ៏មានតម្លៃមួយចំនួនដែលត្រូវចាត់ទុកថាសំខាន់ជាងលទ្ធផលដ៏មានតម្លៃផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ ដែនកំណត់នៃលទ្ធផលវាស់វែង គណនេយ្យភាពរបស់សាលាអាចទទួលបានជោគជ័យក្នុងការសម្រេចបាននូវគោលបំណងរបស់ខ្លួន ប្រសិនបើអ្នកពាក់ព័ន្ធ ផ្តល់តម្លៃលើព័ត៌មានដែលបានបង្កប់នៅក្នុងប្រព័ន្ធគណនេយ្យភាព។ ។

Figlio and Lucas (2004) បង្ហាញថា ថ្នាក់គណនេយ្យភាពរបស់សាលាមានផលវិបាកយ៉ាងសំខាន់សម្រាប់ការវាយតម្លៃអចលនទ្រព្យ (សូម្បីតែការរក្សាការជានាប្រសិទ្ធភាពផ្សេងទៀតរបស់សាលាមិនថេរ) ដែលបង្ហាញថាលក្ខណៈនៃការបង្ហាញនៃព័ត៌មានគណនេយ្យភាពរបស់សាលាគឺពិតជាមានផលវិបាក មិនត្រឹមតែសម្រាប់ឪពុកម្តាយប៉ុណ្ណោះទេសិស្សានុសិស្ស ប៉ុន្តែសម្រាប់សមាជិកសាធារណៈទូទៅផងដែរ ទាក់ទងនឹងតម្លៃទ្រព្យសម្បត្តិរបស់ពួកគេ។ នៅក្នុងការងារថ្មីៗនេះ Figlio and Kenny (2009) ផ្តល់ភស្តុតាងថ្មីដែលបង្ហាញថា វិធានការគណនេយ្យភាពរបស់សាលាមានឥទ្ធិពលលើការរួមចំណែកដោយស្ម័គ្រចិត្តដល់សាលារដ្ឋ។ ជាពិសេស ពួកគេរកឃើញថា សាលារៀនដែលមានព័ត៌មានគណនេយ្យភាពអវិជ្ជមាន "ភាពតក់ស្លុត" បាត់បង់ការគាំទ្រផ្នែកហិរញ្ញវត្ថុពីឪពុកម្តាយ និងសមាជិកសហគមន៍ ខណៈពេលដែលរឿងនោះ។ទទួលបានការទទួលខុសត្រូវជាវិជ្ជមាននៃការទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ទាំងនេះការឆ្លើយ

តបគឺខ្លាំងជាពិសេសសម្រាប់សាលារៀនដែលបម្រើសិស្សជនជាតិភាគតិច និងគ្រួសារដែលមានប្រាក់ចំណូលទាប ដែលអាចមានកម្រិតនៃការត្រួតពិនិត្យសាលារៀនទាបជាងកន្លែងផ្សេងទៀត។ គ្រួសារ និងស្របជាមួយនឹងការរកឃើញពីចិត្តវិទ្យា ការរួមចំណែកសប្បុរសធម៌ និងអក្សរសិល្ប៍ទីផ្សារ ដែលភាគីពាក់ព័ន្ធមានទំនោរចង់ជៀសវាង "ការបោះចោលរបស់ល្អ លុយបន្ទាប់ពីអាក្រក់។ សរុបមក ទម្ងន់នៃភ័ស្តុតាងដែលមានបង្ហាញថា ភាគីពាក់ព័ន្ធនៃធ្វូតជាច្រើនយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីលទ្ធផលនៃការទទួលខុសត្រូវរបស់សាលា។ ប្រព័ន្ធហើយនេះបង្ហាញ ថាអ្នកអប់រំទំនង ជាចង់ឆ្លើយតបផងដែរ ។

## ២.៦ កត្តាប្រសិទ្ធភាពនៃគណនេយ្យភាពសាលារៀន

គំរូនៃការគ្រប់គ្រងដោយផ្អែកលើសាលារៀនត្រូវបានអនុវត្តនៅក្នុងប្រទេសអភិវឌ្ឍជាច្រើន ដូចជាប្រទេស អង់គ្លេស ញូវហ្សឺឡែន ឬ Victoria អូស្ត្រាលី កាណាដា និងសហរដ្ឋអាមេរិកសម្រាប់រយៈពេលពីរបីទសវត្ស កន្លងមកនេះ។ ជាសំខាន់ ការគ្រប់គ្រងដោយផ្អែកលើសាលារៀនពាក់ព័ន្ធនឹងប្រភេទមួយចំនួននៃការផ្ទេរ ការទទួលខុសត្រូវ និងការធ្វើសេចក្តីសម្រេចចិត្ត ដែលជារឿយៗការទទួលខុសត្រូវចំពោះប្រតិបត្តិការរបស់ សាលារៀន ផ្ទេរទៅឱ្យនាយកសាលា គ្រូបង្រៀន ឪពុកម្តាយ និងសមាជិកសហគមន៍ផ្សេងៗទៀតរបស់សាលា រៀនទទួលខុសត្រូវរួមគ្នាតែម្តង ( Barrera-Osorio, Fasih, & Patrinos, ២០០៩ ) ។ Caldwell ( n.d ) កំណត់វាថាជា "ការធ្វើវិមជ្ឈការជាលក្ខណៈប្រព័ន្ធទៅឱ្យសាលារៀននូវសិទ្ធិ និងការទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅលើកិច្ចការសំខាន់ៗទាក់ទងនឹងប្រតិបត្តិការរបស់សាលារៀន នៅក្នុងក្របខ័ណ្ឌដែលគេបានកំ ណត់នៅថ្នាក់កណ្តាលទាក់ទងនឹងគោលដៅ គោលនយោបាយ កម្មវិធីសិក្សា ស្តង់ដារ និងគណនេយ្យភាព"។

ជាប្រវត្តិសាស្ត្រ ទោះបីជាប្រទេសជាច្រើនបានអនុវត្តប្រព័ន្ធមជ្ឈការនៅក្នុងវិស័យអប់រំដែលផ្តល់អំណាច និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តទាំងអស់ទៅឱ្យរដ្ឋាភិបាលថ្នាក់កណ្តាលក៏ដោយ ក៏នៅដើមសតវត្ស ទី២១ គេអាចមើលឃើញនៅចលនានានានៅទូទាំងពិភពលោកក្នុងការកែប្រែរូបភាពនៃការងាររដ្ឋបាលសាធារណៈទៅជាប្រព័ន្ធវិមជ្ឈការ។ នៅក្នុងវិស័យអប់រំមានកំណែទម្រង់ប្រព័ន្ធសំខាន់ៗចំនួន៣ ដែល Caldwell និង Spinks ( ១៩៩៨ ) បានរកឃើញ ៖ ការកសាងនូវប្រព័ន្ធស្វ័យគ្រប់គ្រងរបស់

សាលារៀន (ការគ្រប់គ្រងដោយ ផ្អែកលើសាលារៀន) ការផ្តោតដោយគ្មានការប្រែប្រួលទៅលើលទ្ធផលនៃការសិក្សារៀនសូត្រ និងការបង្កើត ឡើងនូវសាលារៀនសម្រាប់សង្គមពុទ្ធិ និងសេដ្ឋកិច្ចសកល។ សេចក្តីសន្និដ្ឋានរបស់ពួកគាត់គឺថា ការគ្រប់គ្រង ដោយផ្អែកលើសាលារៀន បានក្លាយទៅជារឿងសាមញ្ញបំផុតក្នុងចំណោមគោលនយោបាយអប់រំរបស់ជាតិ ហើយថា មូលនិធិចម្បងៗនានាត្រូវបានគេបម្រុងទុកសម្រាប់អនុវត្តប្រព័ន្ធបែបនេះនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។

គោលគំនិតស្នូលមួយនៃការគ្រប់គ្រងដោយផ្អែកលើសាលារៀន គឺត្រូវធានាថាសាលារៀននីមួយៗ និង ការិយាល័យអប់រំតាមមូលដ្ឋានមានគណនេយ្យភាពចំពោះឪពុកម្តាយសិស្សអ្នកបោះឆ្នោតនៅតាមមូលដ្ឋាន និងអ្នកនយោបាយនៅមូលដ្ឋាន។ ស្វ័យភាពក្នុងកម្រិតខ្ពស់ត្រូវបានគេផ្តល់ឱ្យសាលារៀន ដើម្បីឱ្យសាលារៀន អាចប្រតិបត្តិការបានដោយឯករាជ្យ។ សាលារៀននីមួយៗត្រូវតែផ្តល់ឱ្យនូវលទ្ធផលចុងក្រោយនៃ *គុណភាពអប់រំខ្ពស់ និងដែលគេចង់បាន"។ ជាទូទៅ សាលារៀន និងសហគមន៍មូលដ្ឋានមានអំណាចក្នុងការធ្វើសេចក្តី សម្រេចចិត្តកាន់តែខ្លាំងទាក់ទងនឹងខ្លឹមសារនៃការសិក្សារៀនសូត្រ ការធ្វើផែនការចំណាយការធ្វើផែន ការសម្រាប់អភិវឌ្ឍ និងកែលម្អសាលារៀន ព្រមទាំងការអនុវត្តភារកិច្ចផ្សេងៗ ជាច្រើនដោយខ្លួនឯងផ្ទាល់។ ទោះជា យ៉ាងណាក៏ដោយ ជាការឆ្លើយតប សាលារៀនចាំបាច់ត្រូវមានគណនេយ្យភាពចំពោះការសម្រេចចិត្តរបស់ខ្លួន ក្នុងការប្រើប្រាស់ធនធានដែលមានតាមរយៈការផ្តល់នូវលទ្ធផលដែលគេចង់បាននៅក្នុងដំណើរការនៃការអប់រំ (Mayston & Jesson, ១៩៨៨)។ នោះគឺអ្វីដែលគោលគំនិតនៃគណនេយ្យភាពរបស់សាលារៀនមានសារៈ សំខាន់ចំពោះវិធីសាស្ត្រនៃការគ្រប់គ្រងដោយផ្អែកលើសាលារៀន។ ទោះបីជាការគ្រប់គ្រងដោយផ្អែកលើសាលារៀន ត្រូវបានគេមើលឃើញថាជាគំរូប្រកបដោយជោគជ័យ មួយនៃការគ្រប់គ្រងការងារអប់រំនៅក្នុងប្រទេសអភិវឌ្ឍ តាមរយៈការកើនឡើងនូវលទ្ធផលនៃការសិក្សារបស់ សិស្សក៏ដោយ ក៏ការសិក្សានានាទៅលើផលជះរបស់វានៅក្នុងប្រទេសកំពុងអភិវឌ្ឍ បានបង្ហាញឱ្យឃើញនូវការ កែលម្អតិចតួចចំពោះគុណភាពអប់រំ (ឧទាហរណ៍ Fullan & Watson, ២០០០; Ouchi & Segal, ២០០៣; Volansky & Friedman, ២០០៣)។ កង្វះនូវភាពជោគជ័យនេះត្រូវបានគេសន្មតថា បណ្តាលមកពីថវិកា ទាបនៅក្នុងប្រទេសកំពុងអភិវឌ្ឍសមត្ថភាពទាប

របស់នាយកសាលានៅក្នុងការប្រតិបត្តិសាលារៀនផ្ទាល់របស់ ខ្លួន និងការធានាសុវត្ថិភាពចំពោះការចូលរួមរបស់សហគមន៍ ឱ្យបានកាន់តែទូលំទូលាយឡើងនៅក្នុងការ អភិវឌ្ឍ និងដំណើរការរបស់សាលារៀន។ ការចូលរួមរបស់សហគមន៍ និងគណនេយ្យភាពរបស់សាលារៀន ដូចដែលបានពន្យល់នៅក្នុងផ្នែកខាងលើ ការចូលរួមរបស់សហគមន៍មូលដ្ឋានត្រូវបានគេបង្ហាញថា ជាជំនួយដ៏ច្រើនសម្រាប់ រៀនក្នុងការប្រតិបត្តិដំណើរការរបស់ខ្លួនឱ្យបានពេញលេញបំផុត។ ការទទួលខុសត្រូវរួមគ្នារបស់សហគមន៍មូលដ្ឋានក្នុងការអភិវឌ្ឍសាលារៀនជួយកំណត់អត្ថន័យពិតប្រាកដនៃគណនេយ្យភាព របស់សាលារៀន (Linn, ២០០៣) ។ ការចូលរួមរបស់សាធារណជន ពោលគឺមិនមែនត្រឹមតែក្នុងចំណោមអ្នក អប់រំ និងសិស្សានុសិស្សប៉ុណ្ណោះទេ តែថែមទាំងអ្នកកាន់ការងាររដ្ឋបាល អ្នករៀបចំគោលនយោបាយ ឪពុក ម្តាយ និងអ្នកស្រាវជ្រាវផ្នែកអប់រំកែលម្អការអប់រំបានតាមរយៈការទទួលខុសត្រូវរួមគ្នា។ នៅក្នុងន័យនេះប្រព័ន្ធ គណ នេយ្យភាពដែលមានប្រសិទ្ធិភាពមួយត្រូវពាក់ព័ន្ធគ្រប់ភាគីទាំងអស់នៅក្នុងការងារអប់រំរួមឬជាសាធារណៈ។ ការចូលរួមមិនគ្រាន់តែកែលម្អគណនេយ្យភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្នែកផ្សេងៗនៃគណនេយ្យភាព ដែល មិនអាចញែកឱ្យដាច់ពីគ្នាបាន ដូចជាស្វ័យភាព គណនេយ្យភាព និងការជឿទុកចិត្ត (Burke, ២០០៥; Cornwall, Lucas & Pasteur, ២០០០)។

គណនេយ្យភាព ស្នាដៃបំពេញការងាររបស់សាលាឡូន និងការសិក្សារៀនរបស់សិស្សានុសិស្ស ភស្តុ តាងជាអន្តរជាតិបង្ហាញថា គណនេយ្យភាពជួយផ្តល់នូវស្នាដៃបំពេញការងារខ្ពស់របស់សាលារៀនដែលទីបញ្ចប់លើកកម្ពស់ការសិក្សារៀនសូត្ររបស់សិស្ស។ ការសិក្សាស្រាវជ្រាវដែលលេចធ្លោមួយស្តីពីកំណែ ទម្រង់គណនេយ្យភាពថ្មីៗនេះ បានរកឃើញនូវឥទ្ធិពលវិជ្ជមាននានា ទៅលើលទ្ធផលនៃការរៀនសូត្ររបស់ សិស្សនៅក្នុងការប្រឡងថ្នាក់ជាតិ (ឧទាហរណ៍ Burgess, et al., ២០០៥; Carnoy & Loeb, ២០០២; Hanushek & Raymond, ២០០៤)។ បើយោងតាមទ្រឹស្តីនៃសកម្មភាពរបស់គណនេយ្យភាព (Amo, ២០១៥; Figlio & Loeb, ២០១១; Jacob, ២០០៥) ការធ្វើឱ្យអ្នកអប់រំ និងថ្នាក់ដឹកនាំសាលារៀនមានគណនេយ្យភាព ចំពោះលទ្ធផលនៃការសិក្សារៀនសូត្ររបស់សិស្សានុសិស្ស (ពោលគឺគណនេយ្យភាពដែលផ្អែកលើលទ្ធផលនៃការសិក្សានឹងជំរុញលើកទឹកចិត្តពួកគាត់ធ្វើឱ្យភាពស្របគ្នារវាង

អាកប្បកិរិយា និងការអនុវត្តការណែនាំដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស។ នៅក្នុងការសិក្សានានារបស់ Deere និងStrayer (២០០១) ព្រមទាំង Cullen និង Reback (២០០៦) នៅក្នុងរដ្ឋ Texas គណនេយ្យភាពកាន់ តែទូលំទូលាយឡើង គឺជាប់ទាក់ទងនឹងការកើនឡើងយ៉ាងច្រើនចំពោះអត្រាគង់វង្សនៅក្នុងថ្នាក់។ ការសិក្សា មួយចំនួនបានរកឃើញថា គោលនយោបាយគណនេយ្យភាពកាន់តែមានប្រសិទ្ធិភាពច្រើនថែមទៀតនៅតាម បណ្ដារដ្ឋនានា ដែលមានការធ្វើប្រតិភូកម្មកាន់តែច្រើនឡើងនូវការធ្វើសេចក្ដីសម្រេចចិត្តទៅឱ្យថ្នាក់មូលដ្ឋាន។ ឧទាហរណ៍ Loeb និង Strunk (២០០៧) បានសន្និដ្ឋានថា បើគ្មានការត្រួតត្រាខ្លះពីថ្នាក់មូលដ្ឋានទេ ទោះបី គោលនយោបាយគណនេយ្យភាពត្រូវបានគិតគូរយ៉ាងល្អិតល្អន់យ៉ាងណាក៏ដោយ ក៏គោលនយោបាយនោះមាន ប្រសិទ្ធិភាពតិចដែរ ហើយពេលខ្លះគ្មានប្រសិទ្ធិភាព និងបង្កការឈឺចាប់ទៀតផង។

## ២.៧ សកម្មភាពរបស់សហគមន៍ក្នុងការចូលរួមចំណែកអភិវឌ្ឍសាលារៀន

សហគមន៍អាចចូលរួមនៅក្នុងសកម្មភាពមួយចំនួនដើម្បីធានាថា សាលារៀនកំពុងនាំមកនូវលទ្ធផល ដែលគេចង់បានសម្រាប់កូនៗរបស់គាត់។ ឧទាហរណ៍ ដោយមានព័ត៌មាន និងការគាំទ្រត្រឹមត្រូវ សហគមន៍ អាចត្រួតពិនិត្យ និងវាយតម្លៃការងាររបស់សាលារៀន និងគ្រូបង្រៀន។ នៅត្រង់ចំណុចនេះ ពួកគាត់អាច ពិនិត្យ មើលពីរបៀបដែលសាលារៀន និងគ្រូបង្រៀនអនុវត្តកម្មវិធីសិក្សារបស់ជាតិសម្រាប់ការរៀនសូត្រពេញលេញ របស់សិស្សានុសិស្ស ព្រមទាំងរកឱ្យឃើញនូវឧបសគ្គនានាដែលសាលារៀន និងគ្រូបង្រៀនមាននិងស្វែងរកដំណោះស្រាយដែលអាចធ្វើទៅបាន។ ទី២ សាលារៀនក៏ត្រូវការជំនួយពីសហគមន៍ដែរ ក្នុងការរៀបចំផែនការ កែលម្អសាលារៀន និងផែនការថវិកា។ តាមការអះអាង ចំណុចនេះមានសារៈសំខាន់ខ្លាំងណាស់នៅក្នុង ប្រទេសកំពុងអភិវឌ្ឍដែលភស្តុតាងនានាបញ្ជាក់ថា នាយកសាលា និងបុគ្គលិករបស់សាលារៀនមានសមត្ថភាព ទាបក្នុងការរៀបចំផែនការអប់រំ។ ការចូលរួមរបស់សហគមន៍ក៏ជាយន្តការមួយដែរក្នុងការធានាបាននូវតម្លាភាព ចំពោះតួនាទី និងការទទួលខុសត្រូវរបស់សាលារៀន។ សហគមន៍ អាចធ្វើការជាមួយសាលារៀនក្នុងការលើក កម្ពស់បរិស្ថានល្អសម្រាប់ការរៀន និងការបង្រៀន

ពេលខ្លះរាប់បញ្ចូលទាំងទិដ្ឋភាពនានាដែលគេពិពណ៌នាថា សាលារៀន "មានលក្ខណៈមេត្រីសម្រាប់ការរៀនសូត្រ" ដែលរាប់បញ្ចូលទាំងសុវត្ថិភាព ភាពស្រស់ស្អាត និង បរិស្ថានរូបវន្តរបស់សាលារៀន។

គណនេយ្យភាពរបស់សាលារៀនមិនត្រឹមតែកែលម្អពិន្ទុតេស្តរបស់សិស្សានុសិស្សប៉ុណ្ណោះទេ។ បញ្ញវន្ត ផ្នែកគណនេយ្យភាពមួយចំនួន ដែលមានការប្រឆាំងនឹងការប្រើប្រាស់ពិន្ទុតេស្ត នៅក្នុងការកំណត់ គណ នេយ្យភាពរបស់សាលារៀនបានរៀបចំការសិក្សាជាច្រើន ដើម្បីពិនិត្យមើលពីរបៀបដែលគណនេយ្យភាព ដើរ តួនាទីដ៏សំខាន់មួយចំពោះការសិក្សារៀនសូត្ររបស់សិស្ស ។ ការសិក្សានានាបានរកឃើញថា យន្តការគណ នេយ្យភាពរបស់សាលារៀនក៏អាចកែលម្អលទ្ធផលសិក្សារៀនសូត្រជំនាញ ក្នុងការដោះស្រាយបញ្ហាកិច្ចសហការ ការប្រាស្រ័យទាក់ទង ភាពប៉ិនប្រសប់ និងការអត់ធ្មត់ដែរ (Turnipseed & Darling-Hammond, ២០១៥)។ ពួកគាត់បានអះអាងថា ជំនាញទាំងនេះពិតជាមានសារៈសំខាន់ខ្លាំងជាងពិន្ទុតេស្តដែលសិស្ស សម្រេចបានទៅទៀត ដោយសារជំនាញទាំងនេះជួយអ្នកបញ្ចប់ការសិក្សាឱ្យរៀបចំខ្លួនសម្រាប់ឱកាសការងារ ដែលតម្រូវឱ្យមានជំនាញដែលផ្ទេរបាន និងដែលសិស្សមិនអាចរំពឹងទុកមុនបាននៅពេលជ្រើសរើសមុខវិជ្ជាជាក់លាក់នានាដើម្បីសិក្សា ឬការបណ្តុះបណ្តាលបច្ចេកទេស។ វិធីសាស្ត្រជាតិគណនេយ្យភាពរបស់សហគមន៍សម្រាប់សាលារៀនយុទ្ធសាស្ត្រផ្សេងៗគ្នាជាច្រើនដើម្បីបង្កើនគណនេយ្យភាពរបស់សាលារៀន ត្រូវបានគេអនុវត្តទាំងនៅ ក្នុងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍដោយមានទាំងទទួលជោគជ័យ និងបរាជ័យនៅក្នុងបរិបទខុសៗគ្នា។ ដើម្បីធានាបាននូវការប្រតិបត្តិល្អបំផុតនានា ប្រទេសដែលជាសមាជិក OECD ភាគច្រើនបានអនុវត្តនូវ យន្តការដែលរួមបញ្ចូលគ្នាមួយដើម្បីធ្វើឱ្យសាលារៀនមានគណនេយ្យភាព។ យន្តការទាំងនេះត្រូវបានគេចងជា កម្រងគណនេយ្យភាពចំនួន៣ធំៗ ៖ គណនេយ្យភាពនៃស្នាដៃបំពេញការងារ គណនយ្យភាពផ្នែកបទបញ្ញា និងគណនេយ្យភាពផ្នែកទីផ្សារ (OECD ២០១១)។ ស្ថិតក្រោមគណនេយ្យភាពនេះ សាលារៀនតាមតំបន់ ជនបទគឺជាកម្មវត្ថុចំពោះការធ្វើរបាយការណ៍ស្តីពីស្នាដៃបំពេញការងាររបស់ខ្លួន ជាពិសេសការសិក្សារៀនសូត្រ របស់សិស្សដើម្បីឱ្យអង្គភាពអភិបាលកិច្ច និងសាធារណៈជន អធិការកិច្ចខាងក្រៅ ការអនុវត្តស្វ័យវាយតម្លៃដែលបានរៀបចំផែនការ និងជាទៀងទាត់ ព្រមទាំងការប្រកួតប្រជែងដើម្បីទទួលបានមូលនិធិ។ ស្នាដៃ

បំពេញ ការងារពុំបានល្អនៅក្នុងប្រព័ន្ធទាំងនេះអាចបណ្ដាលឱ្យមានការកាត់បន្ថយចំពោះថវិការបស់សាលារៀន។ គំរូ របស់ OEDC សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការមានប្រព័ន្ធត្រួតពិនិត្យដែលបានបង្កើតឡើងយ៉ាងល្អិតល្អន់ និងសកម្មដើម្បីសម្របសម្រួលស្ថាដែបំពេញការងាររបស់សាលារៀននៅថ្នាក់មូលដ្ឋាន។

## ២.៨ សមិទ្ធិផលរបស់របស់សហគមន៍ក្នុងការចូលរួមចំណែកអភិវឌ្ឍសាលារៀន

របៀបដែលប្រព័ន្ធគណនេយ្យភាពរបស់សាលាត្រូវបានរៀបចំឡើង អាចមានឥទ្ធិពលយ៉ាងសំខាន់ទៅលើធម្មជាតិ និងកម្លាំងនៃការលើកទឹកចិត្តដែលសាលារៀនប្រឈមមុខនឹងការលើកកម្ពស់សិស្សឱ្យសម្រេចបានលទ្ធផលនៅក្នុងមុខវិជ្ជាដែលបានសាកល្បង។ លើសពីនេះ ការរចនាអាចប៉ះពាល់ដល់សិស្សានុសិស្ស ការយកចិត្តទុកដាក់បំផុត។

ប្រព័ន្ធគណនេយ្យភាពរបស់សាលាអាចអនុវត្តវិធីសាស្ត្រពីរផ្សេងគ្នាទាក់ទងនឹងផលវិបាកនៃការទទួលខុសត្រូវ។ លទ្ធភាពមួយគឺរួមបញ្ចូលរង្វាន់ច្បាស់លាស់ និង/ឬទណ្ឌកម្មសម្រាប់ការអនុវត្តលើសពី ឬមិនបំពេញតាមការរំពឹងទុក។ ឧទាហរណ៍នៃផលវិបាកជាវិជ្ជមានសម្រាប់សាលារៀន និងអ្នកអប់រំនៅក្នុងប្រព័ន្ធទាំងនេះអាចរួមបញ្ចូលការកើនឡើងធនធាន ឬស្វ័យភាពក្នុងការចំណាយធនធានទាំងនេះនៅកម្រិតសាលា។ និងប្រាក់រង្វាន់សម្រាប់អ្នកអប់រំនៅសាលាជោគជ័យ។ ប្រព័ន្ធគណនេយ្យភាពមួយចំនួនផ្តល់រង្វាន់ដល់សាលារៀនដែលលើសពីការរំពឹងទុកដែលបានបញ្ជាក់ ឬផ្លាស់ទីយ៉ាងខ្លាំងក្នុងទិសដៅនៃការធ្វើដូច្នេះ។ នៅផ្នែកម្ខាងវិញ ប្រព័ន្ធគណនេយ្យភាពក៏ជារឿយៗរួមបញ្ចូលការដាក់ទណ្ឌកម្មច្បាស់លាស់សម្រាប់សាលារៀនដែលមិនបំពេញតាមការរំពឹងទុក។ ឧទាហរណ៍នៃទណ្ឌកម្មទាំងនេះរួមមានការដកស្វ័យភាព; តម្រូវឱ្យភ្នាក់ងារអប់រំក្នុងស្រុកផ្តល់បន្ថែមជម្រើសសាលារៀន - ទាំងជម្រើសសាលារៀន ឬសេវាកម្មបន្ថែម - ដល់សិស្សនៅក្នុងទាំងនេះ

សាលារៀន; និងការរៀបចំរចនាសម្ព័ន្ធសាលាឡើងវិញ ឬបិទសាលាទាំងស្រុង។ ការសិក្សាជាច្រើនរួមទាំង Hanushek និង Raymond (២００៥) និង Dee and Jacob (២００៩), ប្រព័ន្ធគណនេយ្យភាពសាលាប្រហែលជាមិនចាំបាច់មានផលវិបាកច្បាស់លាស់ពីមជ្ឈិម ទោះជាយ៉ាងណាក៏ដោយអាជ្ញាធរមានឥទ្ធិពលលើអាកប្បកិរិយារបស់អ្នកអប់រំ។ ដូចដែលបានរៀបរាប់ខាងលើ រដ្ឋាភិបាលកណ្ដាលគឺគ្រាន់តែជា

អ្នកឃ្លាំមើលការអនុវត្តសាលាជាច្រើនប៉ុណ្ណោះ ហើយការអនុវត្តផ្សេងទៀតរបស់ moni tors ឪពុកម្តាយ និងសមាជិកសហគមន៍ អាចខ្ទប់កណ្តាប់ដៃគ្រប់គ្រាន់ដើម្បីមានឥទ្ធិពលលើអ្នកអប់រំ។ អាកប្បកិរិយា។ អក្សរសិល្ប៍សេដ្ឋកិច្ចទូលំទូលាយលើតួនាទីនៃព័ត៌មានអំពីគុណភាពផលិតផល បង្ហាញថាតើការលោតត្រដាងព័ត៌មានដ៏រឹងមាំសម្រាប់សមាជិកអាចមានឥទ្ធិពលលើទីផ្សារ ហើយវាមានភាពប្រាកដនិយមក្នុងការរំពឹងថានឹងមានទីផ្សារដ៏ធំមួយ ។ ប្រភពនៃផលវិបាកនៃការទទួលខុសត្រូវរបស់សាលានឹងជាសម្ពាធសហគមន៍ និងមូលដ្ឋានបង្កឡើងដោយការបង្កើនលទ្ធភាពទទួលបានព័ត៌មាន។ Figlio and Lucas (២០០៤) បង្ហាញថាទីផ្សារលំនៅដ្ឋានមានប្រតិកម្មកាន់តែខ្លាំងចំពោះព័ត៌មានដែលបានបង្កប់នៅក្នុងប្រព័ន្ធគណនេយ្យភាពរបស់សាលា។

ការរកឃើញនៃការសិក្សាទាំងពីរនេះចាប់តាំងពីពេលនោះមកត្រូវបានចម្លងនៅក្នុងការកំណត់ជាច្រើននៅក្នុងភាគខាងជើងអាមេរិក និងអឺរ៉ុប។ Figlio and Kenny (២០០៩) ក៏បង្ហាញថាឪពុកម្តាយ និងសហគមន៍

សមាជិកមិនទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសាលា ដែលរដ្ឋាភិបាលកណ្តាលនិយាយដំណើរការមិនល្អ និងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ថែមទៀត ដល់អ្នកដែលរដ្ឋាភិបាលកណ្តាលនិយាយកំពុងដំណើរការបានល្អ។ សម្ពាធហិរញ្ញវត្ថុនេះ រួមជាមួយនឹងសម្ពាធក្រៅផ្លូវការផ្សេងទៀត។ ប្រាកដជាអមជាមួយវា ដោយផ្តល់យោបល់យ៉ាងមុតមាំថា សូម្បីតែអវត្តមានលទ្ធផលផ្លូវការនៃសមត្ថភាពគណនី ប្រព័ន្ធគណនេយ្យភាពអាចនឹងមានប្រសិទ្ធភាពក្នុងការជះឥទ្ធិពលលើអាកប្បកិរិយាអ្នកអប់រំ ប្រព័ន្ធគណនេយ្យភាពរបស់សាលាមានភាពខុសប្លែកគ្នានៅក្នុងចំនួន និងប្រភេទនៃការធ្វើតេស្ត ឬការអនុវត្តផ្សេងទៀត។

សូចនាករ ពួកគេរួមបញ្ចូលរដ្ឋាភិបាលកណ្តាលប្រឈមមុខនឹងការដោះដូរដ៏សំខាន់នៅពេលកំណត់របៀបទូលំទូលាយដើម្បីបង្កើតប្រព័ន្ធគណនេយ្យភាពរបស់ពួកគេ។ ជាពិសេសប្រព័ន្ធដែលតម្រឹមគណនេយ្យភាពសាលា ៣៨៩ទំនួលខុសត្រូវជាមួយនឹងលទ្ធផលតូចជាង មានទំនោរធ្វើឱ្យវិសាលភាពនៃការអប់រំតូចចង្អៀតផ្តល់ជូនសិស្ស។ ម៉្យាងវិញទៀត លទ្ធផលយ៉ាងទូលំទូលាយគឺពិបាកជាងក្នុងការបញ្ជាក់ឱ្យច្បាស់ថាអាចទុកចិត្តបាន ហើយអាចធ្វើឱ្យការផ្តោតអារម្មណ៍របស់បុគ្គលិកសាលា និងសាលាស្រុកមិនច្បាស់លាស់។ ប្រព័ន្ធគណនេយ្យភាពរបស់សាលាមានគោលបំណងផ្តល់នូវការលើកទឹកចិត្ត សម្រាប់

សាលារៀនក្នុងការបង្កើនប្រសិទ្ធភាពការងារខ្ពស់នៅក្នុងមុខវិជ្ជាសិក្សា ហើយជាការពិតណាស់ សាលារៀនហាក់ដូចជាយកចិត្តទុកដាក់លើប្រធានបទដែលការធ្វើតេស្តត្រូវបានផ្អែកលើ។ ភស្តុតាងដែលអាចរកបានយ៉ាងខ្លាំងគាំទ្រការ សន្និដ្ឋានថាសាលារៀនមានទំនោរផ្តោតការយកចិត្តទុកដាក់របស់ពួកគេលើមុខវិជ្ជាបានធ្វើតេស្ត និងលើថ្នាក់ដែលមានការប្រលងជាប់ខ្ពស់ (Deere and Strayer, ២០០១; Ladd និង Zelli ២០០២; Stecher et al., ២០០០)។ ការសិក្សាផ្សេងទៀត (ឧ. Hamilton et al., ២០០៥; Jones et al., ១៩៩៩; Koretz និង Hamilton, ២០០៣; លីន, ២០០០; Stecher et al., ១៩៩៨; និង Stecher et al., ២០០០) បង្ហាញថាគ្រូបង្រៀន និងសាលារៀនមានទំនោរបង្រួមកម្មវិធីសិក្សា និងផ្លាស់ប្តូររបស់ពួកគេ។ការសង្កត់ធ្ងន់លើការបង្រៀនពីមុខវិជ្ជាដែលមិនបានធ្វើតេស្តទៅមុខវិជ្ជាដែលបានសាកល្បង ខណៈពេលដែលការងារមុនដោយ Shepard និង Dougherty (១៩៩១) និង Romberg et al. (១៩៨៩) ណែនាំថា គ្រូបង្រៀនផ្តោតសំខាន់លើតំបន់មាតិកាដែលបានសាកល្បងនៅក្នុងមុខវិជ្ជាជាក់លាក់។ នៅក្នុងការងារដែលពាក់ព័ន្ធ Chakrabarti (២០០៥) មុនបានបញ្ជូនភស្តុតាងដែលថាសាលារៀនអាចប្រមូលផ្តុំថាមពលរបស់ពួកគេនៅលើ បេសកកម្មរបស់សហគមន៍សាលារដ្ឋគឺដើម្បីប្រកួតប្រជែងជាមួយនឹងកម្រិតខ្ពស់រំពឹងថាកុមារម្នាក់ៗនឹងរៀន សម្រេចបាន និងបំពេញបំណងរបស់គាត់។

- ABCs ពឹងផ្អែកលើសាលារៀនក្នុងស្រុក និងសាលារៀនដើម្បីចូលរួមទាំងអស់គ្នាមាតាបិតា គ្រូបង្រៀន និងតំណាងសហគមន៍ក្នុងដំណើរការរៀបចំផែនការនិងអភិវឌ្ឍ និងអនុវត្តកម្មវិធី និងគណនេយ្យភាពមូលដ្ឋាន

ប្រព័ន្ធវាយតម្លៃដែលបំពេញបន្ថែមផែនការ ABCs របស់រដ្ឋ។

- ABCs ទទួលស្គាល់សិទ្ធិរបស់សាធារណជនក្នុងការដឹងពីការអនុវត្តក្នុងស្រុក សាលារៀន និងស្រុកសាលា។ កាតរបាយការណ៍សាលានឹងរួមបញ្ចូលការសង្ខេប ទិន្នន័យអំពីស្ថានភាពសាលារៀនទាំងអស់នៅលើសូចនាករនៅក្នុង ABCs ។ ទិន្នន័យគឺរាយការណ៍ទៅក្រុមប្រឹក្សាអប់រំរដ្ឋ និងផ្តល់ជូនឪពុកម្តាយ និងសាធារណជនទូទៅ។ David (2021)

ក្រុមកែលម្អសាលារៀនសម្រាប់ការគ្រប់គ្រងតាមសាលារៀន (SBM) មានគោលបំណងធ្វើវិមជ្ឈការ

ការសម្រេចចិត្តដោយការផ្ទេរសិទ្ធិអំណាច និងធនធានពីទីភ្នាក់ងារអប់រំរដ្ឋ និង LEAs ដល់អង្គភាពដូចជាក្រុមប្រឹក្សាអភិបាលកិច្ច គណៈកម្មាធិការ ឬក្រុមដែលមានទីតាំងនៅបុគ្គល។ ការគ្រប់គ្រងតាមគេហទំព័រគឺជាវិធីសាស្ត្រមួយក្នុងការធ្វើកំណែទម្រង់ការអប់រំដែលអនុញ្ញាតឱ្យមានសាលាបុគ្គល ដើម្បីធ្វើការសម្រេចចិត្តដោយខ្លួនឯងទាក់ទងនឹងហិរញ្ញវត្ថុ និងកម្មវិធីសិក្សា។ ភាពជាអ្នកដឹកនាំក្រុមប្រឹក្សាក្រុម ដែលជាធម្មតាមាន នាយកសាលា គ្រូ និងឪពុកម្តាយ ជាអ្នកកំណត់ទិសដៅគោលនយោបាយសម្រាប់សាលា។ក្រុមកែលម្អសាលារៀនអាចដោះស្រាយបញ្ហាដោយផ្ទាល់ ឬដោយប្រយោលទាក់ទងនឹងការណែនាំការសម្តែងរបស់សិស្ស និងបរិស្ថានសាលាការកែលម្អ។ ការសម្រេចចិត្តគួរតែត្រូវបានធ្វ/ើឡើងដោយការឯកភាពនៅពេលណាដែលអាចធ្វើទៅបាន ជាមួយនឹងជម្រើសជំនួស។ តើនឹងមានអ្វីកើតឡើងប្រសិនបើក្រុមមិនអាចឈានដល់ការឯកភាពទេ? ការសម្រេចចិត្តត្រូវបានចងនៅលើសាលា, ផ្តល់ឱ្យការសម្រេចចិត្តគឺនៅក្នុងអាជ្ញាធររបស់សាលា។ LEA គួរតែសម្រេចចិត្តក្នុងកម្រិតដែលអាចអនុវត្តបាន។ តំបន់ដែលក្រុមសាលានឹងមានសិទ្ធិអំណាចចុងក្រោយ និងតំបន់ដែលសាលាក្រុមកែលម្អនឹងបម្រើក្នុងសមត្ថភាពប្រឹក្សា។ LEA ដោយមានការចូលរួមពីមាតាបិតា។

គួរតែកំណត់តួនាទី ច្បាប់ និងទំនួលខុសត្រូវសម្រាប់អ្នកគ្រប់គ្រង គ្រូបង្រៀន សិស្ស និងមាតាបិតា ប្រសិនបើក្រុមទទួលបានជោគជ័យក្នុងការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តរបស់សិស្ស និងកំណែទម្រង់សាលា។ តាម រយៈការអនុវត្តក្រុមកែលម្អសាលារៀន ឪពុកម្តាយ និងសហគមន៍ផ្សេងទៀត។

សមាជិកអាចចូលរួមក្នុងដំណើរការធ្វើការសម្រេចចិត្ត។ ឪពុកម្តាយផ្តល់ការយល់ដឹងដ៏មានតម្លៃអំពីរបៀបដែលដំណើរការសិក្សាអាចត្រូវបានកែលម្អ ដើម្បីអប់រំកុមារឱ្យកាន់តែប្រសើរឡើងសហគមន៍។ ក្រុមអាចជាក្រុមមួយក្នុងចំណោមបី (3) ប្រភេទ។

ការបម្រើក្នុងសមត្ថភាពផ្តល់ប្រឹក្សា ក្រុមការងារផ្តល់ការបញ្ចូល ប៉ុន្តែការបំពេញបន្ថែម ( School-Based Management And Accountability Procedures Manual, Oct ២០០៤) "គណនេយ្យភាពរបស់សាលារៀនចំពោះមាតាបិតា គឺជាគោលដៅនៃកំណែទម្រង់វិស័យអប់រំ"សារខ្លីរបស់លោកបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្នុងពិធីសម្ពោធការដាក់ឱ្យអនុវត្តគម្រោងគាំទ្រ ផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២ នៅថ្ងៃទី១៨ ខែកុម្ភៈ និងក្នុងយុទ្ធនាការផ្សព្វផ្សាយការងារគណនេយ្យសង្គម។

សហគមន៍យល់ថាត្រូវតែអភិវឌ្ឍការដឹកនាំឈានឱ្យដល់កម្រិតនៃការដឹកនាំដោយមិនបាច់ដឹកនាំ ជាការហត់នឿយណាស់បើអង្គភាពមួយមានបញ្ហារាប់រយដែលត្រូវចំណាយពេល សម្រាប់ដោះស្រាយវាហើយមិនមានពេលវេលាធ្វើកិច្ចការដើម្បីអភិវឌ្ឍ។ អ្នកដឹកនាំគោលនយោបាយ មន្ត្រីអប់រំ សាលារៀន និង សហគមន៍ មានភាពប្រាកដក្នុងចិត្តថាត្រូវតែរៀនរស់ក្រោមច្បាប់ ព្រោះនេះជាអភិបាលកិច្ច ប្រការនេះនឹងបញ្ចៀសនូវបញ្ហារាប់រយដែលមិនបានការ ប្រើពេលវេលាគិតនិងជួយមនុស្សក្នុងសង្គម ហើយដែលពេលខ្លះការពិតនៃជីវិតដែលវាលើសពីច្បាប់ គោលការណ៍ដែលបានណែនាំ ដែលទាមទារឱ្យមានការធ្វើបច្ចុប្បន្នកម្មច្បាប់ សេចក្តីណែនាំជាប្រចាំដើម្បីជួយសង្គម និងមនុស្សជាច្រើនឱ្យទាន់ពេលវេលា ជួយមនុស្សម្នាក់ៗនិងមនុស្សគ្រប់រូប ឱ្យក្លាយជាអ្នកដឹកនាំ បើបុគ្គលគ្រប់រូបជាអ្នកដឹកនាំ នោះមិនត្រូវការការដឹកនាំឡើយ តែអ្វីមួយគត់ដែលមនុស្សត្រូវការគឺការកំណត់ទិស។

គុណតម្លៃសហគមន៍និងសាលារៀន ជាការអនុវត្តគំនិតល្អដែលព្រមព្រៀងគ្នាក្នុងរយៈពេលមួយកំណត់ គំនិតល្អនោះនិងក្លាយជាគុណតម្លៃ។

**សាលារៀននិងសហគមន៍៖**

១. នឹងបម្រើប្រយោជន៍រួម និង ប្រសើរបំផុតសម្រាប់ប្រជាជននិងសិស្ស

២. គោរពនិងថែទាំគ្នាទៅវិញទៅមក

៣. រៀនសូត្រនិងធ្វើការជាក្រុមប្រចាំឆ្នាំ

៤. ផ្តួចផ្តើមគំនិតថ្មីសម្រាប់អភិវឌ្ឍសាលារៀននិងសហគមន៍

៥. ធ្វើឱ្យមាននិរន្តរភាពដំណើរការសាលារៀន និងរៀបចំសិស្សរបស់យើងសម្រាប់រស់ជាមួយជីវិតនិងការងារដែលប្រសើរ។

**ភារកិច្ចចម្បងរបស់នាយកសាលា និង គ.គ.ស ឬ ក.ប.ស**

នាយកសាលាដែលបានអភិវឌ្ឍសាលារៀន បំពេញបាននូវស្តង់ដារសាលារៀន មានប្រសិទ្ធិភាពជានាយកសាលាល្អ ហើយគាត់នឹងត្រូវបន្តការងាររបស់គាត់ជានាយកសាលា។ នាយកសាលាមានតួនាទីជាប្រធានប្រតិបត្តិ ហើយគាត់និងសហគមន៍មានភារកិច្ចធំៗដូចខាងក្រោម៖

១. កែលម្អការរៀនសូត្ររបស់សិស្សពីថ្នាក់ទី៧ ដល់ទី១២ នាំឱ្យសិស្សអាចរៀនទទួលបាននូវកម្រិតល្អនិងល្អប្រសើរលើមុខវិជ្ជាគោល

២. ផ្តោតការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា ជាអទិភាពពិសេសនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា

៣. អនុវត្តអនុសាសន៍របាយការណ៍ការគ្រប់គ្រងហិរញ្ញវត្ថុនិងសវនកម្ម។

៤. ធ្វើឱ្យការសិក្សាមានភាពបន្ស៊ីគ្នារវាងសាលាមត្តេយ្យសិក្សា បឋមសិក្សា និង មធ្យមសិក្សាដើម្បីឈានឆ្ពោះទៅឧត្តមសិក្សា

៥. បង្កើនប្រសិទ្ធផល និងបង្កើនមុខសញ្ញាប្រើប្រាស់ធនធាន ដោយផ្តោតលើអាទិភាពរបស់សាលារៀនដែលមានមូលដ្ឋានលើយុទ្ធសាស្ត្រ វប្បធម៌និងគុណតម្លៃ។

**និរន្តរភាពសហគមន៍សាលារៀន**

កត្តាដែលនាំឱ្យសហគមន៍សាលារៀនមាននិរន្តភាព មានចរិយាដឹកនាំផ្តោតលើលទ្ធផលផ្អែកលើវប្បធម៌ និងគុណតម្លៃអង្គភាពសមត្ថភាពស្ថាប័ននិងសមត្ថភាពទាំង៤ដែលមាន សមត្ថភាពមន្ត្រី សមត្ថភាពហិរញ្ញវត្ថុការអនុវត្តវប្ប ។

## ២.៩ ការវិភាគការអនុវត្តការងាររបស់សាលារៀន

ការវិភាគត្រូវដោយក្រាហ្វទិន្នន័យនៅថ្នាក់ជាតិ ដែលត្រូវមាន៖

ក. ពិន្ទុស្តង់ដាសាលារៀន មានប្រសិទ្ធិភាពរវាងសាលាក្នុង ក្រុង ស្រុក ខ័ណ្ឌ ឬរាជធានី ខេត្ត ទំនោនៃការរីកចម្រើននៃពិន្ទុសាលារៀនមានប្រសិទ្ធិភាពពី ២ ឬ ៣ ឬ ៤ឆ្នាំ នៃសាលារៀនក្នុង ក្រុង ស្រុក ខ័ណ្ឌ ឬ រាជធានី ខេត្ត ។

### ២.៩.១ យុទ្ធសាស្ត្រអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀនៈ ប្រព័ន្ធ ៣ អា បិទជិត

រូបភាពទី ១៖ ប្រព័ន្ធ ៣ អា បិទជិត




ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *សៀវភៅណែនាំប្រតិបត្តិ ស្តីពីការគ្រប់គ្រងសាលារៀន* គម្រោងកែលម្អការអប់រំ នៅមធ្យមសិក្សា។

ពាក់ព័ន្ធនិងការអភិវឌ្ឍមូលធនមនុស្ស តាមទិន្នន័យរបស់ក្រសួងអប់រំ យុវជន និង កីឡា និងការសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោក (ការអប់រំមនុស្សជំនាន់ក្រោយ) បង្ហាញនូវការបែងចែក និង ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន មានដូចជាការបែងចែកគ្រូបង្រៀនមិនសមស្របតាមតម្រូវការ ឧទាហរណ៍ ផលធៀបគ្រូ/សិស្សនៅមធ្យមសិក្សាក្នុងរាជធានីភ្នំពេញគឺ១/១៤.៨ តែនៅខេត្តព្រៃវែង១/២៩.៩។ ការបំពេញការងាររបស់គ្រូបង្រៀនវិញ ជាមធ្យម ៤៧.៦ភាគរយ នៃសំណាកគំរូមានកិច្ចតែងកា

បង្រៀន ក្នុងនោះ ៦៦.២ភាគរយជាគ្រូបង្រៀន នៅតំបន់ប្រជុំជន និងមានតែ៣៤.៧ភាគរយ ប៉ុណ្ណោះ សម្រាប់គ្រូបង្រៀននៅតំបន់ជនបទ និងដាច់ស្រយាល។ គ្រូបង្រៀនដែលអវត្តមានញឹកញាប់មានចំនួន ៦ ភាគរយ ក្នុងនោះ ៣.៦ភាគរយ នៅតំបន់ប្រជុំជន ៧.៦ភាគរយ នៅតំបន់ជនបទ និង ១០.២ភាគរយ នៅតំបន់ដាច់ស្រយាល ។

ជារួម ក្រសួងអប់រំ យុវជន និង កីឡា ចាំបាច់ត្រូវពង្រឹងគណនេយ្យភាពក្នុងប្រព័ន្ធអប់រំដើម្បីធានាថា សាលារៀនទទួលបានធនធាន/ដែលមានគុណភាពស្របតាមនិយាម (គ្រូបង្រៀន និងសម្ភារៈរូបវន្ត) ស្តង់ដាកំណត់ ហើយសាលរៀនត្រូវប្រើប្រាស់ធនធានទាំងនោះឱ្យអស់លទ្ធភាព ។ ផ្អែកតាមស្ថានភាពខាងលើ និងសមត្ថភាពដែលមានស្រាប់ ក្រសួងអប់រំ យុវជន និង កីឡា ផ្តោតលើការអន្តរាគមន៍ និងផ្តល់ការគាំទ្រដល់សាលារៀនមួយចំនួនដើម្បីក្លាយជាសាលាមានឧត្តមានុវត្តនិងបំពេញបានស្តង់ដាសាលារៀនមានប្រសិទ្ធភាព។ ការចូលរួម និងការប្តេជ្ញាចិត្ត របស់មន្ត្រីអប់រំគ្រប់កម្រិត របស់សិស្សានុសិស្ស របស់សហគមន៍ និងមាតាបិតាអ្នកអាណា/ព្យាបាល ជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន។

**២.៩.២ ចំណេះដឹងសាកលលោកពីការគ្រប់គ្រងតាមសាលារៀនៈ វិមជ្ឈការ និងអប់រំ**

ក្របខ័ណ្ឌនៃគំនិតវិមជ្ឈការៈ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានឆ្ពោះទៅរកគណនេយ្យភាព

ក្នុងបរិបទកម្ពុជាបច្ចុប្បន្ន ការទទួលខុសត្រូវថ្នាក់ជាតិ(ព្រួញដាច់ៗ) គឺជាការផ្តល់ធាតុចូលដែលមានគុណភាពដល់សាលារៀន។ ឧទាហរណ៍ កង្វះអគារសិក្សាជាបញ្ហាប្រឈមចម្បងមួយៈ នៅតំបន់ប្រជុំជនភាគច្រើនមានអគារសិក្សាគ្រប់គ្រាន់ ចំណែកនៅតំបន់ជនបទនៅតែខ្វះអគារសិក្សា។ មួយវិញទៀត គណនេយ្យភាពក្នុងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពគឺ (១) មិនមានភាពច្បាស់លាស់ ដូចជាការបើកថ្នាក់រៀនយឺត និងបិទថ្នាក់រៀនមុនម៉ោងកំណត់ (២) គ្រូបង្រៀន ២ភាគ៣ នៅជនបទមិនធ្វើកិច្ចតែងការបង្រៀន។ ភស្តុតាងទាំងអស់នេះជាឧទាហរណ៍មួយបង្ហាញថា ប្រសិទ្ធភាពនៃការអនុវត្តកិច្ចអន្តរាគមន៍ថ្នាក់ជាតិនៅមានកម្រិត ។

រូបភាពទី ២៖ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានឆ្ពោះទៅរកគណនេយ្យភាព




ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា(២០១៨) *សៀវភៅណែនាំប្រតិបត្តិ ស្តីពីការគ្រប់គ្រងសាលារៀនគម្រោងកែលម្អការអប់រំ នៅមធ្យមសិក្សា។*

ក្នុងបរិបទសាកលលោក ការប្រើប្រាស់យន្តការអន្តរាគមន៍ ថ្នាក់មូលដ្ឋាន ដោយផ្ទាល់រវាងប្រជាពលរដ្ឋ និងអ្នកផ្តល់សេវាអប់រំ ឆ្លើយតបបានទាន់ពេលវេលាទៅតាមតម្រូវការបន្ទាន់របស់សាលារៀន (ព្រួញជាប់) មានន័យថា មានតែអ្នកនៅមូលដ្ឋានទេ ដែលដឹងពីតម្រូវការអាទិភាពរបស់សាលារៀន ហើយអាចសម្រេចចិត្តប្រើប្រាស់ធនធានតាមតម្រូវការអាទិភាពដែលបានកំណត់ និងពិនិត្យតាមដានការ

ប្រើប្រាស់ធនធាននេះរួមគ្នា។ សិទ្ធិសម្រេចនៅថ្នាក់មូលដ្ឋាន នេះជាផ្នែកមួយនៃកម្មវិធីវិមជ្ឈការវិស័យអប់រំ ដែលស្របទៅនិងកម្មវិធីកំណែទម្រង់វិមជ្ឈការតាមបែបប្រជាធិបតេយ្យរបស់រាជរដ្ឋាភិបាល។

ការប្រើប្រាស់យន្តការអន្តរាគមន៍ ថ្នាក់មូលដ្ឋាន ធ្វើឱ្យសេវាសាធារណៈមានប្រសិទ្ធភាពដូចបាន រៀបរាប់ខាងក្រោម ។

**យន្តការអន្តរាគមន៍ឆ្ពោះទៅរកការគ្រប់គ្រងសាលារៀន**

សាប៊ែរ (SABER) បង្ហាញលទ្ធផលការសិក្សាស្រាវជ្រាវពីករណីដូចខាងក្រោម៖

១. នៅអាមេរិកឡាទីន មានករណីតិចតួចណាស់ ដែលការគ្រប់គ្រងសាលារៀនធ្វើឱ្យមានការកែប្រែខ្លាំងជាវិជ្ជមាន លើលទ្ធផលសិក្សារបស់សិស្ស (Patrinos ២០១១) ដោយហេតុថា យន្តការកិច្ចអន្តរាគមន៍ដែលបានប្រើនៅអាមេរិកឡាទីន គឺ ផ្អែកលើមូលដ្ឋានទាំងស្រុង ក្នុងបរិបទរចនាសម្ព័ន្ធស្ថាប័ននៅខ្សោយហើយសេវាសាធារណៈនៅការរំខានដោយសង្គ្រាមស៊ីវិល ។ ការប្រើប្រាស់អភិក្រមគ្រប់គ្រងតាមសាលារៀនធ្វើឱ្យមានអវត្តមានគ្រូ និងសិស្សថយចុះ តែមិនបង្ហាញពីការប្រែប្រួលជាវិជ្ជមាន លើលទ្ធផលសិក្សារបស់សិស្សនោះទេ ។

២. នៅអឺរ៉ុប មានភស្តុតាងជាច្រើនដែលបានបង្ហាញពីការប្រែប្រួលជាវិជ្ជមាន លើស្វ័យភាពសាលារៀន និងលទ្ធផលសិក្សារបស់សិស្ស (Eurydice ២០០៧) ។ យន្តការកិច្ចអន្តរាគមន៍តាមអភិក្រម ការគ្រប់គ្រងតាមសាលារៀន គឺជាដំណោះស្រាយដ៏មានប្រសិទ្ធភាព ដោយស្ថាប័នមានភាពរឹងមាំ និងសាលារៀនមានស្វ័យភាព និងគណនេយ្យភាព។ ក្នុងន័យនេះ ការគ្រប់គ្រងតាមសាលារៀន នឹងមានប្រសិទ្ធភាព ប្រសិនបើ បុគ្គលិកអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានសមត្ថភាព ធ្វើឱ្យការដឹកនាំគ្រប់គ្រងសាលារៀនឆ្លើយតបនិងតម្រូវការជាអាទិភាពរបស់សិស្ស និងគ្រូបង្រៀនទាន់ពេលវេលា។ តម្រូវការអាទិភាពរបស់សិស្ស និងគ្រូបង្រៀនត្រូវបានកំណត់តាមរយៈ ទិន្នន័យនិងព័ត៌មានពិតដែលបានមកពី ការវាយតម្លៃសិស្ស គ្រូបង្រៀន និងសាលារៀន ហើយព័ត៌មានទាំងនោះត្រូវផ្សព្វផ្សាយជាសាធារណៈ។ ការប្រើប្រាស់និងផ្សព្វផ្សាយទិន្នន័យ និងព័ត៌មានពិតជាប្រចាំ ព្រមទាំងការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព និងធ្វើ

ឱ្យសហគមន៍ បុគ្គលិកអប់រំជឿទុកចិត្តគ្នាទៅវិញទៅមកជាពិសេសធ្វើឱ្យមាតាបិតាសិស្ស/អ្នកណាព្យាបាលសិស្សមានទំនុកចិត្តលើគ្រូបង្រៀននិងសាលារៀន។

**ចក្ខុវិស័យសហគន៍សាលារៀន**

*១. បេសកកម្ម*

(១) បណ្តុះសិស្សឱ្យមានបំណិនខ្ពស់សម្រាប់ជីវិត និង ការងារ និងត្រៀមជាស្រេចដើម្បីចូលរៀននៅ គ្រឹះស្ថានឧត្តមសិក្សា ឬ ចូលរួមទីផ្សារការងារ និង

(២) កែលម្អការអនុវត្តរបស់សាលារៀនឱ្យបំពេញបានស្តង់ដាសាលារៀនមានប្រសិទ្ធិភាព។ សាលារៀន និងជួយដល់សិស្សទាំងអស់ដោយគ្មានការរើសអើងលើភាពក្រីក្រ យេនឌ័រ ពិការភាព ជនជាតិភាគតិច (បរិយប័ន្ន សមធ៌ម)។

*២. គោលបំណង*

(១) ចំនួនសិស្ស ៨០ទៅ៨៥% មានបំណិនខ្ពស់សម្រាប់ជីវិតនិងការងារនិងត្រៀមជាស្រេចដើម្បីចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ឬ ចូលរួមទីផ្សារការងារ មុនឆ្នាំ២០៣០

(២) សាលារៀនបានបំពេញតាមស្តង់ដា យុទ្ធសាស្ត្រសហគមន៍សាលារៀននៅ៦ឆ្នាំក្រោយ។ សាលារៀន និងជួយដលើសិស្សទាំងអស់ដោយគ្មានការរើសអើងលើភាពក្រីក្រ យេនឌ័រ ពិការភាព ជនជាតិភាគតិច (បរិយប័ន្ន សមធ៌ម)។

*៣. យុទ្ធសាស្ត្រ និង ការផ្លាស់ប្តូរ*

**យុទ្ធសាស្ត្រសហគមន៍សាលារៀន (៦អា)**

រូបភាពទី ៣៖ យុទ្ធសាស្ត្រសហគមន៍សាលារៀន (៦អា)



ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *សេចក្តីណែនាំ ប្រតិបត្តិ យុទ្ធសាស្ត្រ សហគមន៍សាលារៀន*

*ការអនុវត្តយុទ្ធវិធីនាំឱ្យមានការផ្លាស់ប្តូរ*

១. ការធ្វើតេស្តវាស់សមត្ថភាពសិស្ស និងបិទផ្សាយលទ្ធផលជាសាធារណៈ នាំឱ្យមានការទាមទារពីអតិថិជនពីសេវាសាធារណៈនិងការបង្រៀនមានគុណភាព

២. សហគមន៍មានអំណាចសម្រេចចិត្តលើផែនការ ថវិកា និងកិច្ចការសាលារៀន នាំឱ្យសហគមន៍ក្លាយជាម្ចាស់សាលារៀន និង ជួយដល់សាលារៀន

៣. នាយកសាលាប្រើប្រាស់សិទ្ធិប្រតិបត្តិជានាកិច្ចការរដ្ឋបាលសាលារៀន និងបង្ហាញលទ្ធផលសិក្សា ចំណូល ចំណាយ និងការរីកចម្រើនស្តង់ដារសាលារៀនជាសាធារណៈដែលនាំឱ្យសហគមន៍ជឿជាក់លើសាលារៀន គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

៤. ត្រូវយកចិត្តទុកដាក់ថែរក្សាគ្រូបង្រៀន ទាំងសមត្ថភាព និង ការរស់នៅ វាជាគន្លឹះក្នុងការកសាងកិច្ចសន្យាសង្គមរវាងគ្រូបង្រៀន មាតាបីតាសិស្សនិងសិស្ស និងសហគមន៍ហើយវានាំឱ្យពួកគេធ្វើការងាររបស់ខ្លួនដើម្បីគាំទ្រការរៀនសូត្ររបស់សិស្ស

៥. ការអនុវត្តវប្បធ៌ម ធ្វើឱ្យបុគ្គលិកអប់រំទាំងអស់ក្នុងសាលារៀន គោរពគ្នាដោយប្រើអំណាចសម្រាប់ដើម្បីបំពេញកិច្ចដែលត្រូវធ្វើ មិនប្រើអំណាចខុសគោលដៅ ឬប្រើធនធានរបស់សាលាដើម្បីប្រយោជន៍បុគ្គល ឬឯការអនុវត្តគុណតម្លៃ ជាកត្តានាំឱ្យមនុស្សម្នាក់ៗក្លាយជាមនុស្សល្អដោយសារបុគ្គលម្នាក់ៗធ្វើតែអ្វីដែលត្រូវ ហើយជួយដល់មនុស្សទាំងអស់ក្នុងសហគមន៍

៦. ការយកចិត្តទុកដាក់លើការអប់រំថែទាំកុមារតូចគឺជា កត្តាគន្លឹះនាំឱ្យកុមារមានសមត្ថភាពគ្រឹះដូចជាសមត្ថភាពទំនាក់ទំនង អាហារូបត្ថម្ភល្អ ហើយមានខួរក្បាលពេញលេញ អក្ខរកម្ម និងចិត្តសង្គម និងសមត្ថភាពទាំងនេះនឹងនាំឱ្យក្រុមកុមារម្នាក់ៗក្លាយជាធនធានមនុស្សដ៏សំខាន់សង្គមនៅអនាគត។

គ្រប់ការផ្លាស់ប្តូរគឺចាប់ផ្តើមពីមួយ ពោលគឺអ្នកហ្នឹងហើយជាអ្នកចាប់ផ្តើម៖

១. ការផ្លាស់ប្តូរគឺដោយសារវាមានគ្រឹះមួយដែលរឹងមាំ គ្រឹះនោះគឺ ពុំមាននណាម្នាក់ចង់ក្រទេ ហើយមនុស្សគ្រប់គ្នាម្នាក់ៗ ចង់ក្លាយជាមនុស្សល្អ

២. ផ្តើមពីនាំសិស្សម្នាក់ផ្លាស់ប្តូរ និងនាំសិស្សទាំងអស់ក្នុងថ្នាក់ផ្លាស់ប្តូរ

៣. ផ្តើមពីថ្នាក់រៀនមួយផ្លាស់ប្តូរ ថ្នាក់រៀនទាំងអស់ក្នុងសាលារៀនផ្លាស់ប្តូរ

៤. ផ្តើមពីសាលារៀនមួយផ្លាស់ប្តូរ ទៅសាលារៀនទាំងអស់ក្នុងក្រុង ស្រុក ខ័ណ្ឌផ្លាស់ប្តូរ

៥. ផ្តើមពីក្រុង ស្រុក ខ័ណ្ឌមួយផ្លាស់ប្តូរ ទៅក្រុង ស្រុក ខ័ណ្ឌទាំងអស់ក្នុងរាជធានី ខេត្តផ្លាស់ប្តូរ

៦. ផ្តើមពីរាជធានី ខេត្តមួយផ្លាស់ប្តូរ ទៅរាជធានី ខេត្តទាំងអស់ក្នុងប្រទេសផ្លាស់ប្តូរ។

### *៤. វប្បធម៌សហគមន៍សាលារៀន*

ជារបៀបធ្វើកិច្ចការតាមបែបវិមជ្ឈការអំណាចទៅសហគមន៍ និងសាលារៀន ដែលនាំឱ្យគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្ស និងសហគមន៍ មានកិច្ចការច្បាស់លាស់ និងទទួលខុសត្រូវជាមួយនឹងកិច្ចការរបស់ខ្លួន។

### *៥. គុណតម្លៃសហគមន៍សាលារៀន*

ជាការអនុវត្តគំនិតល្អដែលព្រមព្រៀងគ្នាក្នុងរយៈពេលមួយកំណត់ គំនិតល្អនោះនិងក្លាយជាគុណ តម្លៃ។ សាលារៀននិងសហគមន៍៖

១. និងបម្រើប្រយោជន៍ និងប្រសើរបំផុតសម្រាប់ប្រជាជននិងសិស្ស

២. គោរពនិងថែទាំគ្នាទៅវិញទៅមក

៣. រៀនសូត្រនិងធ្វើការជាក្រុមជាប់ជាប្រចាំ

៤. ផ្តួចផ្តើមគំនិតថ្មីដើម្បីអភិវឌ្ឍសាលារៀន និង សហគមន៍

៥. ធ្វើឱ្យមាននិរន្តរភាពពីដំណើរការសាលារៀននិងរៀបចំសិស្សរបស់យើងសម្រាប់រស់នៅជាមួយជីវិតនិងការងារដែលប្រសើរ។

### ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្ត

ក្របខណ្ឌនិងលំដាប់អនុវត្តយុទ្ធសាស្ត្រសហគមន៍និងសាលារៀន

**របនាសម្ព័ន្ធ**

រូបភាពទី ៤៖ ក្របខណ្ឌនិងលំដាប់អនុវត្តយុទ្ធសាស្ត្រសហគមន៍និងសាលារៀន




ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *សេចក្តីណែនាំ ប្រតិបត្តិ យុទ្ធសាស្ត្រ សហគមន៍សាលារៀន*

| **ដំណាក់កាលអភិវឌ្ឍសហគមន៍សាលារៀនជាការទទួលខុសត្រូវរួមគ្នារវាងនាយកសលា គណៈកម្មការគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន** |
|---|
| ឆ្នាំទី១ ការធ្វើឱ្យសាលារៀននិងថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សារៀនសូត្រ |
| ឆ្នាំទី២ ការធ្វើឱ្យសាលារៀនបំពេញបានស្តង់ដាអប្បបរិមាសាលារៀនមានប្រសិទ្ធិភាព |
| ឆ្នាំទី៣ ឆ្ពោះទៅរកការរក្សានិរន្តរភាពសាលារៀនជាមួយកម្មវិធីបំណិនរកចំណូល |
| ឆ្នាំទី៤ សាលារៀនមានដំណើរការប្រកបដោយនិរន្តរភាព និងឈានឆ្ពោះទៅដូចសាលារៀននៃប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ |

## តួនាទី និងស្តង់ដាសហគមន៍សាលារៀន

| តួនាទី | ស្តង់ដាសហគមន៍សាលារៀន |
|---|---|
| គណៈគ្រប់គ្រងសាលារៀន | ស្តង់ដាទី១៖សាលារៀនមានដំណើរការសម្រាប់ផលសម្រេចការអប់រំ និងការសិក្សាសិស្ស |
| គ្រូបង្រៀន | ស្តង់ដាទី២៖ ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀននិងការសិក្សារបស់សិស្សម្នាក់ៗ |
| គណៈកម្មការគ្រប់គ្រងសាលារៀន | ស្តង់ដាទី៣៖ ភាពជាម្ចាស់របស់សហគមន៍សាលារៀន |
| គណៈគ្រប់គ្រងសាលារៀន | ស្តង់ដាទី៤៖ ដំណើរការរដ្ឋបាលនិងប្រតិបត្តិការសហគមន៍សាលារៀន |
| ថ្នាក់ជាតិនិងក្រោមជាតិ | ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ជាតិនិងក្រោមជាតិ |

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងដំណើរការនៃការស្រាវជ្រាវទៅលើប្រធានបទស្ដីពី **"សាកល្បងសិក្សាលើទំនាក់ទំនងរវាងទំនាក់ទំនងរវាងគណនេយ្យភាពសាលារៀន និងការចូលរួមរបស់សហគមន៍ នៅវិទ្យាល័យមេសាង ច័ន្ទក្រឹស្នា និងវិទ្យាល័យ អង្គរស ក្នុងស្រុកមេសាង "** អ្នកសិក្សាស្រាវជ្រាវបានកំណត់យកការស្រាវជ្រាវ ដោយផ្ដោតទៅលើ វិធីសាស្ត្រនៃការស្រាវជ្រាវ ការជ្រើសរើសភាគសំណាក កម្រងសំណួរ ការកសាងឧបករណ៍ស្រាវជ្រាវ ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ដូចខាងក្រោមនេះ៖

## ៣.១ វិធីស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ អ្នកការស្រាវជ្រាវបានប្រើវិធីស្រាវជ្រាវតាមបែបបរិមាណវិស័យ (ទំនាក់ទំនងអថេរ)។ ការស្រាវជ្រាវតាមបរិមាណវិស័យនេះគឺមានគោលបំណងសិក្សាលើថាតើគណនេយ្យភាពសាលារៀន និងការចូលរួមរបស់សហគមន៍ មានទំនាក់ទំនងគ្នាដែរឬទេ បើមានតើមានកម្រិតណា? ឃើញបញ្ហាប្រឈមផ្សេងៗដែលមាន និងដំណោះស្រាយទៅលើបញ្ហាទាំងនោះហើយម្យ៉ាងទៀត ក្នុងដំណើរការអនុវត្តគណនេយ្យភាពសាលារៀន តើមានទំនាក់ទំនងគ្នាដល់កម្រិតណា ដើម្បីឱ្យអ្នកស្រាវជ្រាវបានដឹង និងយល់ច្បាស់ពីឫសគល់និងហេតុផលទាំងឡាយពីអ្នកចូលរួមនៅក្នុងការអនុវត្តគណនេយ្យភាពសាលារៀនដើម្បីអោយសហគមន៍មមានការចូលរួមនៅកម្រិតមធ្យមសិក្សាក្នុងខេត្តព្រៃវែង។

## ៣.២ ការជ្រើសរើសភាគសំណាក

ក្នុងការជ្រើសរើសភាគសំណាកដែលត្រូវយកមកវិភាគបានកំណត់យកសាលាចំនួន ០៣ ក្នុងស្រុកមេសាង ដើម្បីយកមកធ្វើការស្រាវជ្រាវលើប្រធានបទនេះ គឺអ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសតាមគោលដៅដែលបានកំណត់ទុក ដោយសំដៅយកតែភាគសំណាកទាំងឡាយណា ដែលអ្នកស្រាវជ្រាវពិតជាជឿជាក់ថា ភាគសំណាកទាំងអស់នោះអាចទទួលបាននូវទិន្នន័យបានជាក់លាក់ ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ ដូចនេះភាគសំណាកដែលអ្នកសិក្សាស្រាវជ្រាវយល់ថា អាចផ្ដល់បាននូវទិន្នន័យទាំងនោះមាន៖ លោកគ្រូ អ្នកគ្រូ ទាំង០៣ វិទ្យាល័យ សរុបទាំងអស់ ១៧៣រូប ដែលជាគ្រូ

មធ្យមសិក្សាចំណោះទូទៅ ។ នៅក្នុងភាគសំណាកដែលបានជ្រើសរើសទាំងអស់នេះ សុទ្ធតែជាអ្នកដែលបានដឹងនិងចូលរួមយ៉ាងសកម្មនៅក្នុងការអនុវត្តគណនេយ្យភាព សាលារៀន និង កៀរគសហគមន៍ឱ្យមានការចូលរួមនៅមធ្យមសិក្សាក្នុងខេត្តព្រៃវែង ។ ដោយមូលហេតុនេះហើយ ទើបបានជាអ្នកសិក្សាស្រាវជ្រាវជឿជាក់ថា ភាគសំណាកទាំងនេះពិតជាអាចផ្តល់នូវទិន្នន័យ ដែលទាក់ទងទៅនឹងប្រធានបទខាងលើបានជាក់លាក់ និងពិតប្រាកដ។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ដោយដឹងហើយថាក្នុងការស្រាវជ្រាវនេះដើម្បីទទួលបាននូវទិន្ន័យ អ្នកស្រាវជ្រាវបានបង្កើតជាកម្រងសំណួរឡើង ដោយផ្អែកលើវត្ថុបំណងនៃការស្រាវជ្រាវ និងទាក់ទងទៅនិងប្រធានបទ ដើម្បីយកទៅជូនអ្នកដែលបានចូលរួមបំពេញ។ នៅក្នុងកម្រងសំណួរដែលបានបង្កើតឡើងមកនេះបានបែងចែកមានបីផ្នែកសំខាន់ គឺ ផ្នែកទីមួយជាព័ត៌មានស្ថានភាពទូទៅរបស់លោកគ្រូ អ្នកគ្រូ ។ សម្រាប់ផ្នែកទីពីរគឺជាការអនុវត្តគណនេយ្យភាពសាលារៀន ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការអនុវត្តការងារប្រតិបត្តិសាលារៀន ដោយមានការសរសេររៀបរាប់ពីសកម្មភាព សំខាន់ៗដែលបានអនុវត្តនៅក្នុងសាលា និងការគូសសញ្ញាជីកនៅត្រង់ចំណុចដែលសំណាកយល់តាមកម្រិតនៃប្រយោគនីមួយ។ ចំណែកផ្នែកទីបី គឺស្តីពីការចូលរួមរបស់សហគមន៍ ដោយតម្រូវឱ្យសំណាកលើកឡើងពីកម្រិតនៃការចូលរួមរបស់សហគមន៍ ដែលអាចកើតមានឡើងក្នុងការអនុវត្តក្នុងសាលា ដូចជា ការអនុវត្តផែនការការគាំទ្រពីសាលា។ កម្រងសំណួរដែលអ្នកស្រាវជ្រាវបានបង្កើតឡើង ដូចបានរៀបរាប់ខាងលើនេះ ត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវយ៉ាងហ្មត់ចត់ និងមានការឯកភាពពីគ្រូដឹកនាំ។

ទិន្នន័យដែលប្រមូលបានមក គឺជាព័ត៌មានសម្រាប់គាំទ្រដល់ការសិក្សាស្រាវជ្រាវមួយនេះ និងអាចជាព័ត៌មានសម្រាប់ដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងការអនុវត្តគណនេយ្យភាពសាលារៀននៅមធ្យមសិក្សាក្នុងខេត្តព្រៃវែង។ ដើម្បីប្រមូលបាននូវទិន្នន័យដ៏ជាក់លាក់ និងជឿជាក់បាន នោះជាការចាំបាច់ខ្លាំងណាស់ក្នុងការបង្កើតនូវឧបករណ៍ស្រាវជ្រាវនេះឡើង សម្រាប់ប្រមូលទិន្នន័យពីភាគសំណាកដែលបានកំណត់តាម Random sampling ក្នុងគោលបំណងដើម្បីស្វែងរកឱ្យឃើញច្បាស់ពីកម្រិតយល់

ដឹងជាក់ស្តែងរបស់ពួកគាត់ បញ្ហាប្រឈម និងដំណោះស្រាយនានា ដើម្បីឱ្យគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធឆ្លើយតបបានត្រឹមត្រូវទៅ នឹងតម្រូវការជាក់ស្តែងរបស់ពួកគាត់ ព្រមទាំងរកឱ្យឃើញនូវកម្រិត នៃទំនាក់ទនងក្នុងការអនុវត្តគណនេយ្យភាព និងទាក់ទាញការចូលរួមពីសហគមន៍ ដើម្បីរុញច្រាននូវ ប្រសិទ្ធភាព គុណភាព អប់រំកាន់តែមានសក្តសិទ្ធភាព ។

## ៣.៤ ការប្រមូលទិន្នន័យ

ក្នុងការស្រាវជ្រាវប្រធានបទខាងលើ អ្នកស្រាវជ្រាវបានប្រមូលទិន្នន័យនិងព័ត៌មានមួយចំនួនពីសៀវភៅ និងឯកសារផ្សេងៗដូចជា សេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន សៀវភៅណែនាំប្រតិបត្តិ ស្តីពីការគ្រប់គ្រងតាមសាលារៀន SBM ទិន្នន័យដែលបានមកតាមរយៈកម្រងសំណួរ។ ចំពោះទិន្នន័យដែលបានមកពីសៀវភៅនិងឯកសារ អ្នកស្រាវជ្រាវបានដកស្រង់នូវខ្លឹមសារដែលទាក់ទងនឹងប្រធានបទ ដើម្បីយកធ្វើជាឯកសារពិគ្រោះក្នុងការសរសេររៀបរៀងអត្ថបទស្រាវជ្រាវ ដោយភាគច្រើនមាននៅក្នុងសេចក្តីផ្តើម និងរំឭកទ្រឹស្តី ហើយបានសរសេររៀបរាប់ទៅតាមលំដាប់លំដោយនៃខ្លឹមសារ។ ឯកសារនិងសៀវភៅទាំងនេះមានទាំង ភាសាខ្មែរ និងភាសាអង់គ្លេស ដែលអ្នកស្រាវជ្រាវរកបានពីបណ្ណាល័យ កន្លែងបម្រើការងារ និងទាញយកពីអ៊ីនធឺណែត ដើម្បីធ្វើជាឯកសារ។

ម្យ៉ាងទៀត ចំពោះទិន្នន័យដែលទទួលបានមកតាមរយៈកម្រងសំណួរ អ្នកស្រាវជ្រាវបានអនុវត្តទៅតាមជំហានបន្តបន្ទាប់។ ដើម្បីឱ្យដំណើរការចុះប្រមូលទិន្នន័យមាន លក្ខណៈជាផ្លូវការ និងដើម្បីឱ្យការប្រមូលទិន្នន័យមានភាពរលូនល្អ អ្នកស្រាវជ្រាវបានយកលិខិតសុំអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំទៅសុំជួបជាមួយថ្នាក់ដឹកនាំមន្ទីរអេប់រំ យុវជន និងកីឡាខេត្តព្រៃវែង បន្ទាប់មកជាក់ជូនរដ្ឋបាលស្រុក និងគណៈគ្រប់គ្រងនៅតាមវិទ្យាល័យដែលអ្នកស្រាវជ្រាវចុះប្រមូលទិន្នន័យ ដើម្បីជម្រាបពីគោលបំណង និងសុំអនុញ្ញាតធ្វើការប្រមូលទិន្នន័យនៅទីតាំង ទាំងនោះ។ អ្នកស្រាវជ្រាវបានស្នើសុំដល់ភាគសំណាកឱ្យបំពេញកម្រងសំណួរតាមពេលកំណត់ជាក់លាក់ ដោយក្នុងនោះដែរ អ្នកស្រាវជ្រាវបានពន្យល់ណែនាំពីរបៀបបំពេញកម្រងសំណួរជារួមក្នុងសាលប្រជុំ ដើម្បីឱ្យប្រាកដប្រជាថាទិន្នន័យដែលទទួលបានមកគឺជាទិន្នន័យល្អ ប្រកបដោយភាពជាក់លាក់ និងជឿទុកចិត្តបាន សម្រាប់គាំទ្រដល់ប្រធានបទស្រាវជ្រាវខាង

លើ។ បន្ទាប់មក អ្នកស្រាវជ្រាវបានប្រមូលកម្រងសំណួរ រួចយកទិន្នន័យក្នុងកម្រងសំណួរមករៀបរៀងសរសេរតាមវត្ថុបំណងនៃការស្រាវជ្រាវ និងតាមលំដាប់លំដោយខ្លឹមសារ។

នៅក្នុងការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានប្រជុំណែនាំ និងពន្យល់ពីរបៀបបំពេញកម្រងសំណួរ ក្នុងបរិយាកាសស្និទ្ធស្នាលប្រកបដោយភាតរភាព និងបានស្នើសុំភាគសំណាកឱ្យបំពេញតាមភាពជាក់ស្តែង តាមខ្លឹមសារនីមួយៗ ដោយមិនតម្រូវឱ្យដាក់ឈ្មោះ ឬបង្ហាញព័ត៌មានដែលនាំឱ្យគេស្គាល់ពីអត្តសញ្ញាណរបស់ភាគសំណាកឡើយ ដើម្បីចៀសវាងការមានឥទ្ធិពលទៅលើការបំពេញកម្រងសំណួរ។ អាស្រ័យហេតុនេះ អ្នកស្រាវជ្រាវសូមបញ្ជាក់អះអាងថាទិន្នន័យដែលលោកគ្រូអ្នកគ្រូបានបំពេញក្នុងកម្រងសំណួរជាគំនិតផ្ទាល់ខ្លួនរបស់ពួកគាត់ពិតប្រាកដ គឺមិនស្ថិតក្រោមឥទ្ធិពល ឬការបង្គាប់បញ្ជាពីអ្នកស្រាវជ្រាវ ឬភាគីណាមួយឡើយ ។

## ៣.៥ ការវិភាគទិន្នន័យ

ដោយសារការស្រាវជ្រាវប្រធានបទខាងលើនេះ ជាការស្រាវជ្រាវតាមបែបបរិមាណវិស័យនោះ អ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យ ដែលទទួលបានមកពីកម្រងសំណួរតាមបែបបរិមាណវិស័យ ដែរ។ ចំពោះការវិភាគតាមបែបបរិមាណវិស័យ អ្នកស្រាវជ្រាវបានយកទិន្នន័យពីកម្រងសំណួរមករៀបចំតាមលំដាប់លំដោយខ្លឹមសារ ដោយផ្តោតសំខាន់លើផ្នែកទីពីរ និងទីបីនៃកម្រងសំណួរ ដើម្បីដឹងពីចំនួន និងកម្រិតនៃការយល់ដឹង និងការអនុវត្តរបស់ នាយក គ្រូ និងសហគមន៍ឱ្យបាន ច្បាស់លាស់។ អ្នកស្រាវ- ជ្រាវបានធ្វើការវិភាគទិន្នន័យដោយប្រើកម្មវិធី SPSS ដើម្បីឱ្យការវិភាគទទួលបានការជឿជាក់ និងទុកចិត្តខ្ពស់ ជាជំនួយក្នុងការធ្វើតារាងសង់ក្រាប (Chart)។ លទ្ធផលនៃការវិភាគដែលទទួលបានតាមរយៈ Chart ត្រូវបានវិភាគបកស្រាយហេតុផល ដោយឈរលើមូលដ្ឋានទទ្បីករណ៍ជាក់ស្តែង។

# ជំពូកទី៤
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ

## ៤.១ លទ្ធផលនៃការស្រាវជ្រាវ

អ្នកចូលរួមចំនួន១៧៣នាក់(N=១៧៣)បានបំពេញកម្រងសំណួរដែលមានសំណួរចំនួន៣៩ ដោយទទួលបាននូវកម្រិតជឿទុកចិត្តបាន Cronbach Alpha (α=0,៩៤២) ដែលជាចំនួនខ្ពស់បំផុតល្អឥតខ្ចោះ។ ការណ៍នេះបញ្ជាក់ថា អ្នកចូលរួមទាំង១៧៣នាក់បានបំពេញកម្រងសំណួរដោយយកចិត្តទុកដាក់ និងត្រឹមត្រូវតាមការណែនាំរបស់អ្នកស្រាវជ្រាវ។

ក្រោយពីវិភាគទិន្នន័យរួច វិធី Linear Regression ត្រូវបានប្រើប្រាស់ ដើម្បីស្វែងរកចម្លើយទៅនឹងសំណួរស្រាវជ្រាវទាំង២ ព្រោះជាការសិក្សាស្រាវជ្រាវបែបទំនាក់ទំនង (Correlational Study)។ ការប្រើប្រាស់វិធី Linear Regression ដើម្បីស្វែងរកទំនាក់ទំនងរវាងអថេរឯករាជ្យ(SA) និងអថេរមិនឯករាជ្យ (CE)។ វិធី Linear Regression ត្រូវបានប្រើប្រាស់ដោយផ្អែកលើហេតុផលទី១)អថេរទាំង២ជាប្រភេទបន្តគ្នា (Continuous) ទី២)ទំនាក់ទំនងមានលក្ខណៈជាបន្ទាត់រវាងអថេរមួយទៅអថេរមួយទៀត (Linear Relationship)ដើម្បីបង្កើតបានជាផ្ទាំងជ្យាក្រាមរាយប៉ាយ (Scatterplot) និងទី៣) Durbin-Watson Test ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងកម្រិតទំនាក់ទំនងដោយស្វ័យប្រវត្តិដែលមានសំណល់ពីការវិភាគ (Regression Analysis)។ ក្នុងន័យនេះ Durbin-Watson Test មានតម្លៃពី០ដល់៤ ដែលតាមគោលការណ៍ច្បាប់បង្ហាញថា តម្លៃទាំងឡាយណាដែលស្ថិតនៅចន្លោះពី១,៥ទៅ២,៥បញ្ជាក់ពីភាពមានទំនាក់ទំនងគ្នាជាធម្មតា ដែលអាចទទួលយកបាន។

**សំណួរស្រាវជ្រាវទី១)** តើគណនេយ្យភាពសាលារៀន (School Accountability)មានទំនាក់ទំនងទៅនឹងការចូលរួមរបស់សហគមន៍ដែរឬទេ(Community Engagement)?

ដើម្បីអាចឆ្លើយទៅនឹងសំណួរស្រាវជ្រាវទី១បាន **តារាង១ តារាង ២** និង**តារាង ៣** បង្ហាញជាលទ្ធផល Regression Model មានទំនាក់ទំនងជាមួយអថេរមិនឯករាជ្យយ៉ាងសំខាន់ β=0,៧៣៨ t= ១៤,២៩៨ F (១, ១៧១)=២០៤,៤៣៤ p=0,០០០។ ការណ៍នេះមានន័យថា। គម្រូនេះ (Regression Model) មានសារៈសំខាន់បែបស្ថិតិ (Statistically Significant) ព្រោះ អាចមានដំណើរការបានដោយ =

០,០០០ ដែលជាចំនួនមួយតិចជាង០,០៥ទៅទៀត។ គម្រូសមល្មមទៅនឹងទិន្នន័យដែលប្រមូលបាន។ ដូចនេះ សំណួរស្រាវជ្រាវទី១ឆ្លើយថា គណនេយ្យភាពសាលារៀន មានទំនាក់ទំនងនឹងការចូលរួមរបស់សហគមន៍។

តារាងទី ១៖ Model Summary

| Model Summary [b] | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| Model | R | R Square | Adjusted R Square | Std. Error of the Estimate | Change Statistics | | | | | Durbin-Watson |
| | | | | | R Square | F Change | df1 | df2 | Sig. F Change | |
| 1 | .738[a] | .545 | .542 | .28595 | .545 | 204.434 | 1 | 171 | .000 | 2.067 |

តារាងទី ២៖ ANOVA

| ANOVA [a] | | | | | | |
|---|---|---|---|---|---|---|
| Model | | Sum of Squares | df | Mean Square | F | Sig. |
| 1 | Regression | 16.716 | 1 | 16.716 | 204.434 | .000[b] |
| | Residual | 13.982 | 171 | .082 | | |
| | Total | 30.698 | 172 | | | |
| a. Dependent Variable: MeanCE | | | | | | |
| b. Predictors: (Constant), MeanSA | | | | | | |

តារាងទី៣៖ Coefficients

| Coefficients[a] | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Model | | Unstandardized Coefficients | | Standardized Coefficients | t | Sig. | 95.0% Confidence Interval for B | |
| | | B | Std. Error | Beta | | | Lower Bound | Upper Bound |
| 1 | (Constant) | .644 | .235 | | 2.735 | .007 | .179 | 1.109 |
| | MeanSA | .843 | .059 | .738 | 14.298 | .000 | .727 | .960 |
| a. Dependent Variable: MeanCE | | | | | | | | |

**សំណួរស្រាវជ្រាវទី២)** តើគណនេយ្យភាពសាលារៀន (school accountability)មានទំនាក់ទំនងដល់កម្រិតណា ទៅលើការចូលរួមរបស់សហគមន៍(community engagement)?

យោងតាម**តារាង១** លទ្ធផលបញ្ជាក់ឱ្យឃើញថាមេគុណទំនាក់ទំនង (Correlation Coefficient r=0,៧៣៨) ដែលជាចំនួនមួយខ្ពស់ខិតទៅរកលេខ១។ មេគុណទំនាក់ទំនងមានក្រិតលេខពី -១ទៅ១។ ម្យ៉ាងវិញទៀត Durbin-Watson Test មានចំនួន២,០៦៧ ដែលជាចំនួនមួយខ្ពស់ខិតទៅជិត២,៥ បង្ហាញពីកម្រិតទំនាក់ទំនងខ្ពស់។ លទ្ធផលរូបភាព៥ ក៏បង្ហាញពីកម្រិតទំនាក់ទំនងខ្ពស់ដែលបណ្តុំទិន្នន័យទទួលបានស្ទើតែមានលក្ខណៈជាបន្ទាត់ត្រង់ ដោយគ្មានសំណល់ និងគ្មានបណ្តុំទិន្នន័យដែលចាកចេញពីបណ្តុំបន្ទាត់។ ដូចនេះ សំណួរស្រាវជ្រាវទី២ ឆ្លើយថា គណនេយ្យភាពសាលារៀនពិតជាមានទំនាក់ទំនងខ្លាំងទៅនឹងការរួមរបស់សហគមន៍សាលា។

រូបភាពទី ៥៖ កម្រិតទំនាក់ទំនងខ្ពស់ដែលបណ្តុំទិន្ន័យទទួលបាន




## ៤.២ ដែនកំណត់នៃការស្រាវជ្រាវ

តារាងទី ៤៖ វិទ្យាល័យទាំងបី គ្រូបង្រៀនមានអាយុ

**Age**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | <30 | 32 | 18.5 | 18.5 | 18.5 |
| | 30 -45 | 117 | 67.6 | 67.6 | 86.1 |
| | >45 | 24 | 13.9 | 13.9 | 100.0 |
| | Total | 173 | 100.0 | 100.0 | |

តាមតារាងខាងលើនេះបង្ហាញថា គ្រូបង្រៀននៅវិទ្យាល័យទាំងបី ភាគច្រើនមានអាយុចន្លោះពី ៣០ ទៅ ៤៥ឆ្នាំ ព្រោះសាលាមានគ្រូគ្រប់ គណៈគ្រប់គ្រងសាលារៀន មិនបានស្នើគ្រូបន្ថែមទេ ហើយមួយវិញទៀត ជាវ័យមួយពោរពេញទៅថាមពលក្នុងការអភិវឌ្ឍន៍សមត្ថភាព និងងាយទទួលយកនូវចំណេះដឹង

ថ្មីៗ នឹងបទពិសោធន៍ល្អ ដើម្បីបំពេញតួនាទីរបស់ខ្លួនប្រកបដោយគុណភាព និងប្រសិទ្ធិភាពខ្ពស់ក្នុងវិស័យអប់រំ ទើបវិទ្យាល័យទាំងបី បោះសម្លេងល្បី ដោយមានសិស្សពូកែថ្នាក់ជាតិរាល់ឆ្នាំ និង សំបូរសិស្សនិទ្ទេសA។

តារាងទី ៥៖ វិទ្យាល័យទាំងបី គ្រូបង្រៀនមានភេទ

**Gender**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Female | 42 | 24.3 | 24.3 | 24.3 |
| | Male | 131 | 75.7 | 75.7 | 100.0 |
| | Total | 173 | 100.0 | 100.0 | |

តាមលទ្ធផលវិភាគនៅក្នុងតារាងនេះបង្ហាញថា គ្រូបង្រៀននៅវិទ្យាល័យទាំងបីភាគច្រើនជាបុរស ចំណែកគ្រូបង្រៀនជាស្ត្រីមានចំនួនតិចបើប្រៀបធៀប ទៅនឹងបុរស ។ ដូចនេះបញ្ជាក់ឲ្យឃើញថា ស្ត្រីនៅជនបទទទួលបានឪកាសសិក្សារៀនសូត្រមិនបានច្រើនដូចបុរសនៅឡើយ ហើយសម្លេងរបស់ពួកគេក្នុងការចូលរួមលើកពីតម្រូវ ដាក់ចូលក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានតិចទួចដែលមិនអាចឆ្លើយតបទៅនឹងតក្រូវរបស់ពួកគេបានពេញលេញនៅឡើយ ។

តារាងទី ៦៖ វិទ្យាល័យទាំងបី គ្រូបង្រៀនមានបទពិសោធ

**Workexperience**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | <5 years | 20 | 11.6 | 11.6 | 11.6 |
| | 5-10 years | 45 | 26.0 | 26.0 | 37.6 |
| | >10 years | 108 | 62.4 | 62.4 | 100.0 |
| | Total | 173 | 100.0 | 100.0 | |

តាមតារាងនេះបង្ហាញថាគ្រូបង្រៀនភាគច្រើនមានអាយុចន្លោះពី ៣០ ទៅ ៤៥ឆ្នាំ ។ ហើយពួកគេមានបទពិសោធន៍ក្នុងការបង្រៀនច្រើនជាង១០ឆ្នាំលើវិស័យអប់រំកម្រិតមធ្យមសិក្សាចំណេះទូទៅ នៅវិទ្យាល័យទាំងបី ក្នុងស្រុកមេសាង ។

នេះបង្ហាញឲ្យឃើញពីលោកគ្រូ អ្នកគ្រូ មានបទពិសោធន៍ ក្នុងវិស័យអប់រំ វិធីសាស្ត្រក្នុងការបង្រៀន/ផ្ទេរចំណេះដឹងដល់សិស្សប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

តារាងទី ៧៖ វិទ្យាល័យទាំងបី គ្រូបង្រៀនមានកម្រិតវប្បធម៌

**Qualification**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Associate | 28 | 16.2 | 16.2 | 16.2 |
| | BA | 131 | 75.7 | 75.7 | 91.9 |
| | MA | 14 | 8.1 | 8.1 | 100.0 |
| | Total | 173 | 100.0 | 100.0 | |

តាមតារាងទិន្ន័យខាងលើបានបង្ហាញពីកម្រិតវប្បធម៌/សញ្ញាបត្ររបស់គ្រូបង្រៀនៅវិទ្យាល័យទាំងបីនៅស្រុកមេសាង ភាគច្រើនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ នេះបញ្ជាក់ថាគ្រូបង្រៀនមានសមត្ថភាព និងចំណេះដឹងគ្រប់គ្រាន់ក្នុងការផ្តល់ចំណេះដឹងដល់សិស្ស នៅថ្នាក់មធ្យមសិក្សាចំណេះទូទៅ ។

តារាងទី ៨៖ វិទ្យាល័យទាំងបី ចំនួនគ្រូបង្រៀនដែលបានចូលរួមក្នុងការប្រមូលទិន្នន័យ

**Workplace**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Mesang High school | 90 | 52.0 | 52.0 | 52.0 |
| | Chan kreosna High school | 43 | 24.9 | 24.9 | 76.9 |
| | Angkor Sor | 40 | 23.1 | 23.1 | 100.0 |
| | Total | 173 | 100.0 | 100.0 | |

អង្គរស មានគ្រូជាសំណាក ៤០ និង ៤៣នាក់ ព្រោះនៅវិទ្យាទាំងពីរនេះ មានគ្រូសរុបតែ ៦០នាក់ប៉ុណ្ណោះ នេះបង្ហាញថាការយកសំណាក បានពី ៧០ទៅ ៨០ភាគរយនៃចំនួនប្រជាករសរុប វានឹងបង្ហាញលទ្ធផលនៃភាពជឿជាក់ខ្ពស់ ក្នុងការស្រាវជ្រាវនេះ ។

